៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៩ ខែ មីនា

ព.ស. ២៥០៩ គ.ស. ១៩៦៧

- ភ្នំពេញ -

...NATIONALE
DU CAMBODGE
P.K. 1
1967. 3

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* ទំព័រ

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . . ២២៩
២– ព្រះត្រៃលក្ខណ៍ លោក ព្រហ្ម-ភុម ស្រាវជ្រាវ–ដកស្រង់ (ត-ចប់) . . . ២៣៩

*ផ្នែកអក្សរសាស្ត្រ*

៣– ការយកគ្នាជាប្ដីប្រពន្ធ (វិចារណកថា) លោក ផេង-ទ្រឹវ រៀបរៀង . : . ២៥១
៤– គួរតម្រង់ទិសអក្សរសាស្ត្រឲ្យបំពោលដៅ លោក មាស-យុត្ត រៀបរៀង. . . . ២៦១
៥– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង–ខាត់ រៀបរៀង (ត) . . . . . ២៦៧
៦– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គឹមសៀ រៀបរៀង (ត) . . . ២៧១
៧– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឱ. ពាម ស្រាវជ្រាវ (ត) . . . . . . ២៧៩
៨– ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ២៨៧
៩– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . ២៩១
១០– ឯកសារកម្ពុជសុរិយា លោក ឱ.ពាម ប្រមូលរៀបរៀង (ត) . . . . . . ២៩៩
១១– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . . . ៣០៧
១២– អត្ថបទផ្នែកទំនៀមទម្លាប់ ចូលឆ្នាំថ្មី អ្នកស្រី ពេជ្រ-សល់ រៀបរៀង . . . . . ៣១៥

*ផ្នែកកំណត់និងប្រវត្តិការណ៍*

១៣– សេចក្ដីរាយការណ៍ អំពីសកម្មភាពពុទ្ធសាសនបណ្ឌិត្យ ត្រីមាសទី ៤-១៩៦៦ . . ៣២២
១៤– អនុសិទ្ធិបទមហាសន្និបាតមន្ត្រីសង្ឃទី ២៣ . . . . . . . . . . . ៣៣០

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារៀល ២៣០រ០០ ៗ

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការពាំមក, ឲ្យធ្វើល្អទៅ,
ឲ្យជុំសខាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(គ)

លោក សម-ថាំង ប្រែ - រៀបរៀង

បុ. ព្រះសទ្ធម្មទេសនានោះ នាំពួកបញ្ចវគ្គិយឲ្យបានផលដូចម្ដេចខ្លះ?

វិ. កោណ្ឌញ្ញដែលចាស់ជាងគេ ជាអ្នកដឹងច្បាស់បានលះបង់អស្មិមានះមុនគេ ហើយទទួលគោរពស្ដាប់ព្រះធម៌របស់ព្រះអង្គនោះ បានជាសាវ័កសំរេចព្រះអរហត្តផលក្នុងខណៈនោះ ។ ឯព្រាហ្មណ៍៤រូបទៀតបានយកតំរាប់តាមហើយក៏បានសំរេចអរហត្តផលជាលំដាប់ខាងក្រោយដែរ ។

បុ. ព្រះអង្គទ្រង់ប្រៀនប្រដៅជនណាតទៅទៀត ?

វិ. ទ្រង់ប្រៀនប្រដៅសេដ្ឋីបុត្តឈ្មោះ យស និងបិតាដែលជាមហាសេដ្ឋី ។ លុះបាន ៣ ខែ សាវ័កក៏បានកើនឡើងមានចំនួន ៦០ រូប ។

បុ. ស្ត្រីណាខ្លះ ដែលបានជាសាវិកាមុនគេបង្អស់ ?

វិ. គឺមាតានិងភរិយានៃព្រះយស ។

បុ. ព្រះពុទ្ធជាម្ចាស់ទ្រង់ធ្វើអ្វីតទៅទៀត ?

វិ. ទ្រង់ប្រជុំអស់ពួកសាវ័កព្រះអង្គ ហើយបង្ហាត់បង្រៀនប្រៀនប្រដៅព្រះធម៌ដ៏ជ្រាលជ្រៅ ទើបទ្រង់ចាត់ឲ្យទៅប្រកាសផ្សាយសាសនាគ្រប់ទិសទាំងពួង ។

បុ. អត្ថរស របស់ព្រះពុទ្ធសាសនាដូចម្ដេច ?

វិ. ព្រះពុទ្ធសាសនាជាផ្លូវដឹកនាំសត្វ ឲ្យរួចចេញចាកទុក្ខទាំងពួង ដោយចរិយាការប្រព្រឹត្តិ តាមគន្លងដំណើរ ដែលនឹងអធិប្បាយទៅខាងក្រោយ ។

បុ. គន្លងដំណើរទៅកាន់អរហត្តផលនោះឈ្មោះអ្វី ?

វិ. ឈ្មោះថាផ្លូវដ៏ប្រសើរមាន ៨ ប្រការ ។

បុ. ផ្លូវនោះជាភាសាបាលីហៅថាដូចម្ដេច ?

វិ. អរិយោ អដ្ឋង្គិកោ មគ្គោ ។

បុ. ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅកាន់ទីណាទៀត ?

វិ. ទៅកាន់ព្រៃឧរុវេឡ ។

បុ. មានហេតុកើតដូចម្ដេចនៅទីនោះ ?

វិ. ព្រះអង្គប្រដៅសាស្ដាម្នាក់ ឈ្មោះកស្សប ដែលល្បីល្បាញដោយចំណេះវិជ្ជា ហើយដែលជាគណាចារ្យយ៉ាងធំ ព្រមទាំងពួកជដិល

ដែលជាសិស្សគណ ប្រកាន់ខាងលទ្ធិបូជាយ័ញ ឲ្យបានលុះដោយនូវសំណាញ់ញាណរបស់ព្រះអង្គ ។

ប្ញ. មហាបុរសណាមួយ ដែលបានលុះដោយដំបូន្មាន របស់ព្រះអង្គដែរ ?

វិ. ព្រះបាទពិម្ពិសារ ជាព្រះចៅនៃដែនមគធៈ ។

ប្ញ. សាវ័ករបស់ព្រះអង្គពីររូបណា ដែលបេះដូង ជ្រៅជ្រះជាងសាវ័កទាំងពួង ហើយជាទីគាប់ព្រះហឫទ័យរបស់ព្រះអង្គ មាននាមអ្វីខ្លះ?

វិ. គឺព្រះសារីបុត្ត និង ព្រះមោគ្គល្លាន ដែលពីដើម ជាសិស្សនៃសាស្ដាម្នាក់ឈ្មោះ សញ្ជ័យ ។

ប្ញ. ចុះសាវ័កទាំងពីររូបនេះ បានជាបុគ្គលល្បីល្បាញឆ្នើមដោយសារអ្វី ?

វិ. ព្រះសារីបុត្ត ជាបុគ្គលឆ្នើមខាងបញ្ញា មោគ្គល្លានជាបុគ្គលឆ្នើមខាងឥទ្ធិរិទ្ធិ ។

ប្ញ. ចុះឥទ្ធិពលដ៏ក្រៃលែងនៃសាវ័កទាំងពីររូបនេះគួរឲ្យអស្ចារ្យឬទេ?

វិ. ជាធម្មតារបស់មនុស្សទាំងពួងទេ ឥទ្ធិពលអាចកើតឡើងបាន ដោយការហ្វឹកហ្វឺនហាត់ពត់ចិត្ត ។

ប្ញ. ព្រះបរមគ្រូ ព្រះអង្គបានជ្រាបដំណឹងពីព្រះញាតិវង្សដែរឬ តាំងពីឃ្លាតឆ្ងាយមក ?

វិ. មែនពិត, ប្រាំពីរឆ្នាំក្រោយមក, កាលព្រះអង្គសម្រេច

ព្រះឥរិយាបថ នៅក្នុងក្រុងរាជគ្រឹះ ព្រះបាទសុទ្ធោទនៈ ជាព្រះពុទ្ធបិតា បានបញ្ជូនទូតទៅសូមនិមន្តព្រះអង្គ ឲ្យចូលមកព្រះរាជវាំង ដើម្បីទ្រង់បានឃើញយល់ព្រះភក្ត្រ មុននឹងទ្រង់ទិវង្គត ។

ប្រ. ព្រះអង្គយាងទៅឬទេ ?

វិ. ព្រះអង្គយាងទៅ ។ ព្រះពុទ្ធបិតា ទ្រង់ធ្វើបច្ចុគ្គមនាការទទួល ដោយសេចក្តីសោមនស្សដ៏ក្រៃលែង មួយអន្លើដោយព្រះញាតិ-វង្ស និងពពួករដ្ឋមន្ត្រី ។

ប្រ. ព្រះអង្គព្រមត្រឡប់មកទទួលសោយរាជសម្បត្តិ ដូចដើមឬទេ ?

វិ. ទេ, ទ្រង់បានអធិប្បាយពន្យល់ព្រះវររាជបិតា ដោយព្រះមធុរ-ពាចាថា ព្រះសិទ្ធត្ថរាជកុមារ បានលះបង់ភារៈជាក្សត្រក្នុងកាលមុននោះហើយ ក្នុងពេលនេះ តថាគតឋិតនៅក្នុងលក្ខណៈ ជាព្រះពុទ្ធមួយព្រះអង្គ ហើយមនុស្សសត្វទាំងឡាយ សុទ្ធជាញាតិមិត្ររបស់តថាគតទាំងអស់ឥតមានរើសមុខ ។ ព្រះសទ្ធម្មរបស់តថាគតនេះ អាចញុំាងសត្វទៅឲ្យប្រតិបត្តិតាម ពុំមែនដូចស្តេចផែនដី ដែលគ្រាន់តែគ្រប់គ្រងមនុស្សមួយកុលសម្ពន្ធ ឬមួយប្រជាជាតិប៉ុណ្ណោះទេ ។

ប្រ. ទ្រង់បានយល់ព្រះភក្ត្រព្រះនាងយសោធរា និងព្រះរាហុល-កុមារឬទេ ?

វិ. បាន, ព្រះនាងមានសេចក្តីវិយោគសោកសង្រេងដោយសេចក្តី

ស្នេហាចំពោះព្រះអង្គ ហើយបានទាំងត្រាស់ប្រើព្រះរាហុលកុមារ ឲ្យទៅសូមសម្បត្តិជាកេរ្តិ៍មរតក តំណតអំពីព្រះអង្គទៀតផង ដើម្បីឲ្យសមឋានៈជាព្រះរាជបុត្រនៃព្រះមហាក្សត្រ ។

បុ. ព្រះអង្គបានធ្វើដូចម្តេច ?

វិ. ព្រះអង្គបានប្រោសប្រទាន ព្រះធម៌វិសេសទេសនា បដូចជាឱសថដ៏វិសេស រំងាប់បង់នូវទុក្ខសោក ។ ព្រះពុទ្ធបិតា ព្រះរាជកុមារ ព្រះអគ្គមហេសី ព្រះអានន្ទជាព្រះអនុជ ទេវទត្តជាបងប្អូនជីដូនមួយនិងជាបងថ្លៃរបស់ព្រះអង្គ សឹងបានលុះ ដោយនូវធម្មាភិសម័យ ហើយបានជាពុទ្ធបរិស័ទទាំងអស់ ។ បុគ្គលក្រៅពីនេះ គឺព្រះអនុរុទ្ធដែលជាអ្នកប្រាជ្ញខាងអភិធម្ម និងព្រះឧបាលិ ជាជាងកាត់ព្រះកេសទាំងពីររូបនេះ សឹងមានកិត្តិស័ព្ទល្បីល្បាញទូទៅ ។

បុ. ស្ត្រីណាដែលបានចូលបួសក្នុងពុទ្ធសាសនាមុនគេអស់ ?

វិ. ព្រះនាងបជាបតី ត្រូវជាព្រះមាតុច្ឆា និងជាព្រះមាតាចិញ្ចឹមនៃសិទ្ធត្ថកុមារ, ក្នុងពេលជាមួយគ្នានោះ ព្រះនាងយសោធរា និងស្ត្រីឯទៀត ។ សឹងបានបួសជាភិក្ខុនីទាំងអស់ ។

បុ. ព្រះបាទសុទ្ធោទនៈ កាលបើឃើញព្រះនន្ទ, ទេវទត្ត ជាព្រះភាគិនេយ្យ, ព្រះនាងយសោធរា ជាសុណិសា និងព្រះរាហុលកុមារ ជាព្រះរាជនត្តា ចូលបួសក្នុងព្រះពុទ្ធសាសនាដូច្នោះ តើទ្រង់មានព្រះទ័យវិតក្កដូចម្តេចខ្លះ ?

វិ. ទ្រង់សោកស្ដាយជាទីបំផុត ហើយបានចូលទៅសំពះសុំពរអំពីព្រះបរមគ្រូថា អំណើះតទៅ សុំកុំឲ្យបំបួសកុលបុត្រ ដែលមាតាបិតាឬអាណាព្យាបាល ពុំបានអនុញ្ញាតឲ្យបួសនោះសោះឡើយ ។

បុ. ទេវទត្តបានជាអ្វី ?

វិ. បានជាបុគ្គលប្រកបដោយប្រាជ្ញាចេះចាំធម៌វិន័យ ដោយឆាប់រហ័ស ក៏ប៉ុន្តែភិក្ខុនេះ មានសេចក្ដីច្រណែនឈ្នានីសពន់ពេក ក៏ត្រឡប់ជាចង់អាឃាតព្យាបាទនឹងព្រះអង្គវិញ ។ ភិក្ខុនេះ បានទាំងញុះញង់ព្រះបាទអជាតសត្រូវ ជាព្រះរាជបុត្រព្រះបាទពិម្ពិសារ ឲ្យធ្វើបិតុឃាត ហើយឲ្យចូលធ្វើជាសិស្សខ្លួនទៀតផង ។

បុ. ចុះទេវទត្តព្យាបាទព្រះអង្គបានសម្រេចឬទេ ?

វិ. ទេ, អំពើទុច្ចរិតដែលភិក្ខុនេះបានប្រព្រឹត្ត សឹងវិលត្រឡប់មកដល់ខ្លួនវិញ ទាល់តែដល់ទីមរណកាល ដោយទុក្ខវេទនាជាទីបំផុត ។

បុ. ព្រះបរមសាស្ដា ព្រះអង្គសំដែងធម៌ទេសនា ប្រោសសត្វបានប៉ុន្មានឆ្នាំ ?

វិ. បាន ៤៥ ឆ្នាំ, ក្នុងឱកាសនោះ ព្រះអង្គទ្រង់ប្រោសប្រដៅវេនេយ្យសត្វជាច្រើនលើកច្រើនគ្រា តែងតែធ្វើពុទ្ធដំណើរប្រោសទេសនាក្នុងរវាងប្រាំបីខែ នៅរដូវប្រាំង មួយអន្លើដោយភិក្ខុសង្ឃទាំងពួងជាពុទ្ធ-បរិវារ ឯរដូវវស្សាទ្រង់គង់នៅក្នុងបណ្ណសាលា និងក្នុងវិហារដែលពពួក

កថា និងសេដ្ឋីសាងថ្វាយដោយសេចក្ដីជ្រះថ្លា ។

បុ. វិហារដែលមាននាមល្បីល្បាញជាងគេ ឈ្មោះអ្វីខ្លះ ?

វិ. ឈ្មោះជេតវនារាម, វេឡុវនារាម, បុព្វារាម, និគ្រោធារាម និងឃោសិតារាម ។

បុ. ព្រះអង្គប្រោសសត្វនូវបុគ្គលណាខ្លះ ?

វិ. បុគ្គលគ្រប់តំណែង គ្រប់ជាតិនិងគ្រប់វណ្ណៈគឺ ក្សត្រិយ៍ និងកម្មករ, អ្នកមានធនធាន, អ្នកក្រីក្រលំបាក, អ្នកមានឫទ្ធិអំណាច និងអ្នកទាបថោក, អ្នកប្រាជ្ញចេះដឹង, អ្នកល្ងង់ខ្លៅ ។ ព្រះធម៌របស់ព្រះអង្គ សឹងជាទីពេញចិត្ត គួរដល់បុគ្គលគ្រប់ឋានៈទាំងអស់ ។

បុ. ចូរអ្នកអធិប្បាយអំពីដំណើរ ដែលព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅចូលបរិនិព្វានមកមើល ?

វិ. នៅថ្ងៃពេញបូណ៌មីខែវិសាខ ក្រោយបឋមពោធិកាលចំនួន ៤៥ វស្សា ព្រះបរមគ្រូទ្រង់ជ្រាបច្បាស់ថា ទៀបនឹងចូលកាន់បរិនិព្វានហើយ ព្រះអង្គធ្វើពុទ្ធដំណើរទៅកាន់កុសិនគរ ស្ថិតនៅចម្ងាយប្រមាណ ១២០ ម៉ែលពីនគរពារាណសី នៅក្នុងព្រៃសាលវ័នខែឧព្វត្តមល្លក្សត្រដ៏ជាឧបវត្តនៈនៃក្រុងកុសិនារា ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ។ ព្រះអង្គឲ្យចាត់ចែងរៀបបញ្ញាសនាក្រឡាព្រះបន្ទំ ហើយទ្រង់ផ្ទំផ្ដោះព្រះកេសាទៅឧត្តរទិសតាមបវេណី ។ ព្រះអង្គសំដែងព្រះសទ្ធម្មទេសនាប្រោសវេនេយ្យសត្វជា

ចុងក្រោយបំផុត រួចហើយ ទ្រង់ក៏ផ្តែផ្តាំលាពួកពុទ្ធបរិស័ទ បរិនិព្វាន ក្នុងទីនោះ ។

បុ. ពេលក្រោយបង្អស់ ព្រះអង្គបានប្រោសបុគ្គលណាទៀតទេ ?

វិ. ទ្រង់បានប្រោសបណ្ឌិតព្រាហ្មណ៍ម្នាក់ ឈ្មោះសុភទ្ទបរិព្វាជក និងមល្លក្សត្រទាំងឡាយ ព្រមទាំងពួកបរិវារនៃស្តេចទាំងនេះ ។

បុ. លុះដល់ពេលភ្លឺស្វាង ព្រះអង្គធ្វើអ្វីខ្លះ ?

វិ. ព្រះអង្គដំកល់ព្រះហឫទ័យជាសម្មាធិញាណ, ញ៉ាំងឈានឲ្យកើតឡើងហើយ, ហើយក៏រលត់ខន្ធចូលកាន់ព្រះមហានិព្វាន ។

បុ. ព្រះអង្គទ្រង់ប្រទានពុទ្ធឱវាទ ចុងក្រោយបំផុត ដូចម្តេចខ្លះ ដល់សាវ័កទាំងឡាយ ?

វិ. ថា ម្នាលភិក្ខុទាំងឡាយ ! ចូរអ្នករាល់គ្នា ចាំឲ្យជាក់ប្រាកដថា សង្ខារទាំងឡាយមានកិរិយាអស់ទៅ និងសូន្យទៅជាធម្មតា នៅសល់តែសេចក្តីពិត ទើបឋិតថេរតាំងនៅជាដរាបទៅបាន ចូរអ្នកទាំងឡាយខំប្រឹងញ៉ាំងប្រយោជន៍របស់ខ្លួនឲ្យសម្រេច ដោយសេចក្តីមិនប្រមាទ ។

បុ. មានភស្តុតាងអ្វីខ្លះ ដែលបញ្ជាក់ឲ្យឃើញច្បាស់ថា ព្រះសិទ្ធត្ថកុមារ បានត្រាស់ជាព្រះពុទ្ធមែន ?

វិ. ការតាំងនៅនៃអាយុសង្ខាររបស់ព្រះអង្គ ជាគ្រឿងបញ្ជាក់ឲ្យឃើញដោយជាក់ស្តែង ដូចជាមនុស្សក្នុងលោកដទៃ ។

ប្រ. ចូរអ្នកអធិប្បាយរៀបរាប់ អំពីកស្តុតាងទាំងនោះមកមើល ?

ឆ្លើ. ១ កស្តុតាងជាសាក្សី អ្នកដែលបានចូលជិតស្និទ្ធស្នាលនឹងព្រះអង្គ ។

២– ការរកឃើញសំណង់ទីដ្ឋាន និងបុរាណវត្ថុបាក់បែក ដែលមានពណ៌នាអំពីរឿងព្រះអង្គ ។

៣ - សិលាចារឹកលើផែនថ្ម, សសរថ្ម, ព្រះស្តូបដែលស្តេចគ្រប់គ្រងផែនដីបានកសាងទុកជាអនុស្សាវរីយ៍ ចំពោះវិញ្ញាណក្ខន្ធព្រះអង្គ ជាតំណាក្រោយដែលព្រះអង្គចូលបរិនិព្វានទៅ ដើម្បីបញ្ជាក់ក្នុងរឿងក៏ផ្សេង ៗ ។

៤– មានព្រះភិក្ខុសង្ឃជាតំណៗគ្មានចន្លោះ អាចឲ្យដឹងពីប្រវត្តិរបស់ព្រះអង្គជាប់តមក គ្រប់ ៗ ជំនាន់ ។

៥– កាលពីក្នុងឆ្នាំ ដែលព្រះអង្គចូលកាន់បរិនិព្វាន និងនៅខណៈផ្សេង ៗ ជាលំដាប់មក ក្រុមជំនុំភិក្ខុសង្ឃសឹងបានប្រជុំ ដើម្បីផ្ទៀងផ្ទាត់ធម៌វិន័យរបស់ព្រះអង្គ និងប្រកាសផ្សាយធម៌វិន័យនេះ ដោយត្រឹមត្រូវជាតំណពីគ្រូអាចារ្យមកសិស្ស រហូតដល់យើងសព្វថ្ងៃនេះ ។

៦– ក្រោយដែលបានធ្វើពិធីថ្វាយព្រះភ្លើង រំលាយព្រះបរមសពរួចហើយ ស្តេចទាំង ៨ នគរសឹងបានចែកចាយព្រះសារីរិកធាតុ ហើយបានកសាងព្រះស្តូបដាក់តម្កល់ជាទីគោរពគ្រប់កន្លែង ។ ព្រះអដ្ឋិធាតុដែលបានទៅព្រះបាទអជាតសត្រូវ គេដាក់តម្កល់ក្នុងស្តូប នៅក្រុងរាជគ្រឹះ ហើយ –

មិនទាន់ទាំងបាន ២០០ ឆ្នាំផង ព្រះបាទធម្មាសោក ទ្រង់បាននិមន្ត យកពិតនៃរឿងនេះ ទៅចែកចាយគ្រប់ទីដំបន់ ក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គ ។ ព្រះមហាកជាធិកជអង្គនេះ បានរកឃើញទំនងគ្រប់យ៉ាង ជាទីសំអាងថាជាព្រះអដ្ឋិធាតុ របស់ព្រះសម្មាសម្ពុទ្ធពិតប្រាកដ ព្រោះព្រះអដ្ឋិធាតុទាំងនេះ សឹងជាទីថែរក្សានិងគោរពបូជារបស់ស្ដេចបត្តៈ ។

៧– មានសាវ័ករបស់ព្រះអង្គជាច្រើន ដែលបានសម្រេចអរហត្ត ហើយនៅមានអាយុសង្ខាររស់នៅអស់កាលយូរ ។ ដូច្នេះ គ្មានហេតុអ្វីនឹងជាវិនាស មិនឲ្យព្រះអរហន្តពីរ បី អង្គ គង់នៅជាតំណគ្នាមក តាំងពីថ្ងៃដែលព្រះបរមគ្រូចូលកាន់បរិនិព្វាន មកទល់នឹងរជ្ជកាល នៃព្រះបាទអសោកនោះឡើយ ដើម្បីឲ្យព្រះមហាកជាធិកជអង្គនេះ បានជួបប្រទះនឹងអ្នកដែលរស់នៅជំនាន់ព្រះសម្មាសម្ពុទ្ធនេះ ហើយនឹងបានដឹងហេតុច្បាស់ប្រាកដ ក្នុងរឿងនៃព្រះអង្គផង[១] ។

---

១– មានសិស្សរបស់ព្រះមហាអានន្ទ ២ រូប ដែលនៅមានព្រះជន្មស្ថិតនៅអស់រយនៃឆ្នាំ ។ ជំនាន់ព្រះបាទអសោក បានចូលប្រជុំ នៅពេលលើកទុតិយសង្គាយនា, នៅក្នុងការលើកសង្គាយនា ដែលព្រះបាទអសោកទ្រង់ចាត់ចែង ក៏មានសិស្សរបស់លោក ចូលរួមផងដែរ ។

(នៅមានត)

# ព្រះត្រៃលក្ខណ៍

(ត-ចប់)

ឲ្យគេកសាង ចិត្តនឹកក្តីអរ នឹកព្រះធម៌ថ្លៃ
ចំរៀនរក្សា ភាវនាសព្វថ្ងៃ នឹកតែព្រះត្រៃ-
សីលសរណគមន៍ ៗ

បើបានធម៌ហើយ កុំគិតខ្លាចឡើយ សម្បត្តិឥន្ទ្រព្រហ្ម
សម្បត្តិមហាចក្រ សិទ្ធិស័ក្តិឧត្តម បានហើយទំគំ
សាងសំទៀតទៅ ៗ

យកសង្ឃជាញាតិ ចិត្តកុំឲ្យឃ្លាត ឲ្យចិត្តនឹងនៅ
រក្សាព្រះធម៌ បិដកក្នុងក្រៅ ដែលលោកប្រដៅ
ដោយពុទ្ធវេណី ៗ

ព្រះធម៌សោភ័ណ ប្រាំបីម៉ឺនបួនពាន់ ខន្ធព្រះគម្ពីរ
ព្រះធម៌ជាយាន ជាស្ពានសោភី ចម្លងទៅទី
មឿងកែវថ្លៃថ្លា ៗ

ព្រះធម៌សេដ្ឋ ប្រោសជាកម្លាំង ដាស់តឿនប្រាជ្ញា
បច្ចុប្បន្ននេះបាន ទៅឋានសួគ៌ា ទាន់ព្រះសិការ្យ
ក្នុងកាលនេះនៃ ៗ

យមបាលទាំងបួន ដែលនៅក្នុងខ្លួន ប្រចាំសព្វថ្ងៃ

ចាប់ចិត្តពុំបាន សឹងក្បួនអរក្រៃ អរឲ្យពរថ្លៃ
នៃអ្នកនោះណា ។

កាលសត្វអស់កម្ម ព្រះយមរាជផ្តាំ ទ្រង់ព្រះមេត្តា
អស់ចិត្តកុមារី ក្សត្រីក្សត្រា បានរួចទុក្ខា
នរកទាំងឡាយ ។

ឲ្យមានចិត្តក្បួន រករៀនឲ្យបាន បិដកត្រៃកាយ
ទើបអស់បាបផង ចំណងសោយ រូបរួចសប្បាយ
ពីនរកនោះនៃ ។

ចិត្តកុមារអើ មូលមកស្តាប់ស្រែ ព្រះបន្ទូលថ្លៃ
ព្រះយមរាជា ក្រាបលាមកខ្ញុំ ឡើងមកកើតវៃ
ទាន់ព្រះសាសនា ។

ឲ្យខំរៀនចិត្ត គោរពប្រតិបត្តិ សាងសីលភាវនា
កុំឲ្យមានហ្មង ផ្តាំផ្តងឡើយណា ចិត្តមានមេត្តា
ធ្វើបុណ្យឲ្យទាន ។

ព្រះយមរាជផ្តាំ ចិត្តចេះចងចាំ យកមកខ្លួនាន
កុំឲ្យភ្លេចចិត្ត បង់បាត់វិញ្ញាណ ដល់ស្លាប់បានឋាន
សម្បត្តិសួគ៌ា ។

អស់ហើយនូវចិត្ត  បុណ្យព្រេងមកសង្កត់  ឲ្យចិត្តជ្រះថ្លា
ពុំស្តាយជីវិត  ក្រម្តេចក្តីណា  លែងតែអាត្មា
បានព្រះធម៌ថ្លៃ ៗ

បើមានជីវិត  រស់ឆ្ងាយមែនពិត  រាប់កសន្ធើយ
តែងកើតរវល់  អំពល់ពេកក្រៃ  ឈ្មោះខ្លួននៅដៃ
ព្រះកាលកាឡា ៗ

ថ្កុំថ្កើងថ្កល់ក្រៃ  ហែពលសេនីយ៍  រាប់សែនសហស្សា
បញ្ជីស្លាប់មក  កត់យករូបា  ឥតអ្នកឯណា
ប្រកែកនៅបាន ៗ

ទោះបីមហាចក្រ  ឥន្ទ្រព្រហ្មយក្ស  ពិភពនាគស្ថាន
ខ្ទីរបក្ខនា  ទុកយូរនៅប្រាណ  រាប់ឆ្នាំកោដិលាន
មុខសែនអសន្ធើយ ៗ

សឹងមានអាជ្ញា  ព្រះកាលកាឡា  មកគៀនសព្វថ្ងៃ
ពុំដឹងកំណត់  ប្រាកដនឹងក្ស័យ  គ្រប់រូបទីទៃ
សឹងស្លាប់ដូចគ្នា ៗ

រូបក្ខន្ធខ្លួន  មានទ្វារប្រាំបួន  រាំយោរក្សា
បបរីអាពោ  តេជោចត្តា  ជួយរួមរក្សា
រូបរស់សព្វថ្ងៃ ៗ

ចិត្តបញ្ចោលបង់ រូបខ្លួនសូន្យសុង ដូចៗសាវិស័យ
អាណិតរូបនៅ ចិត្តទៅទីវៃ យមបាលក្រោធក្រៃ
ជាខែតិរច្ឆាន ៗ

មុខស្រពកមុខខ្នែ ចិត្តមិនប៉ៅខ្សែ ចិត្តខ្ពសាមាឡ
ទីរូបខ្លួន កត់កាន់ជាប្រាណ អញ្ចការពុំបាន
រាប់ជាតិអសង្ខេយ្យ ៗ

មិនចិត្តរើរូស អញឲ្យធ្វើទោស រូបមិនសព្វថ្ងៃ
ចងបញ្ចាសាខា រូបាធ្ងន់ក្រៃ ចងអស់សារៃស
ទាំងសាមសិបសង ៗ

មាត់មិនថ្វខ្ទាំង ហើយអស់កម្លាំង អត់អាហារផង
ធាតុភ្លើងក្ដៅលន់ ពោកពន់កន្ទង យមបាលព្រួតបង
ចិត្តកុមាំ ៗ

អជ្ឈត្តិកមាន ចិត្តកុមារមាន ចិត្តស្មោះខ្លះខ្ទាំង
មួយពាន់បានមួយ ជាត្រួយអរហាំ ប្រោសសត្វខ្វាំង
មួយសែនចក្រវាឡ ៗ

ប្រាជ្ញប្រះគិតយល់ ពុំឲ្យអំពល់ កុងវិជ្ជសង្ឃារ
ឧបខ្ញាចបារមី វិឌ្ឍបេស្ដា ព្រះកាលគៀនពារ
រូបខ្លួនសព្វថ្ងៃ ៗ

ព្រះចូលនិព្វាន សកកជយូរបាន សេព្វមួយរយម្ភៃ-
ឆ្នាំទើបកើតក្សត្រ ចុលចក្រមកនៃ ព្រះនាមក្សត្រថ្វៃ
ធម្មាសោកកជ៉ា ។

ព្រះទ័យសង្វាត ចង់លើកព្រះធាតុ ប្រើអរហន្តា
និងព្រះមហិន្ទត្ថេរ ទៅប្រែសាស្ត្រា ឯកោះលង្កា
ប្រាំរយព្រះអង្គ ។

សឹងហៀរហោះបាន ដល់លង្កាបាន រំពេចពុំលង់
ប្រែត្រៃបិដក ទំនុកបម្រុង ធម៌ព្រះពុទ្ធអង្គ
ប្រាំបីម៉ឺនបួនពាន់ ។

ប្រាំរយឆ្នាំបាយ កើតក្សត្រពណ្ណរាយ ក្រុងមិលិន្ទសោភ័ណ
មានប្រាជ្ញាច្បាស់ រហ័សស្រួន ដូចកលជវ័ន
សុបណ្ណកជរ៉ ។

ព្រះអរហន្តា មិនសែនសហស្ស អ្នកប្រាជ្ញផងនៃ
សឹងតញ្ញប្រាជ្ញា រកោទទៃ រត់ទៅពួនព្រៃ
ឧបគ្នាបប្រាជ្ញា ។

សម្តេចកោសិយ ជ្រាបសព្វសេចក្តី ពីគុបិតា
អញ្ជើញទេវបុត្រ ឲ្យចុះមកជា នាគសេនប្រាជ្ញា
ផ្ចាញ់ក្រុងមិលិន្ទ ។

ថ្កើនព្រះសាសនា    អស់អរហន្តា    វិលវិលមកថ្កើង
មនុស្សផងត្រេកអរ    សាវគ្រប់ប្រាណ    អរហន្តហោះញាន
ប្រោសសត្វសព្វថ្ងៃ    ៗ

សកពងយូរឆ្ងាយ    ប្រាំបីរយឆ្នាយ    កើតមហាក្សត្រថ្ងៃ
អភ័យទសគ្រាមណី    រិទ្ធិជាញជ័យ    ផ្ចាញ់ទមិឡអឡិតរិយ៍
អន្តរធានបង់    ៗ

មួយពាន់ព្រះវស្សា    សូន្យអស់អត្តព    សូន្យសត្តពោជ្ឈង្គ
ប្រាំបីមុនបួនពាន់    គម្ពីរសូន្យសុង    ក្តៅផល់ទៅអង្គ
សម្តេចឥន្ទ្រា    ៗ

អញ្ជើញទេវបុត្រ    ឲ្យអ្នកច្បុត    ចុះចាកសួគ៌ា
ប្រែព្រះធម៌ពី    សីហឡលង្កា    ផ្សិតជម្ពូទ្វីបា
សូន្យព្រះធម៌ថ្ងៃ    ៗ

ឃោសទេវបុត្រស្តាប់    កោសិយប្រាយប្រាប់    ជ្រាបស្រេចហើយនៃ
លាទេពអប្សរ    បវរស្រីថ្លៃ    ចុះចាកមកពុ
ចាប់បដិសន្ធិ    ៗ

ត្រកូលព្រាហ្មណ៍ថ្លៃ    គ្រប់ទសមាសនៃ    ចេញចាកអំពី
ទេវមាតា    ជ្រះថ្លាសោភី    ព្រះវរជននី
ព្រះជនកអាក្រ    ៗ

ធំទៀនបួសជា សាមណេរហើយណា ជាភិក្ខុប្រពៃ
រៀនចប់គម្ពីរ វិន័យធម៌ថ្លៃ រៀនចប់ព្រះត្រៃ-
បិដកជ្រាលជ្រៅ ។

ព្រះអរហន្ត ជាគ្រូឧបជ្ឈាយ៍ អ្នកតែងប្រដៅ
ព្រះពុទ្ធឃោសា ប្រាជ្ញាជ្រាលជ្រៅ គ្រូអស់ប្រដៅ
គ្រូសៀមព្រងើយ ។

ព្រះពុទ្ធឃោសា ទឹកក្នុងចិន្តា ថាគ្រូអញអើយ
អស់ធម៌ប៉ុណ្ណោះ ឬចេះនៅឡើយ ទើបលោកតទ្តើយ
ពិតពុំបារបែង ។

អរហន្តជ្រាបថា ព្រះពុទ្ធឃោសា ជៀលគ្រូខ្លួនឯង
ត្រូវឲ្យទណ្ឌកម្ម បង់ចាំពុំលែង អារុំសោព្រះស្តែង
ទៅកោះលង្កា ។

រកប្រែព្រះត្រៃ- បិដកធម៌ថ្លៃ ជាមគធភាសា
ទើបអស់មន្ទិល សរិលអាត្មា ដែលជៀលឧបជ្ឈាយ៍
ជាគ្រូនោះនៃ ។

ព្រះពុទ្ធឃោសា ទូលព្រះពុទ្ធដីកា កុំព្រួយព្រះទ័យ
ទទួលទៅប្រែ បន្ទូលធម៌ថ្លៃ ក្បិតខុសវិន័យ
ខ្ញុំសូមទោសា ។

អ្នកលាចុះទៅ គង់លើសំពៅ អស់ឈ្មួញគេត្រា
បើកក្តោងកណ្តាល ប្រវាលជលសា ក្តៅដល់អាសនា
សម្តេចសហស្សន័យន៍ ។

មកប្រាណសំពៅ ឲ្យលូនលឿនទៅ កណ្តាលជលស័យ
សមុទ្រធំធេង បែកផ្សែងពេកក្រៃ មើលមិនយល់ព្រៃ
ប្រាំពីរទិវា ។

ពុទ្ធទត្តគេ វិលមកពីប្រែ ធម៌ពីលង្កា
ដល់កណ្តាលសមុទ្រ ជួបពុទ្ធឃោសា ប្រគេនដៃកបារ
ដែលព្រះឥន្ទ្រថ្វាយ ។

ព្រះពុទ្ធឃោសា ដល់កោះលង្កា មើលយល់បន្ទាយ
សំពៅសហស្សា គេត្រាវៀនកាយ កំពែងវែងឆ្ងាយ
ថ្វាក់ថ្វល់ខ្វាត់ខ្វែង ។

ពស្ត្រទៅគាប់គាន់ ប្រាសាទកំពង់វ័ណ្ណ មុខដាច់ត្រឡែងកែង
មានកំពុទ្ធបាទ ត្រដាចបែកផ្សែង ត្រដួចលើសលែង
កំផែងទាំងឡាយ ។

ព្រះចន្ទមកែវគូរ ភ្លឺផ្លេកសន្ធៅ គ្រប់ពណ៌កាយ
ឆព្វណ្ណរង្សី រស្មីព្រោងព្រាយ មនុស្សផងក្រាបថ្វាយ
បង្គំសព្វថ្ងៃ ។

ព្រះពុទ្ធឃោសា　គង់នៅលង្កា　ចារប្រែវចប៍
ចប់អស់វិន័យ　គម្ពីរធម៌ថ្លៃ　ចប់បិដកត្រៃ
ប្រាំបីម៉ឺនបួនពាន់ ៗ

រួចទើបទេសនា　ប្រោសស្តេចលង្កា　មនុស្សម្រាមហាជន
មីរមកជជោស　ពេញពាស ពកពន់　ទេវតាខ្ទាប់ខ្ទាន់
ស្តាប់ព្រះធម៌ថ្លៃ ៗ

បូជាមាសប្រាក់　កែវកង់កេទ:　សំពត់អាវស្បៃ
អស់អ្នកកេត្រា　ចែកគ្នាទីទៃ　អាឲ្យពរជ័យ
ព្រះពុទ្ធឃោសា ៗ

លាចុះសំពៅ　បើកក្តោងលឿនទៅ　ទើបអស់ទេវតា
ជួយជូនមកដល់　មណ្ឌលនគរ　ថ្វាយគ្រូបជ្ឈាយ៍
គង់នៅសុខសាន្ត ៗ

ដល់ព្រះសាសនា　ពីរពាន់ព្រះវស្សា　ប្រាំយេឆ្នាំមាន
អ្នកបុណ្យមកលើក　សាសនាថ្កើងថ្កាន　អស្ចារ្យនោះមាន
ឆ្នាំកុរឯកស័ក ៗ

សត្វសត្វសញ្ញី　គោលាគោលី(១)　ឥតទីសំណាក់
មមីនៅព្រៃ　ក្បីណាក្បយឥតអាក់　ទទូងរកអ្នក
បុណ្យបារមី ៗ

---

១. គោលាហលី?

គប់បានពីរពាន់ បីរយសប្តប័ញ្ច ឆ្នាំរោងចត្វា
ស័កខានពីរពាន់ ប្រាំមួយរយព្រះវស្សា ម្ភៃយូរយារ
ឯមុខនៅឡើយ ។

ហៃអស់អ្នកផង ចិត្តបេះចាំចង កុំធ្វើព្រងើយ
រំពឹងសកកាជ ខ្លាចកុំភោះភើយ កុំឯកស័កហើយ
កើតអស្ចារ្យក្រៃ ។

១ កេចជួតរប ចិត្តគិតព្រឺព្រួច កុំឯកស័កថ្ងៃ
ឆ្នាំចវិលមក រកគ្នាទីទៃ មនុស្សផងក្រាស់ក្រៃ
វិន្ទាមហាក្សត្រ ។

ពីរពាន់ប្រាំមួយរយ មនុស្សផងកុំឆ្ងាយ ឲ្យគិតប្រយ័ត្ន
រំពឹងធម៌ថ្ងៃ ប្រពៃបរមត្ថ ព្រះធមិសណ្ឋិត
ផ្លូវព្រះនិព្វាន ។

ឯអស់អាជ្ញា ព្រះកាលកាឡា សល់សែនកោដិលាន
តែងមកសព្វឆ្នាំ ប្រចាំគ្រប់ប្រាណ ដល់ខ្លួនពុំខាន
មហាជនគ្រប់គ្នា ។

ឥឡូវនេះជួន ប្រយ័ត្នគ្រប់ខ្លួន ឆ្នាំរោងចត្វា
ស័កវៀងទៅរក ឆ្នាំកករកា ប-កុំរើបជា
បរិបូណ៌បុណ្យបាន ។

ហៃសាធុជនផង ចូរស្តាប់គ្រាប់គ្រង ទីទៃគ្រប់ប្រាណ
រឿងពុទ្ធសករាជ អាចជាប្រធាន ចាំរៀនឲ្យបាន
ដាក់ប្រាណគ្រប់គ្នា ។

ឲ្យគិតរំពឹង ហើយឲ្យជញ្ជឹង សព្វទិនទិវា
ថាខ្លួនអញអើយ ព្រះកាលកាឡ តៀនសព្វវេលា
ទាំងយប់ទាំងថ្ងៃ ។

កុំឲ្យលោភោ ទោសោមោហោ ចិត្តកាចចង្រៃ
កុំលួចភរិយា កូនគេសព្វថ្ងៃ ដោយសកាដថ្ងៃ
កុំភ័យឡើយហោង ។

លុះដល់កំណត់ នឹងបានសម្បត្តិ មាសប្រាក់កែវកង
សម្បូណ៌សមបុណ្យ លើសលន់កន្ទង ត្បូងសូរ្យកាន្តផង
បទុមពគរ័តន៍ ។

សំពត់គោសេយ្យ ស្រូវគោជ្យសាលី ដុះដល់កំណត់
ទិសទាំងប្រាំបី បារមីព្រះពុទ្ធ ដោយបុណ្យផ្គង់ផ្គត់
មកលើកព្រះសាសនា ។

ព្រះពុទ្ធមានបុណ្យ ព្រះតេជព្រះគុណ ជាម្ចាស់សិរិសោ
ព្រះអង្គតែងប្រោស ទាំងសព្វសួគ៌ា សោឡសព្រហ្ម
ជម្ពូទ្វីបនៃ ។

ព្រះអគ្គីទិត្យនៅ　　រូបល្អឥតសៅ　　ចាំងប្រុសចាំងស្រី
ដំណើរញ៉ែងញ៉ង　　ម៉ដ្ឋហ្មងប្រិមប្រិយ　　រូបហាក់ដូចស្រី
ស្លូតបាទពណ្ណកាយ ។

ព្រះអគ្គីអម្ចាស់　　មានបារមីណាស់　　ស្មើធានះយ
ដោយសព្វព្រឹក្សា　　លតាវល្លិ៍យ　　សត្វផងសម្លាយ
សប្បាយសាន្តសុខ ។

ដោយគេជញ្ជាណញ្ញេយ្យ ព្រះអគ្គីម្ចាស់ថ្លៃ　　និរភ័យនិរទុក្ខ
បច្ចុប្បន្ននេះនៃ　　ប្រពៃសាន្តសុខ　　និញ្ញានទំនុក
សូរេចម្ល៉េះហោង ។

## ព្រូប-ភ្ញុម

ស្រាវជ្រាវ-ចម្លងដកស្រង់ ពីសាស្ត្រាស្លឹករឹត នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ដោយបានពិនិត្យផ្ទៀងផ្ទាត់សម្រួល ជាមួយក្បួនស្លឹករឹតដទៃទៀត មានក្បួនច្បាប់របស់ឈ្មោះ ទៀង-វ៉ែន (ស.) នៅឃុំពាម ស្រុកកំពង់ត្រឡាច កំពង់ឆ្នាំង ជាដើម ។

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ព.ប.

# ការយកគ្នាជាប្តីប្រពន្ធ

(វិចារណកថា)

ការយកគ្នាជាប្តីប្រពន្ធ ជាបញ្ហាមួយដ៏ស្មុគ្រស្មាញ ដែលគួរតែលើកយកមកពិចារណាដោះស្រាយដែរ ព្រោះដំណើរជីវភាពរបស់គ្រួសារ ដែលនឹងប្រព្រឹត្តទៅសុខស្រួល ឬមិនសុខស្រួលទេនោះ ស្រេចនៅលើប្តីប្រពន្ធជាធំបង្អស់ ។ តាមការសង្កេតក្នុងបច្ចុប្បន្ន ឃើញថាមានការប្រឆាំងគ្នា រវាងអ្នកប្រកាន់ទំនៀមទម្លាប់ និង អ្នកសម័យនិយម ។

តាំងពីបុរាណកាលមក ខ្មែរប្រកាន់យកទម្លាប់ថា ការទុកដាក់កូនចៅឲ្យមានគូស្រករ តែងសម្រេចទៅលើអ្នកអាណាព្យាបាល មានឪពុកម្តាយជាដើម បើកូនឬចៅណាស្រឡាញ់គ្នាជាប្តីប្រពន្ធដោយចិត្តឯង គឺស្រឡាញ់គ្នាដោយចិត្តនឹងចិត្ត ឥតបានឲ្យដំណឹងដល់ឪពុកម្តាយជាមុន , គេនិយមទុកថាកូនចៅនោះ មិនគោរពប្រពៃណី មិនគោរពមាតាបិតា

ទុកថាជាអ្នកធ្វើឲ្យកិត្តិយស និងកេរ្តិ៍ឈ្មោះវង្សត្រកូលអាប់ឱន ឈ្មោះថា ជាអ្នកធ្វើឲ្យរស្មីគ្រួសារស្រអាប់ ព្រោះបើដំណើរដ៏ភាពគូស្រករបែបនោះមាន សភាពយ៉ាងណាក៏ដោយចុះ សូមឲ្យតែគោរពទំនៀមទម្លាប់ គឺថាលុះត្រា តែឪពុកម្តាយទុកដាក់ឲ្យ ទើបបានត្រឹមត្រូវ ទើបបានប្រសើរ ទើបបាន ពេញកិត្តិយស ទើបឈ្មោះថាការយកគ្នាជាប្តីប្រពន្ធពេញលក្ខណៈច្បាប់ សម្រាប់ស្រុកភូមិ ។

ខាងក្រោយដែលទំនៀមទម្លាប់នៃបស្ចិមទិសបានចូលមក ទំនៀម ទម្លាប់នេះ ក៏បានដើរពតត្បាតបន្តិចម្តង ៗ លើទំនៀមទម្លាប់ជាតិ ៗ អំពីរឿងយកគ្នាជាប្តីប្រពន្ធ, ទម្លាប់នៃបស្ចិមទិស មានសភាពផ្ទុយគ្នា ស្រឡះពីទម្លាប់ជាតិខ្មែរ ។ បស្ចិមទិស និយមបណ្តោយឲ្យកូនប្រុសស្រី ជ្រើសរើសគូស្រករដោយខ្លួនឯង គឺថាឲ្យកូនប្រុសស្រីស្គាល់ចិត្តគ្នាទៅវិញ ទៅមក ឲ្យបណ្តើរគ្នាលេង ដើម្បីស្គាល់ចិត្តគ្នា បើពេញចិត្ត បើស្រុះ ស្រួលគ្នាហើយ ទើបនាំដំណឹងនោះទៅជំរាបឪពុកម្តាយ ។ ក៏ចាត់ធ្វើ ពិធីអាពាហ៍ពិពាហ៍ឲ្យទៅ ។

ឯទំនៀមទម្លាប់នៃបស្ចិមទិសនេះ ឃើញថាគាប់ប្រសើរណាស់ដែរ ប្រសិនបើសាមីជន អាចនិយមប្រកាន់ឲ្យត្រឹមត្រូវរហូតបាន, តែបើតាម ការសង្កេត ឃើញថាមួយដំបរនិងបួនទេ ។ ហេតុអ្វីបានជាថាដូច្នេះ ? រឿងនេះ មិនខុសគ្នាពីដំណើរកេរហារ ឲ្យក្មេងលេខអគ្គៈមើលផ្គាក់សី

របស់កូនប្រុសស្រី មុននឹងយកគ្នាជាប្តីប្រពន្ធនោះឡើយ ៗ គេធ្វើដូច្នេះដើម្បីអ្វី ? ដើម្បីឲ្យកូនប្រុសស្រី បានទទួលសុភមង្គល ខាងក្រោយអាពាហ៍ពិពាហ៍, តែបំណង់នេះ តើបានសមប្រកប ចំពោះអ្នកដែលគេហោរឲ្យគន់គូគ្រប់ ៗ គ្នាឬទេ ? ចំពោះបញ្ហានេះ, មិត្តអ្នកអានទាំងឡាយមានការពិសោធន៍ចំពោះខ្លួនស្រាប់ហើយ ៗ តាមការពិសោធន៍ ដែលខ្ញុំបានជួបប្រទះ គឺដូច្នេះ : ខ្មែរណាមិនបានគេហោរគន់គូឲ្យកូនប្រុសស្រី មុននឹងយកគ្នាជាប្តីប្រពន្ធ ? បើហោរទាយថាមិនល្អ ត្រូវតែផ្អាក បើហោរទាយថាល្អ ត្រូវតែផ្សំផ្គុំឲ្យបានគ្នាជាប្តីប្រពន្ធ ៗ តើសុភមង្គលត្រូវតែបានគ្រប់គ្នា តាមដូចទំនាយហោរ ឬយ៉ាងណា ? – ឆ្លើយថា: មានបានដូចទំនាយក៏មាន មានមិនបានដូចទំនាយក៏មាន ៗ

ឯការយកគ្នាជាប្តីប្រពន្ធ ក៏មានសភាពដូច្នោះដែរ : ខ្មែរគាន់ទំនៀមថា ក្នុងការយកគ្នាជាប្តីប្រពន្ធ, កូនប្រុសស្រី មិនត្រូវនិងឋះនាទតាមអំពើចិត្តខ្លួនទេ ៗ រឿងនេះ ជាភារៈជាប់មុខនៃឪពុកម្តាយ ៗ ចំណែកខាងបស្ចិមទិស និយមប្រកាន់ថា បណ្តោយទុកឲ្យកូនប្រុសស្រីស្វែងរកស្នេហាដោយខ្លួនឯងសិន បើមានការព្រមព្រៀងគ្នាហើយ ទើបឪពុកម្តាយរៀបចំឲ្យ ព្រោះគេយល់ថា ដំណើរជីវភាពនឹងអាចប្រព្រឹត្តទៅប្រកបដោយសុភមង្គលបាន លុះណាតែគោទាំងពីរមានកម្លាំងស្មើគ្នាដើម្បីទាញកូនរថនេះផង ហើយមានការស្រុះស្រួលគ្នាផង ៗ

ចំពោះរឿងតាំងពីរផ្នែកនេះ : មួយថា ស្រេចលើឪពុកម្តាយ មួយថា ស្រេចនៅលើកូន ៗ តើត្រូវនិយមយកណាទុកជាការប្រសើរ ?

តាមការពិចារណាឲ្យល្អិតល្អន់ និង តាមការពិនិត្យសង្កេតមើលយ៉ាងម៉ត់ចត់ ឃើញថា របៀបតាំងពីរនេះ មិនអាក្រក់ជាងគ្នា មិនល្អជាងគ្នាទេ ឧបមាដូចជាគេធ្វើលេខបូក : ៤+៣ ត្រូវឃើញលទ្ធផល "៧" ហើយបើគេដាក់លេខ ៣ មុន រួចដាក់លេខ ៤ ក្រោយ : ៣+៤ ក៏នៅតែហុចលទ្ធផលដូចគ្នាគឺ ៧ នេះឯង ។

ជនជាតិខ្មែរ និយមទុកស្រីក្រមុំជារបស់មានតម្លៃបរិសុទ្ធ ។ ដូច្នេះទើបខ្មែរប្រើពាក្យមួយ៉ាង ដែលប្រទេសដទៃមិនធ្លាប់មាន សម្រាប់ហៅស្រីក្រមុំ គឺ « ស្រីព្រហ្មចារី ឬ ព្រហ្មចារី » ប្រែថា អ្នកប្រព្រឹត្តធម៌ប្រសើរបរិសុទ្ធ ។ ដោយទុកស្រីក្រមុំជារបស់ប្រសើរបរិសុទ្ធនេះហើយ បានជាខ្មែរមិនព្រមអនុញ្ញាតឲ្យស្រីក្រមុំ មានការទាក់ទងខាងផ្លូវស្នេហាជាមួយនឹងបុរសទាល់តែសោះ សូម្បីតែដោយរបាក៏ដោយ មុនការរៀបអាពាហ៍ពិពាហ៍ ព្រោះខ្លាចការទាក់ទងនេះ ក្លាយទៅជាការសៅហ្មងដែលជាហេតុនាំឲ្យខូចកិត្តិយសនៃខ្លួនផង នៃគ្រួសារផង ធៀបឧបមាដូចសំពត់ក្ទុងក៏ កាលបើយកមកលាតត្រដាងលាតកណ្តាលខ្យល់កណ្តាលថ្ងៃហើយ មុខជានឹងមានការមិនស្អាតមកប៉ះពាល់ ដែលជាហេតុធ្វើឲ្យសៅសម្បុរខ្លះមិនខាន ។

សួរថា : ដែលខ្មែរប្រកាន់ទំនៀមថា ត្រូវទុកឲ្យឪពុកម្ដាយជាអ្នករៀបចំទុកដាក់ ហើយសាមីខ្លួនចាំតែទទួលយក តើការនិយមនេះ រមែងធ្វើឲ្យគូស្រករថ្មីបាក់បែកគ្នាជានិច្ច មិនដែលគេសុខមង្គលឃើញ ឬយ៉ាងណា? ដែលបស្ចិមប្រទេសប្រកាន់ទំនៀមបណ្ដោយឲ្យកូនសួរចិត្តគ្នាមុនឲ្យហើយស្រេច រួចសឹមឪពុកម្ដាយរៀបចំការឲ្យជាក្រោយ, តើការនិយមនេះ រមែងធ្វើឲ្យគូស្រករបានស្រុះស្រួលគ្នាតែគ្រប់រូប ហើយចេះតែរកសុខមង្គលឃើញរហូតទៅឬយ៉ាងណា ?

ចំណែកសំនួរទាំងពីរនេះ គួរគប្បីពិចារណាដែរ ព្រោះច្បាប់ខាងគុណាការនៃបស្ចិមទិស ក៏មានបែងនូវមាត្រាខ្លះ ស្ដីពីបើកសិទ្ធិឲ្យប្ដីប្រពន្ធលែងលះគ្នាបានដែរ ។ ឯច្បាប់គុណាការខ្មែរ ក៏មានរឿងនេះដូចគ្នា ។ ដូច្នេះទឹងសម្រេចថា ខាងណាប្រសើរជាងខាងណាក៏មិនបាន បើប្រកាន់ថាបស្ចិមទិសប្រសើរ ម្ដេចក៏មានការលែងលះគ្នាដែរ បើចោទទម្លាក់ទោសថា ទំនៀមខ្មែរនិយមក្ដាប់សិទ្ធិ ក្នុងការជ្រើសរើសគូស្វាមីភរិយា ក៏មិនឃើញការនិយមនេះបណ្ដាលឲ្យគូស្រករថ្មី ចេះតែបែកបាក់គ្នាគ្រប់តែគ្រួសារទៅ ក៏ឃើញតែមានគ្រួសារ នៅរួមសុខទុក្ខជាមួយគ្នា ពាសពេញទាំងប្រទេស បង្កើតជាកូន តូនជាចៅយ៉ាងច្រើន ។

សព្វថ្ងៃ កម្ពុជាមានពលរដ្ឋជាងប្រាំមួយលាននាក់ដែរ ដែលចេះរួបរួមគ្នា ក្រោមការដឹកនាំដ៏ថ្លៃថ្លានៃសម្ដេចឪ ដើម្បីកសាងជាតិដូចអាស្យ-

ប្រទេសដទៃ ៗ ឬមួយគេយល់ថាចំនួនពលរដ្ឋប៉ុណ្ណះ មិនសមនឹងទំហំប្រទេស ដោយមកពីគ្រួសារគ្មានស្នេហារួម ដែលជាមូលហេតុបណ្តាលឲ្យខ្វះការកើតកូនល្មម? បើយល់ដូច្នេះ ហាក់ដូចមិនសូវសម ព្រោះគ្រួសារភាគច្រើនរបស់ខ្មែរ សុទ្ធសឹងមានកូនច្រើនលើសពីចំនួនប្រាំ ៗ បើយល់ថា គ្រួសារខ្មែរភាគច្រើន សម័យមុន មិនសូវបេះក្បួនអនាម័យ ក៏ការចិញ្ចឹមទារកនោះ ទើបដូចជាត្រូវគ្រាន់បើ ៗ

ខ្ញុំធ្លាប់បានដឹងបានឮមកជាញឹកញយថា គ្រួសារប្តីប្រពន្ធរបស់ជនបស្ចិមប្រទេស និងជនជាតិយើងខ្លះ ដែលប្រកាន់តាមប្រពៃណីបស្ចិមប្រទេស ក៏គង់មានការទាស់ទែងខ្វែងគំនិតគ្នា មិនបានសុខស្រួលនឹងគ្នា រហូតដល់ទៅមានការបាក់បែកលែងលះគ្នា ក៏មានច្រើនដែរ ៗ

តាមយោបល់ផ្ទាល់របស់ខ្ញុំ, ខ្ញុំយល់ឃើញថា បើទំនៀមទាំងពីរនេះមិនជាល្អ មិនជាអាក្រក់ជាងគ្នាទេ គួរតែជនខ្មែរយើង និយមប្រកាន់ទំនៀមរបស់ខ្លួនជាការប្រសើរជាង : ទី ១- ឲ្យឃើញថាយើងជាអ្នកជាតិនិយម, ទី ២- ស្រីនិងប្រុសដូចស្រមោចនិងស្ករ; ស្រមោចនៅជិតស្ករ វៀរលែងតែស្រមោចអហេតុ ទើបមិនរើរកម ទើបមិនលួកលាន់នាយអាយបណ្តើរ បើស្រមោចបុប្ផនជម្ពាទេ ចំពោះរឿងហ្នឹងមិនបាច់ពោលឲ្យវែងឆ្ងាយទៀយ ម៉្លោះហើយព្រហ្មចរិយធម៌ ដែលឪពុកម្តាយខំថែរក្សាមក មុខជានឹងត្រូវសៅហ្មងខ្លះមិនខាន នឹងជាឲ្យគ្មានសោះ

នោះ ឥតអន្លឹមានឡើយ ។ ត្រង់នេះហើយ ជាកិត្តិយសដ៏ធំ របស់គ្រួសារ ហើយនឹងក្លាយទៅជាពូជមិនល្អតកូនតចៅផង ។

យុវជនជាអ្នកក្រាស់ទៅដោយកាមរាគ ជាអ្នកមានការពិសោធន៍ស្ដួចស្ដើង លុះបានជួបនឹងស្ត្រីបរទេស សមនឹងវិស័យ ឬចំណុចចិត្តខ្លួន ក៏នាំគ្នាផ្ដេកខ្លួនប្រុស ៗ ទៅតាមឥតបង្អង់ ដូចពាក្យចាស់ ៗ តែងនិយាយថា " ដេកផ្ញុំផ្ញួល រមួលផ្សំគ្រប " ហើយនាំគ្នាលើកដំកើងនូវស្ត្រីនេះថា ល្អប្រសើរជាងប្រពៃណីរបស់ខ្លួន ដែលធ្លាប់មានហូរហែពីព្រេងនាយមក ។

សូមយុវជនទាំងពីរភេទ ពិចារណាឲ្យជិតដល់ល្អិតល្អន់ចុះ : ការប្រកាន់ទំនៀមទម្លាប់ជាតិនេះ ជាការលើកដំកើងជាតិម្យ៉ាងដែរ ហើយមាតាបិតាអ្នកទាំង ក៏សប្បាយចិត្តរីកថ្លើមប្រមាត់ ដោយសារអ្នកទាំង ។ កាលបើមាតាបិតា មានកិត្តិយសហើយ ឈ្មោះថាអ្នកទាំងបានបំពេញចំពោះមាតាបិតា នូវករណីយកិច្ចជាកូនប្រកបដោយធម៌ និងដោយកតញ្ញូតា ។ មាតាបិតា មិនមានការសប្បាយរីករាយអ្វី ជាងបានឃើញអ្នកទាំងគោរពលោក ធ្វើតាមដំបូន្មានលោកឡើយ ។ ដូច្នេះ ការគោរពនិងការស្ដាប់នូវដំបូន្មានដ៏ស្លូតត្រង់នៃមាតាបិតា ចាត់ទុកជាកតញ្ញូតាមួយផ្នែកធំរបស់កូនចំពោះលោក ហើយសិរីសួស្ដីនិងសុភមង្គលគ្រប់ប្រការ ក៏នឹងអាចកើតមានដល់អ្នកទាំងជាពិតប្រាកដ ។

ដោយហេតុមកពីខ្ញុំបានសរសេរ អំពីរឿងទំនៀមទម្លាប់ខាងយកគ្នាជាគូប្រចាំជីវិតរួចហើយនោះ ខ្ញុំសូមបន្ថែមបន្តិច នូវរឿងដំណើរជីវភាពនៃគ្រួសារខ្លះ ដែលមានសភាពមិនសូវសុខស្រួល រវាងស្វាមីភរិយា បណ្តាលមកច្រើនតែពីផ្នែកខាងទ្រព្យសម្បត្តិ ។

ក្នុងគ្រួសារខ្លះ ជួនកាល ប្តីជាពូជអម្បូរអ្នកមានធនធានច្រើន ឯប្រពន្ធក្រីក្រ ។ ជួនកាលប្រពន្ធ ជាពូជអ្នកមានធនធានច្រើន ប្តីក្រីក្រ ។ គ្រួសារដែលប្តីនិងប្រពន្ធមានកេរ្តិ៍មិនស្មើភាគគ្នានេះហើយ ច្រើនប្រទះនឹងពាក្យកោសស្រែកគ្នាគឺពាក្យថា : "មកស៊ីដោយសារតែអញ" ។ លុះពាក្យអប្រិយនេះលេចធ្លោឡើង ដំណើរនៃគ្រួសារនោះក៏ត្រឡប់មានសភាពរកាក់រកុល ជួនកាលហួសដល់មានការបែកបាក់លែងលះគ្នាផងក៏មាន ។

ឯការដែលពោលថា ខាងនេះឬខាងនោះ "មកស៊ីដោយសារតែអញ", បើតាមយោបល់ខ្ញុំ គឺជាការមិនគួរពោលតែសោះ ។ ហេតុបានជាហ៊ានថាមិនគួរ ព្រោះមុននឹងទទួលយល់ព្រមយកគ្នាជាគូប្រចាំជីវិតម្នាក់ៗ សឹងបានស៊ើប បានពិនិត្យយ៉ាងម៉ត់ចត់ អំពីទ្រព្យសម្បត្តិរួចស្រេចអស់ហើយ ហេតុអ្វីក៏យកសំដីអប្រិយ "ស៊ីដោយសារ" មកប្រើ ធ្វើឲ្យរលាយខ្សែជីវិត ដែលបានរៀបបញ្ចូលគ្នាយ៉ាងស្អិតមាំហើយនោះ ។ ច្បាប់មនុស្សធម៌ប្រាប់ថា : ប្តីប្រពន្ធមានខ្សែជីវិតតែមួយ បានន័យថា មានក្រពះតែមួយ សម្រាប់ផ្ទុកអាហារ ។ បើមនុស្សពីរ

នាក់ មានក្រពះតែមួយ, តើគួរឲ្យខ្មាសផ្សាឬទេ ដែលយកពាក្យ “ស៊ីដោយសារ” មកប្រើ? ។

សួរថា: បើមិនឲ្យយកសំដីនេះមកប្រើ តើត្រូវធ្វើដូចម្ដេច ?

ឆ្លើយថា: ត្រូវតែតាំងចិត្តសាមគ្គី អត់ធ្មត់គ្នាទៅវិញទៅមក រួមសុខទុក្ខជាមួយគ្នា កសាងគ្រួសារតទៅ គឺថាត្រូវតាំងចិត្តថា ប្ដីរបស់អញ, ប្រពន្ធរបស់អញ, ទ្រព្យរបស់អញ ជាទ្រព្យរបស់ប្រពន្ធអញ, ទ្រព្យរបស់អញ ជាទ្រព្យរបស់ប្ដីអញ, អញនិងប្រពន្ធអញ គឺជាអញតែមួយ, អញនិងប្ដីអញ គឺជាអញតែមួយ ។ ទុក្ខរបស់អញ ជាទុក្ខរបស់ប្រពន្ធអញ, ទុក្ខរបស់អញ ជាទុក្ខរបស់ប្ដីអញ ។ ឯការសប្បាយរីករាយក៏ដូចគ្នា ។

មានប្ដីប្រពន្ធភាគច្រើនណាស់ ដែលខ្វះការអប់រំយ៉ាងប្រសើរ តែងគិតថា ប្រពន្ធផ្សេង ខ្លួនឯងផ្សេង ប្ដីផ្សេង ខ្លួនឯងផ្សេង រហូតដល់ទ្រព្យសម្បត្តិទៀត ក៏មានបែងចែកឲ្យនៅផ្សេងពីគ្នាដែរ ។ តាមយោបល់ខ្ញុំ, ប្ដីប្រពន្ធប្រភេទនេះ មិនសមនឹងហៅថា “ប្ដីប្រពន្ធ” ឡើយ គួរហៅត្រឹមតែ “ប្រុសស្រី” បានហើយ គឺថាប្រុសអញ ស្រីអញ ។ ពាក្យថា ប្រុសស្រី មានន័យផ្សេងឆ្ងាយពីពាក្យថា ប្ដីប្រពន្ធ ព្រោះប្ដីប្រពន្ធ ជាកិច្ចសន្យាមួយយ៉ាងឧឡារិកធំណាស់ ជាកិច្ចសន្យាដែលមានមនុស្សដ៏នក្ដីរាប់រយ រាប់ពាន់នាក់ បានទទួលដឹងឮ ហើយនិងធ្វើជាសាក្សីផង ។

បើតាមយោបល់របស់ខ្ញុំ, ពាក្យអប្រិយៈនេះ ពាក្យតក់រកនេះ ភាគច្រើនបណ្ដាលមកតែពីមាតាបិតា ដែលមានការអប់រំ ឬមានកូដត្រកូលមិនសូវប្រសើរ ជាមាតាបិតាដែលគិតតែផលប្រយោជន៍ខាងសម្ភារៈច្រើនជាងផលប្រយោជន៍ខាងផ្លូវចិត្ត ។ តាមដែលធ្លាប់បានដឹងមក រវាងប្ដីប្រពន្ធ មិនសូវជាមានការអ៊ូជាំដុំប៉ុន្មានទេ, តែលុះមាតាបិតាយកភ្លើងមកដុតពីក្រោយញួយ ។ ប្ដីប្រពន្ធក៏ត្រូវតែបែកបាក់គ្នា ។

សូមជំរាបបញ្ជាក់ថា ៖ អត្ថប្រយោជន៍ខាងផ្លូវចិត្ត មានសភាពប្រសើរក្រៃលែងជាងអត្ថប្រយោជន៍ខាងសម្ភារៈ ។ មិនមែនមានចំនួនតិចទេ ដែលគ្រួសារប្ដីប្រពន្ធប្រកបដោយអត្ថប្រយោជន៍ខាងសម្ភារៈដ៏បរិបូរ ហើយទទួលរងទុក្ខវេទនាក្រៀមក្រំ ដូនកាលរហូតដល់ស្លាប់ខ្លួនក៏មាន ព្រោះតែប្ដីប្រពន្ធនេះ ខ្វះអត្ថប្រយោជន៍ខាងផ្លូវចិត្ត ហើយមិនមែនមានចំនួនតិចទេ ដែលប្ដីប្រពន្ធខ្វះអត្ថប្រយោជន៍ខាងសម្ភារៈ តែបែរជាមានដំណើរជីវភាពគ្រួសារយ៉ាងសប្បាយរីករាយ ដោយសារតែគេមានអត្ថប្រយោជន៍ខាងផ្លូវចិត្តបរិបូរ ។

ដូច្នេះ គួរអស់លោកអ្នក និយមគិតអត្ថប្រយោជន៍ខាងផ្លូវចិត្តឲ្យច្រើនជាងអត្ថប្រយោជន៍ខាងសម្ភារៈបន្តិច ទើបដំណើរជីវភាពគ្រួសារអាចប្រព្រឹត្តទៅដោយប្រពៃ ដូចជាខ្សែទឹកស្ងឹមក្នុងពេលស្ងប់ខ្យល់ ។

ផេង-គ្រីវ

# គួរតម្រង់ទិសអក្សរសាស្ត្រឲ្យចំគោលដៅ

កវីនិពន្ធរបស់សហជីវិន មាស-យុត្ត

ស្រណោះផ្គរលាន់ពាន់វេលា ផ្គរព្រួខ្ទរខ្ទារនៅផ្ទៃមេឃ
ឲ្យអស់ឃើញគេហៀរទឹកភ្នែក យំផែកដេកគិតរឿងកំសត់ ៗ
អាណិតនាង-អ្នកកូនចៅជាតិ ដែលប្រើពាក្យឃ្លាតែបែបបទ
ប្រឡូកលូកលេងល្បែងផ្លូវចត់ ឃ្លាតផ្លាតបត់ចុះខុសគោលដៅ ៗ
សៀវភៅប្រលោមលោមនារី ពាក់ស៊ីដក់ក្លូក្រខ្វាចនៅ
ពេញបណ្ណាគារហៀរពេញក្រៅ ទីដៅខ្លៅល្ងិតគិតតែលុយ ៗ
ព្រោះតែអស់លោកអ្នកនិពន្ធ លោកលន់ធ្ងន់ពិតគំនិតផ្ទុយ
យករឿងល្បែងធម៌ស្ដើងទុយ ពាក់លុយយកលាភកាពាះស្នាក់ក្រោក
អក្សរសាស្ត្រខ្មែរបែរខុសទិស ប្រឡាក់ថ្នាំពិសប្រលោមលោក
ព្រលឹងសិល្បៈប្រឡាក់ជោក យោលយោគទៅតាមស្នាមស្នេហា ៗ
គឺរឿងប្រឌិតគិតប្រដូច ប្រដៅផ្លូវខូចខាងកាមា
ត្រអាលស្រាលស្រើបហើចហ៊ុហា ចរចាខ្លួនឆ្លើយគើយកៀកគង់ ៗ
ឱបតែហាតហូបស្រូបកូនក្លូប បទបែប „ នេះ–ខ៊ុះ „ ខុសទំនង
ទំនើងចិត្តក្មេងលេងក្រាបពាង ផ្គាំផ្គង់ផ្គួតកាមញាមតណ្ហា ៗ
ក្មេងខ្ចីស្នាក់តើនៅទន់ជ្រាយ រាងាយជិតជាមស្នាមចរិយា
មើលអានបានដឹងឃើញយ៉ាងណា ចិន្តាព្រឺព្រួចដួចដោតជាប់ ៗ

ខូចចិលខានល្បែងលេងល្បួចលាក់ ជ្រៅកក់ថ្នាក់ផ្ទើភ្លើភ្លេចឆាប់
ភ្លេចអស់ទាំងខ្នាតគួរគាប់ ភ្លោយភ្លាប់ព្រៃហើនភ្លើនផ្លូវខុស ៗ
ដឹងកលយល់កិច្ចល្បិចស្នេហា បរិបារលោមល្អួងល្បួងស្រីប្រុស
គេះគៀវស្រៀវស្រើបហើបឡើងចុះ ស្របស្រុះផ្ទុះថ្ងើមហើមប៉ុនល្អី ៗ
ខេះគិតខ្វិតពលប្រលោមលុយ ដូចនុយដាក់ដោតបញ្ឆោតត្រី
ជាអាចខាញទទឹលងំលោកិយ ប្រុសស្រីពើងទ្រូងប្រឡងខាម ៗ
ប្រឡាសប្រាសបាតគន្ធធម៌ ឈ្នះរគោតនៅទៅរកកាម
បេះក្បួនប្រលោមប្រឡូកកាម ប្រឡាក់ជាប់ស្នាមស្រមាមប៉ាក់ ៗ
ស្រមោលការអានរឿងមិនល្អ សីលធម៌ធ្លុះធ្លាយជ្រាយរខាក
កូនយើងកូនគេរេចូលតាក ប្រាសបាតគម្រោបច្បាប់មេបា ៗ
ភគពេលដោលដំត្រាំលោក រលើងប៉ុងគ្រាកក្រៀមខ្ទោចផ្កា
ក្រឡាប់ផ្កាប់ចុះខុសចរិយា យាយតាភាស់ក្អែកមិនកេតផង ៗ
កូនចៅស្រីប្រុសចុះផ្លូវព្រើល ភ្ញាក់ផ្អើលមើលអានរឿងសៅហ្មង
គ្រប់ក្រៅមានរូបស្រស់ខ្លួនល្អង ញ៉ែងញ៉ីងស៊ីផឹកលក់លោហិត ៗ
ខានក្នុងផ្ទៃរឿងមានរសជាតិ យៀងយ៉ាតគម្រោបច្បាប់ក្រមក្រិត្យ
ពិសពាលពើតពុលជម្រុលចិត្ត លូកលិទ្ធជ្រៅកក់លាក់ក្រោយខ្នង ៗ
គ្រអាលស្រាលស្រើបហើបស្ញប់ស្ញិត កៀកកិតគេះគៀវស្រៀវស្រួបស្រង
ជួបជួនខ្លួនស្រីខ្ទិលអង គ្រើបក្រងលំអគេសរកាម ៗ

គោបពាប់ក្តាប់ជាប់គាប់អារម្មណ៍ ឃើញសមទំសេពហៃហាបហៃហលតាម
ស្រងល់ខ្វល់ខ្វក់ស្រក់ហោម ដិតស្នាមដាមស្នឹមពាំទុក្ខា ។
ទុក្ខចាំជាំជោកពោគព្រួយព្រឺ ធ្ងួលឈឺធាបធេះប្រេះទ្រា
ព្រោះព្រើលប្រលោមទោមបាតផ្សារ ចរិយាខ្ចួចខ្ទុសចុះយ៉ាប់យ៉ាក ។
ក៏សង្ខាយុវជនទន់វៀចវេរ ឆាកវេរគាមដាមប្រគាក
ប្រគាងបៀងពោះឈ្មោះគោក ម៉ែឪស្រឆាកស្រឆោចចិត្ត ។
ការអានកំសាន្តរឿងផ្ដេសផ្ដាស ឥតការអៀនខ្មាសប្រាសក្រមក្រិត្យ
ស្នឹមល្អក់ស្រក់ស្រោចខ្មោចខ្មៅល្ងិត ចាស់ទុំភាស់ចិត្តស្បិតក្រឡេក ។
ខ្ទះខ្ទឹងប្រឹងខំផេរប្រទេច ក្មេងគេចមុខសេចសម្ញុំជេក
ក្អួចការស្មូត្រវៀនញៀនគម្រេក ផ្តួលផ្ដេកខាងល្បែងលេងឡកឡាយ
ទំពក់ភ្ជាក់ខ្ជួនជ្ជួនខកជ្រុល ពិសពុលពេញពោះពិបាកស្រោយ
ទើបព្រមសារភាពជំពប់ម្ដាយ ជួយកាយជួយគេះកែលែងបាន ។
នេះឯងគឺខ្ទាំងខ្មោចបិសាច គ្រោះកាចចង្រៃភ័យសាមាន្យ
ស្ទាក់ចាំបេះបោចខ្ចប់ខ្ជួនប្រាណ រញ្រានពន្ទិចក្តិចពន្ទក ។
ពន្ទឹសីលធម៌គឺជុនជាប ផលបាបផ្អាបស្អុយហុយហុបមក
ខ្វល់ខ្វក់ល្អក់ល្អមតាមជ្រៀតជ្រែក កៀងយកព្រលឹងយុវជន ។
ហេតុនេះគួរយើងខំរិះគិត ពិនិត្យស្រិតស្ទៃលៃរូបមន្ត
ឲ្យត្រូវផ្លូវត្រង់អង្គទិពន្ធ ភោរទន់ទៅតាមស្នាមទីដៅ ។

ទុកជាលំអអក្សរសាស្ត្រ កុំឲ្យប្រឡាសប្រាសចេញក្រៅ
កើតកើនស៊ីផក់ក្នុងក្រមួបនៅ សោកសៅក្តៅនេះប្រេះថៃបធា ។
នាំកើតទុក្ខទាំងជាប់ប្រាណ រំខានខូចចិត្តកុមារ
វេតឃ្លាតក្លួចកិច្ចសិក្សា រត់ចូលរាំបារតាមមិត្តម៉ាក ។
តាមកិច្ចល្បិចល្បែងតែងឲ្យទុក្ខ ឲ្យពាសគ្រប់មុខទុក្ខគោកយ៉ាក
សោកសៅក្តៅក្លួលអួលឥតស្រាក ត្អូញត្អាក់កុំផ្អើលព្រើលតាមចង់ ។
ខ្ញុំសូមគោរពអ្នកនិពន្ធ ដែលមានចិត្តធ្ងន់ស័ក្រស្មោះត្រង់
ជួយស្ទាក់ញាក់ស្វៃលផ្ចិតផ្ចង់ រកផ្លូវត្រូវត្រង់ឲ្យកូនចៅ ។
គឺជួយស្ទួយស្ទង់អក្សរសាស្ត្រ កុំនាំផ្តេសផ្តាសខុសគោលដៅ
កុំឲ្យវេតឃ្លាតចេញក្រៅ ហ្មង់សៅចរិយាកុមារខ្មែរ ។
ព្រោះតាមធម្មតាការមើលអាន ប្រៀបបានទឹងការអប់រំដែរ
និស្ស័យចិត្តថ្មីផ្តើមបត់បែរ ទៅតាមស្នាមខ្សែរឿងនោះឯង ។
បើរឿងប្រលោមលុះដោយកាម ស្នាកស្នាមដាមល្អក់ជក់ត្រាំត្រែង
នាំវិលវិលខុសចុះផ្លូវល្បែង កូនគេកូនឯងតែងអបអរ ។
កើតការពុកផុយស្អុយផ្អេះផ្អាប ដុនដាបសាបសូន្យសីលធម៌
ព្រោះការកើតកើនច្រើនកុះករ នៃរឿងមិនល្អអក្សរសាស្ត្រ ។
ហេតុនេះពួកយើងអ្នកនិពន្ធ ត្រូវបេះរះគន់គិតអៀនខ្មាស
កុំនាំគេ ៗ វង្វេងផ្តាស ប្រែប្រាសចូលព្រៃគួរភ័យព្រួយ ។

កុំចង់ចំណេញតែលុយកាក់ គ្រោះថ្នាក់ពុកផុយស្អុយរលួយ
រលាយក្លាយប្រេះបេះតែពួយ ត្រូវជួយស្ទួយស្ទង់វិជ្ជាប្រពៃណី ៗ
ផលកំពុកសនាយុវជន យើងអ្នកនិពន្ធត្រូវសកិ
ទាញទប់គម្រង់ផ្គង់ទិសទី ឲ្យបានល្បីគ្រប់វិស័យ ៗ
យុវជនជាតិយើងជាកម្លាំង គគាំងឧបសគ្គគ្រោះចង្រៃ
គួរយើងអប់រំទំរែង ជួយថែឲ្យល្អតវែងឆ្ងាយ ៗ
គឺតាមរយៈអក្សរសាស្ត្រ យើងត្រូវប្រកាសប្រកួតផ្សាយ
គំនិតត្រឹមត្រូវផ្ទុកសាយ ឧបាយសាងជាតិឲ្យឃ្លាតទុក្ខ ៗ
ត្រូវលើកទឹកចិត្តខាងការងារ ស្ទុះស្ទួចឲ្យជឿនលឿនទៅមុខ
បង្កើតភោគផលសល់គរទុក ពោរពេញជង្រុកទុកលក់ដូរ ៗ
សេដ្ឋកិច្ចជាតិយើងថ្កើងខ្ពង់ខ្ពស់ យើងរស់រុងរឿងថ្កើងសម្បូណ៌
សម្បត្តិធនធានមានហៀរហូរ ជីវភាពថ្លៃថ្នូរធូរសប្បាយ ៗ
ជាតិយើងត្រូវការជាបឋម នូវអ្នកដឹកនាំក្មេងទាំងឡាយ
ឲ្យដុះគំនិតគិតខ្វល់ខ្វាយ ចង់កាយកាប់គាស់កាស់ការដី ៗ
ធ្វើស្រែយកស្រូវឲ្យបានច្រើន កើតកើនទិន្នផលមួយជាបី
ប្រើជីគីមីប្រែភាពដី ឬគាស់ការថ្មីដីច្រើនណាស់ ៗ
សេដ្ឋកិច្ចប៉ុបពកពន្លកឡើង ចុះថ្កើងឬស្លាប់ងាប់រហ័ស
អាស្រ័យយើងខ្មែរទាំងក្មេងចាស់ ប្រែផ្លាស់គំនិតគិតធ្វើការ ៗ

ទ្រទ្រង់ស្នូនស្នៃលតម្រូវ ត្រង់ផ្លូវប្រសើរមានខ្លឹមសារ
បណ្តុះគំនិតចិត្តកុមារ ឲ្យចេះស្នេហាកសិកម្ម ៗ
នេះឯងគោលដៅល្អវិសេស ដែលព្រះមគ្គុទ្ទេសក៍ទ្រង់ផ្តាំ
ឲ្យខ្មែរគ្រប់ប្រាណបានចងចាំ កុំងាកឆ្វេងស្តាំនាំប្រេះឆា ៗ
យុវជនយើងឡើងថ្កើងថ្លៃ អាស្រ័យមានច្បាប់ក្បួនតម្រា
ជាព្រញ្ញប្រាប់ផ្លូវត្រូវយាត្រា នេះជាមុខការអ្នកនិពន្ធ ៗ
ស្រណោះផ្គរលាន់ឮរណ្តំ ផ្គរព្រួយបារម្ភខំរិះគន់
ក្រែងភ័ព្វកុសនាយុវជន ចាប់ទន់ធ្ងន់ចាប់ជាប់អវិជ្ជា ៗ
ទើបផ្គរលាន់ញាប់បន្ត អង្វរកូនចៅខ្មែរគ្រប់គ្នា
ឲ្យចេះរួបរួមព្រមសាមគ្គា កុំបែកខ្ញែកគ្នាទៅឆ្វេងស្តាំ ៗ
ត្រូវខំបំរើប្រយោជន៍ខ្មែរ ធ្វើស្រែចំការច្បារដំណាំ
កាប់គាស់កសដីដាក់ជោគជាំ បង់ចាំចាប់ចិត្តស្អិតនិត្យនៅ ៗ
នេះឯងទីដៅមានខ្លឹមសារ ដែលខ្មែរត្រូវការយាត្រាទៅ
ណោងចាប់យកផលដល់ជំពៅ កុំនៅស្ងើរស្ងាក់កក់កំផែល ៗ
កុំធ្វើគុញគុះគៀតាល់ប្រូក ក្រែងខកខ្យុកខុសពុះទឹកហែល
តែដល់ជោរជន់ភ្ញាន់ក្រែល ក្រៃលេលតោលទ្រុះទើបផ្លាស់បាន ៗ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

-ជលាឝយ ពុំ. ឧទយៈទឹកខាងក្នុង ។ -ជ្យោតិស៑ គុ. ដែលភ្លឺខាងក្នុង; ពុំ. ពន្លឺខាងក្នុង ។ -ទិវាហ នបុំ. បន្ទោះនៃថ្ងៃផង ។ -ទាហ ពុំ ភ្លើងក្នុង ។ -ទុះខ គុ. ដែលមានទុក្ខខាងក្នុង ។ -ធន នបុំ. អន្តធន, ធនខាងក្នុង ឬកំណប់ទ្រព្យ ។ -ធា ស្ត្រី. -ធិ នបុំ. ទីបំពួន ។ -ធាន នបុំ. កិរិយាតាំងនៅខាងក្នុង, កិរិយាលេបបាត់ ។ -ធានគតិ ស្ត្រី. កិរិយាធ្វើឲ្យបាត់ទៅ ។ ធានបរ គុ. ដែលចរទៅមើលមិនឃើញ ។ -ធៃយ នបុំ. ភាពមាំមួនខាងក្នុង ។ -ធ្វាន្ត នបុំ. ទីងងឹតខាងក្នុង ។ -នគរ នបុំ. រាជនិវេស ។ -និខាត គុ. ដែលធ្លាក់ ។ -និវេឝន នបុំ. បន្ទប់ខាងក្នុង,

អត្ថវិសេស ។ _និហិត គុ. ដែលគេតម្កល់ខាងក្នុង ។ ដែលរៀបចំខាងក្នុង ។ _ពាប្ប គុ. ដែលមានទឹកភ្នែកទីខ្ទប់ទុកហើយ; បុ. ទឹកភ្នែកខាងក្នុង ។ _ភិវែឆម៌ ក្រ.វិ. ខ្វង់ខាងក្នុងលំនៅ ។ _ភាវ បុ. អន្តភាព, កិរិយាបាត់បង់, សេចក្ដីស្លាប់, ការដែលនៅខាងក្នុង ។ _ភិន្ន គុ. ដែលបែកខាងក្នុង ។ _ភូត នបុ. អន្តភូត, កិរិយាកើតខាងក្នុងចិត្ត ។ _ភូមិគត គុ. ដែលបិតនៅខាងក្នុងដែនដី ។ _ភោម ខ្ញួញ ។ _ភេទ បុ. អន្តភេទ, កិរិយាបែកធ្លុះខាងក្នុង ។ _មិទាវិស គុ ដែលអាចមិទៈបិតនៅធ្លុះខាងក្នុង ។ _មនសី គុ. ដែលមានចិត្តស្មើយណាយ, ដែលមានចិត្តព្រួយ ។ _មិគ្និវ នបុ. បន្ទប់ស្រីស្រីង្គារ ។ _មិមិនី នបុ. ចិត្ត ។ _មុខ គុ ដែលមានមុខបែរទៅខាងក្នុង ។ _មោទ បុ. សេចក្ដីរីករាយខាងក្នុង ។ _យាមិនី បុ. ព្រលឹង, កិរិយាឆាំខាងក្នុង,

ព្រាហ្មណ៍ៗ ។ -លីន គុ. ដែលជួនខាងក្នុង, ដែលមិនចេញឲ្យឃើញ, ដែលកំបាំង ។ -វម្សិក ប៉ុ. អ្នករក្សាបន្ទប់ស្រីស្រីង្គារ ។ -វិស្ត្រ ឬ -វាស នប៉ុ. សំពត់, អាវទ្រនាប់ ។ -វាណី គុ ដែលចេះ ។ -វាស ប៉ុ. កិរិយានៅខាងក្នុង ។ -វិស គុ ដែលមានពិសនៅខាងក្នុង ។ -វិហ្វល គុ ដែលមានកកេរណ្ដក់ឮជំខាងក្នុង ។ វុត្តិ ឬ ស្ត្រី កិរិយាប្រព្រឹត្តខាងក្នុង ។ -វេទិ ប៉ុ. អ្នកអន្តវេទិ, បណ្ដាជននៅចន្លោះមហានទីគង្គានិងយមុនា; -វេទី ស្ត្រី. ឈ្មោះប្រទេស ។ -ហាស ប៉ុ កិរិយារីករាយខាងក្នុង ។ -ហិត គុ ដែលគ្រប, ដែលបិទ, ដែលគេមើលមិនឃើញ ។ -អន្ត:ករណ នប៉ុ. ចិត្ត, មនោសញ្ចេតនា ។ -កោប ប៉ុ. (អណ្ដាងឮជំខាងក្នុង) កំហឹង ។ -បាល ឆ្មាំរាជនិវេសន៍ ។ -បុរ អន្ត:បុរ, ប្រាសាទដែលជាបន្ទាយ, បន្ទប់ស្រីស្រីង្គារ,

ស្រីស្រឹង្គារ. អន្តះបុរិក ។ —បុរចរ បុំ. អ្នកយាម ប្រាសាទស្រីស្រឹង្គារ, អ្នកដែលចូលប្រាសាទស្រីស្រឹង្គារបាន។ —បុរជន អន្តះបុរជន, ស្ត្រីនៅក្នុងប្រាសាទស្រីស្រឹង្គារ ។ —ប្រកាឝ អន្តះប្រកាស, ចក្ខុវិស័យខាងក្នុង ។ -ប្រក្ឫតិ ស្ត្រី. បន្ទាយវង្គ ។ —ប្រជ្ញ គុ. ដែលមានការចេះនៅខាងក្នុង ។ —ប្រមោទ បុំ. សេចក្ដីរីករាយខាងក្នុង ។ —ឝរីរស្ថ គុ. ដែលឋិតនៅខាងក្នុងសរីរៈ ។ ឝល្យ នបុំ សរដែលមុតចូលខាងក្នុង ។ —ឝាន្តិ ស្ត្រី. អន្តះសន្តិភាព, សេចក្ដីក្សេមក្សាន្តចូលខាងក្នុង។ —សំជ្ញ គុ. ដែលមានកិរិយាដឹងចូលខាងក្នុង, ដែលមិនសំដែងនមសិការ ។ —សត្វ នបុំ សារចូលខាងក្នុង ។ —សទស៍ នបុំ. សាលប្រជុំ ។ —សលិល គុ ដែលមានទឹកហូរចូលខាងក្នុង; —សលិលម ក្រ.វិ ចូលទឹក ។

(នៅមានត)

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(ក)

លោក ហ៊ុន-គីមសៀ រៀបរៀង

## ជំពូកទី ១

## អ្វីដែលហៅថាតក្កវិជ្ជា

និយាយខ្លីៗ តក្កវិជ្ជា គឺជាមុខវិជ្ជាមួយបែប, ឬអាចថាជាវិទ្យាសាស្ត្រមួយយ៉ាង សិក្សាអំពីវិធីត្រិះរិះ, របៀបពិចារណានៃគំនិតរបស់មនុស្ស ។ (យើងទាំងអស់គ្នា កំពុងតែប្រុងប្រៀបសិក្សាមុខវិជ្ជាមួយខាងការពិចារណាក្នុងវិធីប្រើវោហារ ការលេងសំដីឲ្យគ្រោះក្បាយ ដែលភាសាបារាំងហៅថា La logique ) ។

ជាធម្មតា រៀងរាល់ថ្ងៃ ក្នុងការនិយាយទាក់ទងគ្នាទៅវិញទៅមក យើងទាំងអស់គ្នា សឹងតែបានឮនិងបានប្រើវិធីនិយាយ តាមក្បួនតក្កសាស្ត្រ ស្ទើរតែគ្រប់គ្នាទាំងអស់ មានអ្នកខ្លះថែមទាំងបានយល់ច្បាស់នូវអត្ថរូបនិងអត្ថន័យនៃពាក្យថា « តក្កវិជ្ជា » នេះទៅទៀតផង ។

ពាក្យថា: « តក្កវិជ្ជា » នេះ គេអាចប្រើនៅក្នុងករណីខុសគ្នា ហើយអត្ថន័យរបស់ពាក្យនេះ ក៏មានរូបភាពខុសគ្នា ដោយអនុលោមទៅតាមករណីនីមួយ ៗ អ៊ីចឹងដែរ ។ ហេតុនេះ ចំពោះរូបអ្នកណាមួយដែលគេមិនសូវធ្លាប់ត្រចៀកនឹងពាក្យថា: តក្កវិជ្ជា នេះទេ គឺវាអាច —

នាំឲ្យគេយល់ច្រឡំឆាយណាស់, ពិសេសគឺនាំឲ្យគេពិបាកយល់, ស្ដាប់មិនសូវបាន ហើយពិបាកនឹងធ្វើការសង្កេតតាមដានថែមទៅទៀតផង ។ ហេតុដូច្នេះ អ្នកដែលចេះតក្កវិជ្ជា គប្បីយកចិត្តទុកដាក់ចំពោះប្រការនេះ ដើម្បីចៀសវាងការរិះគន់ ពីសំណាក់មហាជនក្នុងមជ្ឈដ្ឋានខ្លះ ដែលគេមិនធ្លាប់ស្ដាប់ គេថាខ្លួនយើងមាត់រឹង ប្រកែកយកតែឈ្នះ, ប៉ុន្តែផ្ទុយទៅវិញ ការប្រកែកដោយសំដីគ្មានបំណងយកឈ្នះចាញ់ទេ ។ល។

យើងសូមជូនឧទាហរណ៍ពាក្យថា តក្កវិជ្ជានេះ ក្នុងករណីខុសគ្នាខ្លះៗ ដែលមានអត្ថន័យក៏ខុសគ្នាដែរ ដល់មិត្តទាំងអស់គ្នា ដើម្បីធ្វើការពិចារណា កត់សំគាល់ដូចតទៅនេះ ៖

ក– " តក្កវិជ្ជាសម្ភារៈ ខ្លាំងជាងតក្កវិជ្ជាបែបណាទៀតទាំងអស់ " ។ ពាក្យថា តក្កវិជ្ជា ក្នុងករណីបែបនេះ មានន័យថាៈ វិធាន (Loi) ឬថា : ច្បាប់ធម្មជាតិ ( Loi de la nature ) ឧទាហរណ៍ : វត្ថុទាំងអស់ កាលណាត្រូវក្ដៅរីក ... សភាពបែបនេះ វាជាការធម្មតារបស់គ្រឿងសម្ភារៈទាំងអស់ជាកំហិត ។ ថៅកែកេងប្រវ័ញ្ចសព្វាហកម្មណាមួយ តែកាលណាជិះជាន់កម្មករតូចតាចខ្លាំងពេក ប្រព្រឹត្តអំពើព្រៃផ្សៃហួសពេក, ថៅកែនោះ គេចមិនរួចពីការប្រឆាំងតបរបស់កម្មករឡើយ ទោះចង់ឬមិនចង់ក៏ដោយ ពីព្រោះច្បាប់ធម្មជាតិ ឬថា តក្កវិជ្ជានៃសម្ភារៈ គឺវាយ៉ាងនេះឯង ។

១– « គាត់នេះ និយាយស្ដាប់មិនបាន, និយាយចាប់ចុងព្រយុងដើម ដូចឆ្មាចូលត្រឡោក ឬថា និយាយគ្មានតក្កសាស្ត្រ » ។ លោកនេះ និយាយពូកែ, និយាយចេះច្បាប់, និយាយងាយស្ដាប់» ។ ក្នុងករណីបែបនេះ, ពាក្យថា តក្កសាស្ត្រ មានន័យថា ការប៉ិនប្រសប់ចងក្រងគំនិត ដើម្បីនិយាយឲ្យគ្រោះក្រាយ ឬវិធីនិយាយមានរបៀប, មានហេតុមានផល, មានទុតមានខក្ត.. ។

ឧទាហរណ៍: ដៃមួយទះមិនឮទេ, ហេតុនេះ រឿងហេតុដែលកើតឡើង មិនមែនមកតែអំពីមនុស្សម្នាក់ទេ ( និយាយមានតក្កសាស្ត្រ ) ។

ដើមត្នោត មិនទៅជាដើមដូងទេ, ហេតុនេះ មនុស្សល្ងង់ មិនអាចទៅជាមនុស្សចេះបានទេ ( និយាយគ្មានតក្កសាស្ត្រ ) ។

៣– « យើងត្រូវរៀនតក្កវិជ្ជា » ។ ក្នុងករណីបែបនេះ ពាក្យថា : តក្កវិជ្ជា មានន័យថា វិទ្យាសាស្ត្រខាងវិធីប្រើពាក្យសំដី, ការពិចារណាត្រិះរិះក្បួនគំនិត ដើម្បីនិយាយឲ្យបានរឹងប៉ឹង, គ្រោះក្រាយ, ជាក់លាក់, មានហេតុមានផល ... ។ល។ ហេតុដូច្នេះ សៀវភៅតក្កវិជ្ជានេះ ក៏មានន័យដូចករណីទី ៣ នេះដែរ គឺជាវិធីប្រមូលផ្តុំគំនិត ដើម្បីនិយាយឲ្យបានពូកែ បានសេចក្ដីថា : ការសិក្សាអំពីរូបភាពនៃការលាតត្រដាងនូវគំនិត ប្រកបដោយលក្ខណៈសិល្បៈយ៉ាងគ្រោះក្រាយមាំមួន ... ។ តក្កវិជ្ជាដែលយើងនឹងពិភាក្សាគ្នាតទៅនេះ គឺជាតក្កវិជ្ជារូបភាព ដែលភាសាបារាំងហៅថា Logique formelle ។

# ការពិចារណា មានវិធានដែរឬ ?

មាន ! ពីព្រោះតែវាមានហ្នឹងហើយ បានជាមានក្បួនខ្នាតសម្រាប់សិក្សា ដែលគេហៅថា តក្កវិជ្ជា ហ្នឹងឯង ។

មានអ្នកខ្លះ និយាយថា : តាំងពីខ្ញុំកើតមក ខ្ញុំធំឡើង, ខ្ញុំចេះនិយាយ, ខ្ញុំចេះគិត . . . ខ្ញុំគិតរួចហើយ ខ្ញុំនិយាយចេញមកភ្លាម គ្មានចាំបាច់វិធាន ឬ ក្បួនខ្នាតអ្វីទេ ម្តេចក៏គេចេះតែស្តាប់ខ្ញុំបានដែរ?

យើងទាំងអស់គ្នា អាចឆ្លើយតបវិញថា « គេចេះតែស្តាប់បានមែនហើយ ចំពោះការនិយាយបន្តិចបន្តួចនោះ ហើយម្យ៉ាងទៀត នៅក្នុងគំនិតអ្នកនិយាយនោះ ក៏ត្រូវមានការត្រិះរិះគិតគូរខ្លះ ៗ អីចឹងដែរ ប៉ុន្តែសុំប្រាប់ថា មានករណីខ្លះ ការដែលនិយាយបន្តិចបន្តួចនោះ គេស្តាប់បាន ដោយគេកាត់ស្មានខ្លះផង » ។ មិត្តអ្នកអានទាំងអស់គ្នា ប្រាប់ស្រាប់ហើយថា កាលបើនិយាយដល់ការកាត់ស្មានផ្សំផ្គួចេះហើយ គឺយើងមិនបាច់និយាយដល់ការទៀងទាត់, ត្រឹមត្រូវឬជាក់លាក់ទេ, ជាក់លាក់ឯណាបាន បើកាត់ស្មានបែបនេះទៅហើយ ។

មុនដំបូងបង្អស់ យើងត្រូវទទួលស្គាល់ថា តក្កសាស្ត្រជាវិទ្យាសាស្ត្រខាងវិធីផ្សំផ្គុំគំនិត ( រៀបចំគំនិតដែលយើងគិតរួចស្រេចមកហើយ ) ។ ក្បួនវិទ្យាសាស្ត្រនេះ គ្មានប្រកាន់វណ្ណៈទេ គឺជាមគេគរួម សម្រាប់មនុស្សទូទៅក្នុងលោកឥតរើសមុខ ។

យើងទាំងអស់គ្នា ពិចារណាឧទាហរណ៍ខាងក្រោមនេះល្បងមើល បើយើងសង្ស័យថា ក្រែងលោពុំគ្មានវិញ្ញាណ :

ក- យើងទាំងអស់គ្នា ធ្លាប់ម្ដាយបំពេរកូនហើយសួរកូនថា : « អាពៅដេកលក់ហើយឬនៅកូន ? »

កូនឆ្លើយ : « ដេកលក់ហើយម៉ែ »

ខ- លោកគ្រូសួរសិស្សថា « ប្អូនឯង កើតអុតធ្ងន់ណាស់ឬ កាលពីក្មេង បានជាមុខសុទ្ធតែស្នាមកន្ទេញខ្ទុញយ៉ាងនេះ ? »

សិស្សឆ្លើយ : « បាទ ! ខ្ញុំកើតអុតធ្ងន់ណាស់កាលពីតូច ម្ដាយខ្ញុំប្រាប់ » ។ គ្រូសួរ : « ប្អូនឯងមានស្លាប់ទេ បើឈឺធ្ងន់យ៉ាងនោះ ? » សិស្សឆ្លើយ : « បាទ ! ក្រែងស្លាប់ឬទេ ខ្ញុំមិនដឹងដែរ ចាំខ្ញុំទៅសួរម្ដាយខ្ញុំមើល ? » ។

កាលណាតែស្ដាប់ឮភ្លាម គេអស់សំណើច មិត្តមានឆ្ងល់ឬទេ ពីព្រោះហេតុអ្វីបានជាគេអស់សំណើច យើងពិចារណាល្បងមើល ? ។

យើងសុំជូនឧទាហរណ៍មួយទៀត ដើម្បីបញ្ជាក់ដូចតទៅ ៖

មានបុរសម្នាក់ជាអ្នកដំណើរ ដើរមកជួបនឹងកសិករម្នាក់កំពុងតែភ្ជួរស្រែ; អ្នកដំណើរនោះ ឈរក្រឡេកទៅមួយកន្លែង ហើយស្រែកសួរទៅអ្នកភ្ជួរស្រែថា : « បងអើយ ! ដើរប៉ុន្មានម៉ោងទៀត ទើបបានដល់មាត់ស្ទឹង ? » ។ អ្នកភ្ជួរស្រែងើបមើលមុខ ហើយភ្ជួរស្រែតទៅទៀត ដោយគ្មាននិយាយអ្វីទាំងអស់ ។

អ្នកដំណើរឃើញដូច្នោះ ក៏ដើរទៅមុខទៀតដោយនឹកស្មានថា : « អ្នកគ្រូស្រែនោះ ប្រហែលជាមនុស្សគមិនចេះនិយាយ » ។ លុះអ្នកដំណើរ ដើរបានប្រហែលជាដប់ឬម្ភៃជំហាន ស្រាប់តែអ្នកគ្រូស្រែនោះស្រែកហៅឲ្យគេត្រឡប់មកវិញ ហើយនិយាយប្រាប់ថា : « បងឯងដើរពីនេះទៅដល់មាត់ស្ទឹង ប្រហែលជាមួយម៉ោងគត់ » ។

អ្នកដំណើរបែរខឹង ក៏សួរទៅវិញថា : « ចុះអំបាញ់មិញ ម្តេចក៏បងឯងមិនប្រាប់ខ្ញុំ? » ។ អ្នកគ្រូស្រែតបថា: «អំបាញ់មិញ បងឯងឈរនៅស្ងៀមមួយកន្លែង ហើយសួរខ្ញុំ ខ្ញុំមិនដឹងជាកម្លាំងបងឯងដើរលឿនឬដើរយឺតយ៉ាងណានឹងឆ្លើយឲ្យពាក់ត្រូវ, ដល់ខ្ញុំឃើញល្បឿនបងឯងដើរហើយ ទើបខ្ញុំឆ្លើយទៅឲ្យពាក់ត្រូវប្រាកដ កុំឲ្យបងឯងខឹងថាខ្ញុំនិយាយមិនចេះស្មាន » ។

ក្នុងករណីទាំងអស់ខាងលើនេះ យើងទាំងអស់គ្នាយល់ថា : តែរបៀបមិនច្បាស់ នាំឲ្យគេអ្នកស្តាប់ ក៏យល់មិនច្បាស់ដែរ តែគេអ្នកស្តាប់យល់មិនច្បាស់ ក៏នាំឲ្យការនិយាយទៅកាន់គ្នានោះ ក៏មិនបានសម្រេចដូចបំណង បានសេចក្តីថា : ការនិយាយឬការសួររបស់យើងនោះទាស់គ្នាហើយ មែនឬទេ ? ។

តាមធម្មតា ការនិយាយទាស់គ្នា មនុស្សយើងច្រើនតែដឹង, ប៉ុន្តែត្រង់ទាស់កន្លែងណា, ទាស់របៀបណា, ហេតុអ្វីបានជាទាស់គ្នា . . .

បើយើងពិចារណាតាមក្បួនតក្កវិជ្ជា ហើយយើងឃើញថា ក៏ខុសនឹងវិធាន នៃការរៀបចំគំនិតសម្រាប់និយាយ ។

យើងតាំងអស់គ្នាពិនិត្យមើល មានមនុស្សខ្លះ និយាយដោះសាថា

“ ព្រមុះបារាំងក៏គោង

ពូទៅ ព្រមុះគាត់គោង-

ហេតុនេះ ពូទៅ ជាជាតិបារាំង ” ។

និយាយដោះសាយ៉ាងនេះ តើត្រូវដូចម្ដេចកើត ? ដូចគ្នានឹងរបៀបដោះសា គ្មានប្រែកចេញនៃពួកទស្សនវិទូពីដើម ផ្នែកបស្ចិមប្រទេសខ្លះ ដែលជាពួកគំនិតនិយម ( Idéaliste ) ច្រើនយកឧទាហរណ៍ពីរឿងសូក្រាតថា :

“ ជនក្រិចជាមនុស្សករ

សូក្រាតជាជនក្រិចម្នាក់

ហេតុនេះ សូក្រាតជាមនុស្សករ ” ។ និយាយដោះសារបៀបនេះ បើពិត្រូវ ក៏ជាការហេងមួយហើយ ពីព្រោះនៅក្នុងករណីខាងលើ ក៏មានត្រូវខ្លះ ក៏មានខុសខ្លះ ព្រមុះគោង មិនមែនមានតែបារាំងទេ ដូចគ្នានឹងជនក្រិចគីបង់ដែរ មានជនក្រិចខ្លះករខ្លះមិនករ ក៏មិនករទាំងអស់គ្នាទេ ។

ឧបមាខ្លីជាថា : “ ខ្មែរកាន់ព្រះពុទ្ធសាសនា

ខ្ញុំមិនមែនជាខ្មែរ

ហេតុនេះ ខ្ញុំមិនមែនជាពុទ្ធសាសនិកជន ”

បើជួបនឹងគំនិតនិយាយបែបខាងលើនេះ កុំថាឡើយតែយើងជាអ្នកស្តាប់ សូម្បីតែខ្លួនគេជាអ្នកនិយាយនោះ ក៏គេស្តាប់ខ្លួនគេមិនបានដែរ ពីព្រោះនិយាយខុសទំនងវិធាននៃគំនិត បើយើងរៀនតក្កវិជ្ជា ទើបយើងយល់ច្បាស់ចំពោះប្រការនេះ ។

កាលណាគេមិនទាន់យល់ច្បាស់នូវវិធាននៃគំនិតទេ ទោះបើគេសួរមនុស្សដែលមានកំហុសហើយហ្នឹងក៏ដោយ ក៏អ្នកសួរ នៅតែក្លាយទៅបការជាងអ្នកដែលមានកំហុសនោះដែរ ។ ឧទាហរណ៍ដូចជា ម្តាយប្រើកូនឲ្យទៅយកសៀវភៅ នៅលើតុដែលឪពុកមិននៅ កូននោះរើកកាយសៀវភៅពាសពេញនៅលើតុ ដល់ឪពុកត្រឡប់មកវិញ សួរដឹងរឿងក៏ខឹងហើយហៅកូនមកបន្ទោសថា :

ហេតុម្តេចបានជាមករើកកាយសៀវភៅពាសពេញលើតុយ៉ាងនេះ?

កូន : ម៉ែប្រើខ្ញុំឲ្យយកសៀវភៅឲ្យគាត់ ។

ឪពុក : ចុះហេតុដូចម្តេច ក៏ឯងមិនចាំអញមកសិន ?

កូន : ម៉ែគាត់ប្រញាប់ពេក ចាំខ្ញុំមិនបាន ។

ឪពុក : ចុះបើម៉ែឯងប្រើឲ្យស៊ីអាចម៍ តើឯងស៊ីទេ ?

កូន : បាទ ! ប្រើឲ្យយកសៀវភៅ ហើយនិងប្រើឲ្យស៊ីអាចម៍ អាពីរនេះ ខុសគ្នាទេ ។

( នៅមានត )

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១២

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

និយាយតាំងតែពីព្រះបាទធរាដ្ឋ ក្រោយដែលបានតែងពិធីអាពាហ៍ពិពាហ៍ព្រះរាមរួចហើយ ក៏លើកយកពលវិលត្រឡប់ទៅនគរវិញ ប្រទះជួបនឹងកាមេសូរ ច្បាំងគ្នានឹង មេសូរ ១ ពាន់ វេហ្គគធិល់ទុរ៉ីនិងទូក ២ ស្លាប់ ទូរីទៅច្បាំងនឹងពាលី ១ សម្លាប់ទូរីស្លាប់ ។

លុះព្រះបាទធរាដ្ឋ មកដល់ប្រាសាទកែវហើយ ក៏មានព្រះឱង្ការ ប្រាប់ទៅនឹងសេនាជាធំថា ចូរភាត់ចែងរៀបពលសកលយោធាត្រៀមទុកឱ្យស្រេច ដ្បិតអញនឹងលើកទ័ពត្រឡប់ទៅកាំបូរីហោង ។ គ្រានោះ វិសេនាទាំង ៤ នាយ ទទួលព្រះឱង្ការហើយ ក៏ក្រាបថ្វាយបង្គំលា ការថយចេញមកចាត់ចែង តែងរេហ៍ពលសកលយោធា, ឱ្យអង្គសម្តេចព្រះពុមាអកោគារ យុំពល ទាហាន ៦ ម៉ឺនជាទ័ពស្រួចមុខ, រីពលនោះឱ្យស្លៀកពាក់អាវកម្ពុំពណ៌ផ្ទៃមេឃកាន់កាំភ្លើងប្រនេះថ្មុ, យោធា ៥ សែនជាគន់ទ័ពហ្លួង ពាក់អាវពណ៌ស៊ីម្ពូរ កាន់លំពែងនិងដាវដងវែង, ព្រះលក្ស្មណ៍និងព្រះស្រុទ្ធគុឌ្ឍជា ជាកងទ័ពបែកឆ្វេងស្តាំ មានពលយោធា ៤ ម៉ឺនសេ្រុគ្គា ពាក់អាវពណ៌ស៊ីច័ន្ទកាន់ធ្នូស្នា. ព្រះភិរុតបុត្តា កំពង

ជាកងទ័ពខាងក្រោយឲ្យការសត្រូវទាំងពួង ពេលទិងទាយ គឺកាយរៀប ឲ្យដើរខាងដើមជាគូមួយគូៗ រៀងទៅ, ពេល ៦ ម៉ឺនក៏ទ ពាក់អាវសុទ្ធសឹង តែពណ៌ស៊ីជម្ពូ កាន់លំពែងជាខែល ចងក្បាលមោពេមបាមរ ទាំងសេះទាំងដំរី រៀបរបៀបឲ្យដើរជាជួរៗ តាមតំណែងក្នាក់ងារទ្រង់មកជាអ្នកជិះ, មួយទៀត ពេលថ្មើរដើរជើង ក៏រៀបយតាមអណ្តាប់អណ្តាយគ្នាទៅហោង, ពេល ខាងព្រះបាទជនកាធិបតី ដែលព្រះអង្គទ្រង់ព្រះរាជទានពលជីតាទាំងស្រី ប្រុស ១ ម៉ឺន ៦ ពាន់នោះ ក៏រៀបកយឲ្យនៅសងខាងឆ្វេងស្តាំ ហើយ ក៏រៀបទាំងកងដំរីកែវពណ្ណកាយ រង់ចាំស្តេចនិងយាត្រាហោង ។

កាលណោះ ព្រះបាទធតរដ្ឋធិបតីនោះ លុះអស្តង្គតផុតសែងព្រះ សុរិយា ក្សត្រាក៏ចូលគាន់ទីព្រះបន្ទំភិរម្យព្រះទយា ព្រះអង្គក៏ត្រេកអរ ណាស់ ដ្បិតបានកូនប្រសាដូចចិត្តប្រាថ្នា ព្រះអង្គក៏ពេញស្រឡាញ់ លទ់ទឹងគណនាពុំបាន, ក្នុងវេលានោះ ព្រះអង្គទ្រង់ផ្ទំមិនលក់មែន ខែន ព្រោះព្រះអង្គទ្រង់ពឹងគិតតែទឹងត្រឡប់ទៅនគរវិញ, លុះពាលវែក ស្វាងអរុណរះឡើងហើយព្រះអង្គក៏ស្តេចតើនចាកទីបន្ទំ ក៏បបួលក្សត្រ ទាំង ៨ ទៅស្រង់ពរហោង ។ ពេលក់ងារក៏ថ្វាយព្រះសិទ្ធិសេចក្តីនាក ឲ្យស្តេចស្រង់ ។ ព្រះអង្គស្រង់ព្រះកាយវិច្ឆុះស្រេចហើយ ក្សត្រទាំង ៨ អង្គ ក៏ទ្រង់គ្រឿងក្បួនលម្អតាយពណ្ណកាយ តែរៀងកល់ព្រះអង្គ គប់ប្រដាប់ សម្រាប់តែងស្រេចកាលណាហើយ ស្តេចក៏យាងយាត្រាឡើងគង់លើ

ព្រះរាជរថ ហើយបង្គាប់ប្រាប់នាយសារថី ឲ្យគ្រវីទង់ជ័យបោកបក់ ជាកំណត់, ព្រះកុមារាធិបតីស្ញូវស្ញែងនោះ ក៏ស្ដេចឲ្យលើកយោធាទៅជា ទ័ពមុខហោង ៗ ទើបអង្គព្រះបាទធតរដ្ឋស្ដេចក៏កៀនយោធា ឲ្យគោះ គងខ្ទូងស្គរជ័យ យកឫក្សពារវេលាទាំង ចេញតាមសម្ដេចព្រះកុមារាធិបតីជា គ ១ គ្នា ទៅតាមផ្លូវមគ្គាគាំពនាល ៗ ក្នុងគ្រានោះ មានសត្វបក្សី ត្រចៀកកាំនៅក្នុងដៃកងជ័ បណ្ដាលទំនងឲ្យមានហេតុ ៗ សត្វនោះក៏ ហើរមក ហើយក៏ចាប់ឆក់ចឹកទង់ជ័យ ហើយក៏ហើរទៅខាងស្ដាំឲ្យឃើញ និមិត្តច្បាស់នឹងភ្នែក ហើយក៏ហើរទៅកាន់ព្រៃហិមវ័នវិញហោង ៗ

កាលណោះ ព្រះបាទធតរដ្ឋធិបតីនោះ លុះឃើញសត្វត្រចៀកកាំ នោះហើរមកចាប់ចឹកទង់ជ័យដូច្នោះ ទើបព្រះអង្គរំពឹងជញ្ជឹងគិតក្នុងព្រះ ទ័យថា ពីដើមមុនមក មិនដែលដូច្នេះសោះ ទោះតាំងទ័ពទៅកាន់ទៅ បានសួគាល័យក្ដី តាំងវសវិសាក្ដី សុទ្ធតែខ្លាចក្រែងបារមីអញទាំង អស់ ក្នុងគ្រានេះអស្ចារ្យណាស់ ប្រហែលនឹងមានពៅពួកពាលបច្ចាមិត្រ ទើបសត្វនោះហើរមកបណ្ដាលប្រាប់ហេតុអញហ្នះ, ព្រះភូមីទ្រង់រំពឹងគិត ហើយ ក៏នឹកតែឆ្ងល់សង្ស័យក្នុងព្រះទ័យណាស់ ទើបមានព្រះឧង្ការ ត្រាស់ឲ្យហៅហោរាមកទាយនិមិត្តហេតុនោះឲ្យដឹងប្រាកដ ។

គ្រានោះ សេនានោះបានស្ដាប់ព្រះឧង្ការហើយ ក៏ថ្វាយបង្គំលា ទៅស្រែកហៅ គាកគាកដាក់គាលាហល ៗ គ្រានោះ ឃុនហោរា-

ចារ្យនិងយាយចាស់ ជាប្តីប្រពន្ធមកនឹងគ្នាជាយូរយារហើយ គេទៀងដំដើរ នោះក៏មិនសូវដើរលឿនឡើយ ហើយក៏ដំមកជាមួយនឹងគ្នា ក៏និយាយ ចំអកចំអន់ឡកលេងនឹងគ្នាជាប្តីប្រពន្ធជាទីសប្បាយ សើចលេងក្អាកក្អាយ ហាស់ហាយហេហា, លុះបានឮសំឮសម្រែកគេស្រែកហៅថា សម្តេច ព្រះបមក្ខជឲ្យហៅក៏ភ័យក៏ត ហើយក៏ស្រវាចាប់យកគម្រាក្បួនគម្ពីរ ក៏មិន ឃើញសោះឡើយ ហើយក៏ថាអញទុកដាក់ត្រង់ហ្នឹង តើយាយចាស់ឯង យកទៅទុកឯណាបាត់, រីតាហោរានោះ ខំរាវរកគម្រម្ពីរវើកវិលវល់ ទំមតាម ១ ទៅ ក៏ពាល់តែក្អាត់ក្អាក់ពីក្បូងដំបុះមកដល់ដី ក៏ភ័យរលះ រលាំង ខំប្រឹងតាំងឈានឡើងទៅរកក្បួនគម្ពីរវិញ បានឃើញហើយ រត់ មិនទាន់ឈឺទាំងជា មកដោយប្រញាប់ ៗ

កាលណោះ ព្រះបាទធតរដ្ឋធិបតីនោះ ឃើញយុវហោរាចារ្យមក ដល់ហើយ ព្រះអង្គក៏និយាយកាយរឿងប្រាប់ទៅហោរាថា ម្នាលហោរ អើយ ចូរអ្នកទាយទំនាយនិមិត្តហេតុនោះឲ្យគិតប្រាកដ ព្រោះផ្សិតអាន សកុណាហោះមកធាបដកចិញ្ចៀនជ័យ ហើយហោះទៅកាន់ព្រៃពនាល័យ, អញសែនទួលនឹងហេតុហ្នឹងណាស់ ជាការបង្ក្រាដូចម្ដេចហ្ន៎ អ្នកហោរ?

គ្រានោះ តាហោរាចារ្យ បានស្តាប់ព្រះឱង្ការហើយ ថ្វាយបង្គំ ប្រណម្យវន្ទិយស្រេចហើយ ក៏តាំងពាក្យគ្រោះមើលក្នុងក្បួនពិជ័យសង្គ្រាម-យុទ្ធ តាំងយាមត្រីទូទិគ្តច័ក្រ តាមតិថីពេលវេលានាទីទៅ ទើបបាន

ដែនហេតុ ហើយក៏ក្រាបបង្គំទូលទៅតាមក្បួនតម្រាថា សត្វសកុណនេះ ត្រូវក្នុងតម្រាថា វាហើរមកពីទិសខាងត្បូងចំពោះប្រាកដ ថាត្រូវមានចាប់គ្រោះក្នុងវេលានេះ ហើយវាហើរទៅទិសខាងស្តាំវិញ ជានិមិត្តមានពួកពាឡបច្ចាមិត្រ មកបៀតបៀនបំណងរាយរ៉ាយ, តែក្នុងទំនាយទាយថា ព្រះអង្គនឹងត្រូវមានជ័យជំនះឈ្នះអស់សត្រូវ បើទុកជាសត្រូវនោះមានគ្នាច្រើន ដល់ទៅ ១ សែន ១ លានកោដិក្តី ឬក៏វាមកទាំងចក្រវាឡក្តី ក៏នឹងចាញ់រិទ្ធិបារមីព្រះអង្គះហោង ៗ មួយទៀត រីព្រះកិត្តិ-យសឈ្មោះនឹងឮល្បីទូទៅទាំងត្រៃលោកាហោង ៗ

កាលនោះ ព្រះបាទធតរដ្ឋរាជានោះ ទ្រង់បានស្តាប់ទំនាយហោរទាយព្យាករណ៍ហើយ ព្រះអង្គក៏ទ្រង់ក្រេមក្សាន្តសម្រាន្តព្រះទ័យ ទ្រង់ព្រះសម្រួល សើចញញឹមញញែមរីករាយ ទាំងស្រែកយកទៅកាន់អាយិ អគ្គមហេសីទាំង ៣ ផង ស្រេចហើយព្រះអង្គក៏ឲ្យគេនឹងពលសកលយោធី ដើរតាមផ្លូវក្នុងទីហោមកពទាល័យ លុះគន្លងផ្លូវព្រោះជ្រលងដងព្រៃព្រះជ្រៅមកបានបន្តិច ៗ

ទីនិសម្តែងពីកមេស្វរអសុរា ស្ថិតនៅក្នុងពិមានទេវតា ជាពាក់កណ្តាលភ្នំព្រះសុមេរុបព៌ត ក្នុងជាន់ចាតុម្មហារាជិកា ៗ អសុរានោះដ៏កោនកាច មានអំណាចមហិមា មានរៀងដូចក្អែងក្រុត គ្រាន់តែល្បីឮឈ្មោះវានោះ ក៏សឹងស្លុបស្លន់ក្រៃលែងសស្កាកណាស់ ហើយ

អសុរនោះក៏មានចិត្តអហង្ការ មិច្ឆាទិដ្ឋិប្រសព្វសាមាន្យ ក៏ស្រែកកងរន្ទ្រោន ត្រាច់ទៅតាំងព្រៃព្រឹក្ស ទោះតាំងពួកសុរយក្សមនុស្សវិជ្ជាធរសុបណ្ណគ្រុឌ ក៏កោតក្រែងខ្លាចអំណាចឥតអ្នកណានឹងក្លាហានតទល់បានឡើយ ។ ថ្ងៃមួយនោះ ក៏គិតចង់ចេញទៅប្រពាតលេងក្នុងព្រឹក្សពនាវេស គិតហើយ អសុរក៏តែងគ្រឿងរុងរឿងអលង្ការចេញដោយនូវទិព្វវេស្មា ក៏ធ្វើសង្ហាដូចព្រះបាទវេស្សវណ្ណ កុម្ភណ្ឌចាប់យកពូថៅពេជ្រ ហត្ថាម្ខាងកាន់ធ្នូសរជ័យ ស្រេចហើយនៃ ក៏ហោះចាកវិមានភ្លាម សម្ដែងសក្កតេជះ ហោះទៅកណ្ដាលកណ្ដាប់ពពកជ្រកស្រទាប់មេឃ ទៅដល់តែផ្ទៃដែននគរមិថិលាមហាបុរីហើយ អសុរក៏ចុះឈប់នៅនាជាយមាត់ព្រៃ ហើយអសុរី ក៏ត្រាច់យាត្រាដើរមើលអស់សត្វទ្វិបាទចតុប្បាទ ពងសីហានូវគជ-សារសិង្ហគោ ទូរគោគោត្រមហិង្សាសត្វសត្វនានា ទីងពណ៌នាពុំអស់ឡើយ ។ រីឯអសុរទ្ធិនោះ ក៏ដើរមើលរៀង ៗ ឆៀងខេត្រដោយមាគ៌ា លីលាលេងទតសត្វសត្វ ខំរុកកាត់ពនាល័យទៅបានបន្តិច ក៏សង្កាតគយគន់ លបទន្ទួលលួចមើលតាមប្រកបវត្តិនោះ ។ លុះឃើញពួកពលសកលយោធា តាំងពលរថរទេះសេះ ដំរី ឧដ្ឋ លា លើកមកគគ្រឹកគគ្រេងកក្រើកតាំងព្រះធរណី អសុរទ្ធិក៏យាត្រាចូលទៅ ដៃកាន់ពូថៅពេជ្រពណ្ណរាយ បង់ដៃនឹងឈរនៅកណ្ដាលពនាវេស ក៏សម្ដែងគេចដៃជាអ្នកក្លាហាន ហើយក៏ស្រែកប្រកាសប្រាប់ទៅថា អ៊ុយនៃ

អាមនុស្សព្រៃប៉ុនសត្វស្វា ហៅហ្វាយទាយអាឯង គេមាននាមករណ៍ឈ្មោះអ្វី ? មួយទៀត តម្បន់ស្ថានបុរីនៅស្រុកណា នគរណា ? ហើយនាំគ្នាមកក្នុងព្រៃនេះ រកប្រយោជន៍អ្វី ?

គ្រានោះ វីអស់ពួកពលទាំងពួង ទតព្រួចមុខនោះ លុះក្រឡេកមើលទៅឃើញកុម្ភយក្សអសុរនោះ មានរូបរាងធំក្រមហិមាដូច្នោះហើយ ក៏កើតភ័យញាប់ញ័រនូវសព្វស្ទិន ទាំងពលនាយក៏បែរចេញស្ពាំ ពេលនាព-ហានខ្លះ មានស្មារតីមិនស្លូតភ័យពេក ក៏ស្រែកតបទៅវិញ ថា ម្នាលអសុរ វីនាមករបស់ឈ្មោះសម្ដេចព្រះចក្រីនោះ ឈ្មោះហៅព្រះបាទធតរដ្ឋនរបតី ជាចមក្បាលពិនដាទីត្រៃលោកា ស្ដេចគ្រង់បុរីស្រីអយុធ្យាជាទី ព្រះអង្គលើកទ័ពយាត្រាទៅកែងការរក្សាមណ្ឌល គឺអង្គសម្ដេចព្រះរាមរាជនរេស ដែលលើកធ្នូសិល្បជ័យក្នុងបុរីមិថិលា ព្រះអង្គបាននាងសិតាហើយ ស្ដេចក៏នាំវិលទៅកាន់វៀងជ័យវិញ, ឯងមិនដឹងហេតុ ទើបបានមកសួររកនាមឈ្មោះធ្វើអ្វី ? រីឯបារមីព្រះរាមនរបតីនោះ ព្រះអង្គក៏ទ្រង់អានុភាពរីរើសេសណាស់ កុំមកអួតអាងកាន់ក្រញាំចង់តគេជាដៃ នឹងក្ស័យជីវិតពុំលែងឡើយ ។

កាលនោះ រីរាមេសូរយក្ស បានស្ដាប់ហើយ ក៏គ្រោធក្រេវក្រោធក្រញាំង ខឹងខាំមាត់ ហើយក៏ឆ្លើយតបទៅវិញ ដោយពាក្យពោលថា

ថែអាមនុស្ស អាឯងថា ម្ចាស់របស់ឯងនោះ ឈ្មោះកាមេសដ៏មានរិទ្ធិតេជ ដៃក្លាហាន អើថ្ងៃនេះហើយនឹងឃើញដៃគ្នា រីជីវិតដ៏កៅហ្វាយនាយឯង នោះ នឹងស្លាប់ពុំលែងនឹងដៃអញ រីឯខ្លួនអញនេះ ដូចជាព្រះកាល បណ្តាលមកបំផ្លាញប្រហារជីវិត ថាហើយអសុរិទ្ធិ ក៏គ្រវីធ្នូរសិល្ប ជ័យ តន្ត្រំព្រះបាទាសម្តែងនូវអំណាចដូចរាជសីហា អសុរក៏ស្ទុះផ្លោត លោតក្តូតចូលទៅសំពងកាយពលយោធាទាំងពួងហោង ។

គ្រានោះ រីអស់ពួកពលសកលយោធាទ័ពមុខនោះ ក៏ក្រែងស្ញែង រិទ្ធិអសុរ ភាំងប្រាជ្ញាទាំងចូលគ្នាដៃ ក៏ភ័យរត់ទៅទិសពាសទិសែ ញ័រជើង ដៃជ្រកពួនខ្លួនក្នុងអរញ្ញ ។ អសុរក៏ខ្ទឹំឃ្លាតសង្វាតក្រវេញ ហាក់ដូច កេសររាជសីហា ចូលដេញហ្វូងម្រឹគាហោង ។ គ្រានោះកាមេសូរ អសុរនោះ លុះដេញពលទៅដល់តែដល់មុខព្រះរាជរថគ្រុឌសុវណ្ណ កុម្ភណ្ឌ ក្រឡេកភ្នែកមើលទៅ ឃើញអង្គព្រះរាមា និងនាងសីតានង្គលក្សណ៍ សម្ផុរព្រះភ័ក្ត្រដូចទេពលេខា ទើបស្រែកទៅថា រុំយមនុស្សអហង្ការ ក្លាហាន ហើយហ៊ានទាំស្រីមកកាត់មុខអញ ហើយហ៊ានលើកខ្លួនឯង ជាឈ្មោះកម ឲ្យត្រូវនឹងនាមអញដ៏ជាធំក្រៃ រីតួខ្លួនឯងនេះ នឹងក្ស័យ ប្រល័យជន្ម ប្រពន្ធឯងនោះ អញនឹងនាំយកទៅឥឡូវនេះ ។

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( ៩ )

បំណងជើង " *សាស្ត្រា សិដ្ឋធាន* "

អ្នកនិពន្ធ *អម្បូតក្សត្រី "ម៉ុក"* (១)

កាលបរិច្ឆេទ *ព.ស. ២៤០៦ (គ.ស. ១៨៦៣) ។*

របៀបនិពន្ធ *ពាក្យកាព្យៈ បទកាកគតិតែ ១ ដល់ចប់ ។*

ប្រភពរឿង *បញ្ញាសជាតក ។*

លក្ខណៈឯកសារ *សាស្ត្រាស្លឹករឹត ២ ខ្សែចប់ ។ ខ្សែទី ១ មាន*

---

១— លោកអម្បូតក្សត្រី នាមដើមឈ្មោះ ម៉ុក នេះ ជាកវី មានថ្វីដៃ ១ រូប ក្នុងសម័យឧដុង្គ ។ លោកកវីម៉ុក បាននិពន្ធរឿង១ទៀត ហៅថា "រឿងទេវន្ទ" លោកបានស្រង់ប្រែសម្រួល អំពីគម្ពីរបញ្ញាសជាតកដែរ កាលពីឆ្នាំ ១៨៥៩ ។ លោកជាមន្ត្រី ១ រូប ក្នុងរាជ្យសម្ដេចព្រះវររាជជននី នៅចុងសម័យឧដុង្គមានជ័យ ។ កាលនោះ សម្ដេចព្រះវររាជ-ជននី កំពុងទ្រង់ផ្ដើមសាងសង់ព្រះវិហារផ្សេង ៗ មានព្រះវិហារអដ្ឋារសជាដើម នៅភ្នំព្រះរាជទ្រព្យ ។ ទ្រង់មានព្រះសវនីយត្រាស់ប្រើលោកឲ្យនិពន្ធរឿងព្រះសិង្ហនាទ ព្រមទាំងប្រោសប្រទានងារជាឧកញ៉ាអម្បូតក្សត្រី ត្រាស់ប្រើឲ្យឧកញ៉ា សេនីយេ ជួយចម្លងផង ។

កវីនេះ មានលក្ខណៈប្លែកពីកវីដទៃ ៗ គឺចូលចិត្តនិយមប្រើតែពាក្យកាព្យ១បទរហូតដល់ចប់រឿង ទោះបីជារឿងវែងយ៉ាងណាក្ដី ។ល។

៣៥ សន្លឹក, ខ្សែទី ២ មាន ៣៧ សន្លឹក ។ ឯកសារនេះ

ពុទ្ធសាសនបណ្ឌិត្យបានចារចម្លងតាមច្បាប់វត្តហារខេត្តកណ្ដាល

កាលពីឆ្នាំមមែបញ្ចស័ក ត្រូវនឹងថ្ងៃទី ៣ វិច្ឆិកា ១៩៤៣

ចុះលេខ ១.៣៧៩ ។

អត្ថបទផ្ដើម: នមោនមា នមស្សិត្វា ពុទ្ធត្ថំ គមោនុទំ លោក-

នាថំ នាថេវរំ វរញ្ញាណា ។ អញ្ញខ្ញុំគោរព ព្រះម្កុដ

លើសលុប លើសលែងលោកា លោកនាថំ វរញ្ញាណា

ប្រសើរជាតិជា ទីពំនឹងនិត្យ ។ គមោនុទំ មោហតណ្ហំ

ព្រះអង្គអាចបំទ អាចបាំងតណ្ហា មោហាផ្លូវផិត ផ្លូវជាតិមិន

ផិត មិនដល់ព្រះអង្គ . . . . . ។ល។

អត្ថបទបញ្ចប់: សង្ហនាទំ សុជាតកំ ចនិដ្ឋគោ និទានអំពី ពោធិ-

វរេ វរលោកុត្តមោ វរលក្ខណ៍ថ្លៃថ្លា ។ អន្ទោលយកជាតិ

ជាព្រះសង្ហនាទ នៅគន្ថបញ្ញាស-សជាតកកត់ ដោយបទគាថា

បរិបូណ៌ចូលជា ខ្សែពីរស្រេចហោង ។

បំណងជើង "សាស្ត្រា មង្គលសូត្រ[១]"

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យ៧ កម្រងកែវ លំនាំទេសនា ។

ប្រភពរឿង មង្គលសូត្រ លទ្ធិពុទ្ធនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ២ ខ្សែ ។ ខ្សែទី ១ មាន ៣៦ សន្លឹក, ខ្សែទី ២ មាន ៣១ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកពីវត្តព្រែកថ្លឹង ចុះលេខ ១៣៨៧ ។

អត្ថបទផ្ដើម: វេលានេះ នឹងសំដែងក្នុងមង្គល ៣៨ ប្រការ ដោយ យ៉ ។ ជាខវត្តប្រតិបត្តិ ថាតាមបាលីអដ្ឋកថា នូវវោហារ ឲ្យ សមគួរនឹងសតិបញ្ញា ស្មារតីប្រុសស្រីទាំងពួង ដែលមានមនោ-សទ្ធា នឹងចង់បានឲ្យជឹងឆ្ងាយ នឹងរាយស្ដាប់ ហើយ

---

១– សាស្ត្រានេះ តាមឯកសារដើម ដាក់បំណងជើងថា "សេចក្ដីពហូសូត្រ" ឈ្មោះទៅវិញ ប្រហែលជាអ្នកចារចម្លងភ័ន្តច្រឡំទេ ព្រោះផ្នែកអត្ថបទទាំងមូល ថ្លែងអំពីមង្គល ៣៨ ប្រការ ប៉ុណ្ណោះ ។ ក្នុងទីនេះ បានកែតម្រូវតាមអត្ថបទ ។

អធិប្បាយតាមដំណើរថា :

ឯកសម័យ គ្រាមួយនោះ សម្ដេចព្រះបរមសាស្ដាចារ្យ ចរិយាវត្ត ព្រះអង្គស្ដេចគង់នៅ ក្នុងព្រះជេតពន មហាវិហារ ដែលអនាថបិណ្ឌិកសាងថ្វាយ ពុំឆ្ងាយអំពីក្រុងសាវត្ថី ។ល។

**អត្ថបទបញ្ចប់:** មង្គល ៣៨ ប្រការ ចូរខំស្វាហ៍តាំងចិត្ត ខំប្រព្រឹត្ត ឲ្យបរិសុទ្ធបរិបូណ៌ ក្នុងខន្ធសន្តាន គង់នឹងបានសេចក្ដីសុខ សិរីសួស្ដីវិវឌ្ឍនមង្គលចំរើនសុខក្សេមក្សាន្ត បានផលគ្រប់ទិវារាត្រី ដូចខ្ញុំព្រះករុណាវិសជ្ជនាមកដូច្នេះ ចប់មង្គល ៣៨ ប្រការ ដោយយ៉ ៗ ខ្លី ៗ ជាខន្តីប្រតិបត្តិ ផ្លូវបព្វជិតនូវគ្រហស្ថ ដែលសិក្សាតាមផ្លូវលោកិយ ទាំងផ្លូវបរលោក បាននាំនិពានឲ្យ បានចំរើន នូវប្រាជ្ញាសាធុជន ។ បើមិនទាន់បានសម្រេច នូវមគ្គផល គង់នឹងលើកខ្លួនតំកល់ ឲ្យផុតពីអបាយភូមិ ដោយអំណាចប្រព្រឹត្ត នូវមង្គលទាំងឡាយ ដូចបានអធិប្បាយមកនេះ ។ សូមសេចក្ដីចំរើនបូរមានដល់អ្នក ដែលបានមើល ស្ដាប់គ្រប់ទិវារាត្រី ចប់មង្គល ៣៨ ប្រការតែប៉ុណ្ណេះ ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

នូ-កាន

ប្រែរៀបរៀង

( គ )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាតបើបានអាន
នឹងចេះឧបាយកលចំណាន — ទាំងមានសន្តានស្នេហាជាតិ

យូរ—អ៊ុន

ង៉ឺអាយ ដែលជានាយគុយុំពេទ្យហ៊ូតោ ដឹងថា ហ៊ូតោជាគ្រូពេទ្យចេះយ៉ាងពូកែ ក៏ប្រតិបត្តិគោរព ជូនស្រា បាយ មានសាច់ជ្រូក-មាន់-ទា ឲ្យបរិភោគគ្រប់ពេលពុំដែលដាច់ៗ ពេទ្យហ៊ូតោ មានកតញ្ញូតា ដឹងគុណគុយុំ ក៏និយាយថា ខ្ញុំនេះមុខជានឹងស្លាប់ប្រាកដហើយ ខ្ញុំមិនមានរបស់អ្វីនឹងតបស្នងសងគុណនាយទេ ខ្ញុំមានតែវិជ្ជាការខាងពេទ្យល្អណាស់ ខ្ញុំក៏មិនទាន់បានប្រាប់កូនសិស្សណាទៅឡើយ, ចូរអ្នកយកសំបុត្ររបស់ខ្ញុំនេះ ទៅឲ្យភរិយាខ្ញុំ យកតម្រាពីផ្ទះមក ខ្ញុំនឹងចង្អុលបំភ្លឺឲ្យយល់ទាល់តែអស់ គុយុំបានឮដូច្នោះ ក៏មានអំណរណាស់ និយាយថា ខ្ញុំបាទបានវិជ្ជាការពេទ្យរបស់លោកហើយ ខ្ញុំបាទមិនធ្វើការគេទៅទៀតឡើយ នឹងធ្វើការខាងពេទ្យ រក្សារោគឲ្យល្បីឮខ្ទរទៅ ដើម្បីនឹងយករង្វាន់ខាន់ទៅ ថ្លៃសារពើថ្នាំចិញ្ចឹមជីវិតអាត្មាប្រសើរជាង ។

ហ្គិគោ ក៏សរសេរសំបុត្រឲ្យកូយុំ ៗ ក៏នាំយកសំបុត្រទៅឯតំបន់ កូមិតិមសៀ ជូនទៅភរិយាហ្គិគោ ៗ ភរិយាហ្គិគោក៏ប្រគល់គម្រោរបស់ប្ដី តាមសំបុត្រនោះមកឲ្យកូយុំ ៗ បានគម្រោនោះហើយ ក៏យកទៅឲ្យហ្គិគោ ៗ ក៏បន្ទុលបំភ័ក្រប្រាប់វិជ្ជាពេទ្យ ដល់កូយុំនោះ លុះគ្រាតែបានដឹងស្គាល់យល់គ្រប់ប្រការ ហើយក៏ប្រគល់គម្រោនោះឲ្យទៅកូយុំទាំងអស់, កូយុំបានគម្រោនោះហើយ ក៏មានចិត្តត្រេកអរពេកប្រមាណ បានយកគម្រោនោះទៅទុកក្នុងទីលំនៅ, លុះគង់យូរទៅ ពេទ្យហ្គិគោ ក៏ធ្វើកាលកិរិយាក្ស័យជីវិតក្នុងគុកនោះទៅ ៗ កូយុំក៏ឲ្យមន្ត្រីភាក់ងារនាំយកសេចក្ដីទៅទូលព្រះចៅវុយអង់ថា ពេទ្យហ្គិគោស្លាប់ហើយ, កូយុំក៏តាក់តែងគ្រឿងសែនព្រេន នាំសពពេទ្យហ្គិគោទៅបញ្ចុះតាមទំនៀម ៗ

ឯភរិយាកូយុំ ឃើញគម្រោក៏គិតថា ត្រូវការអ្វីនឹងក្បួនគម្រោនោះទុក, គ្រូដែលថាវិសេសណាស់ ម្ដេចក៏ស្លាប់ក្នុងគុក, បើប្ដីអញយកទុកក៏គង់តែដូចគ្នា ៗ គិតហើយ ក៏យកគម្រោនោះ ទៅដុតភ្លើងអស់ទៅ ៗ វេលានោះ ទទួលកូយុំទៅផ្ទះ ក្រឡេកឃើញភរិយាយកគម្រោទៅដុតភ្លើងដូច្នោះ ក៏ស្ទុះទៅដណ្ដើមបាន ២-៣ សន្លឹក; ក្រៅអំពីនោះក៏ឆេះអស់ ៗ កូយុំខឹងណាស់ ស្រែកជេរភរិយា ហើយថា ហេតុម្ដេចបានជាហ៊ានឯងយកគម្រោអញទៅដុតភ្លើងបំផ្លាញ ? ប្រពន្ធឆ្លើយថា បើហ្គិគោគ្រូអ្នកឯងវិសេសណាស់ ម្ដេចក៏ស្លាប់ក្នុងគុក, អ្នកឯងយក

តម្រានោះទុកប្រយោជន៍អ្វី? ឯកូប៉ុំនោះភាល់គំនិត ក៏អង្គុយកើតទុក្ខ ស្តាយតម្រានោះពន់ប្រមាណណាស់ បេះតែដកដង្ហើមធំ ហើយគិតថា សំណោះពីថ្ងៃនេះទៅ តម្រាវិសេសយ៉ាងនេះអស់មានហើយ, ឯសទ្វឹក ដែលយកបាននោះ បានតែបែបមើល ជ្រូក, មាន់, ទា, ប៉ុណ្ណោះ ។

ខណៈនោះ ឯចូចូដែលមានកេតឈើក្នុងក្បាល ក៏បណ្តាលឲ្យកើត ចាប់ធ្ងន់ឡើង ៗ ហើយព្រួយតែក្ក ក្រែងកងទ័ពស្រុកគាំងគាំងនិងស្រុក សែឈួន លើកមកធ្វើអន្តរាយ មានបំរើស៊ើបការណ៍ចូលទៅទូលថា ស៊ិនគួនស្រុកគាំងគាំង មានសំបុត្រមកដល់; ចូចូក៏ឲ្យហៅអ្នកកាន់ សំបុត្រនោះចូលទៅ ហើយយកសំបុត្រនោះទៅមើល ឃើញសេចក្តីថា ខ្ញុំបាទស៊ិនគួន មានចិត្តស្វាមីភក្តិចូលមកជ្រកកោនពឹងបុណ្យសម្ភារ ព្រះ ចៅវុយអង់តទៅ, ឯបណ្តាអាណាខេត្តទាំងពួង ក៏ឡើងទ្រង់អស់ហើយ ឃើញនៅសល់តែស្រុកសែឈួន និងស្រុកគាំងពួនប៉ុណ្ណោះ ហេតុនេះ សុំឲ្យទ្រង់លើកទ័ពទៅកំទេចទៀតចុះ មុខជាបានដោយងាយ ៗ

ចូចូបានស្តាប់ ក៏អស់សំណើច ហើយថា មើលចុះស៊ិនគួន វា បញ្ឆោតយើង ឲ្យដើរជាន់លើគំនរភ្លើង ហើយទ៏ប្រើក្បាម្នាក់ឈ្មោះគាន់កុន ឆ្លើយថា ផែនដីព្រះចៅហៀនតេ ក៏វៀរពេលមកយូរណាស់ហើយ; គ្រា នេះ អាស្រ័យដោយព្រះតេជព្រះគុណទ្រង់ ទើបបានបរិបូណ៌មាំមួន ឡើង អស់អាណាប្រជារាស្ត្រ ក៏បានប្រកបសុខក្សេមក្សាន្ត ដោយ

សារបានផ្ដកម្មប់ព្រះបរមពោធិសម្ភារបារមី ហើយមានតាំងសេចក្ដីស្ម័គ្រ ស្រឡាញ់ព្រះអង្គខ្លាំងណាស់, ឯស៊ិនគួននេះ ក៏បន្ទាបខ្លួនចូលមកពឹងបុណ្យព្រះអង្គដោយត្រង់ហើយ គួរតែទ្រង់ទីងឡើងសោយរាជ្យជាអម្ចាស់ផែនដីវៀតញទៅ ។

ចូឆូពូជូបោះ ក៏សើចសំណើច ហើយថា យើងបានទំនុកបំរុងផែនដីរបស់ព្រះចៅហៀនគេមក សឹកសត្រូវក៏បាក់បាក់ ក្រស្ដុតាសក៏បានសេចក្ដីសុខក្សេមក្សាន្តមកយូរហើយ ព្រោះគំនិតរបស់យើង ។ ក៏បានសម្រេចការ ជាធំបំផុតលើសអស់មុខមន្ត្រីតាំងឡាយ មិនមាននរណាទីងស្មើផល់ បើយើងតាំងខ្លួនជាម្ចាស់ផែនដី ផ្ទឹមនឹងព្រះចៅហៀនគេ ក៏ដូចជាមិនសមគួរ យើងត្រូវធ្វើកែលម្អមើលដូចដាវប៉ូអងដែលធ្វើការទុកឲ្យកូនប្រុសរបស់ខ្លួនប៉ុណ្ណោះក៏បាន ។ សុម៉ាគុីថា ចុះបើវេលានេះ ស៊ិនគួនបានព្រមចំណុះចូលមកជាខ្ញុំទ្រង់ហើយ គួរតែទ្រង់នឹងតាំងលើកស៊ិនគួនជាទីនាម៉ឺនធំ ដើម្បីជាពួកក្រុមរបស់យើង បំរុងទុកឲ្យចាំស្កាត់ទ័ពទៀត ។ ព្រះចៅហ្វុយកង៍យល់ឃើញត្រូវ ទើបតែងត្រាតាំងស៊ិនគួនជាចៅហ្វាយស្រុកកេងជីវ ហើយចាត់បំរើឲ្យនាំត្រាតាំងចេញទៅប្រគល់ស្រុកកេងជីវឲ្យស៊ិនគួន ។

ចំណែកខុមចូឆូ កេតបណ្ដាលការនែតខ្លាំងឡើង ក្នុងថ្ងៃមួយនោះ ចូឆូយល់សប្ដិឃើញថា សេះ ៣ ស៊ីស្មៅក្នុងកេងជាមួយគ្នា លុះព្រឹក

ឡើង ក៏ពណ៌នាយល់សប្តិនោះឲ្យវិប្រក្សាទាំងពួងស្តាប់ហើយថា កាល
គ្រា ម៉ាថេង, ម៉ាហ៊ុរ ម៉ាថៀត ៣ នាក់អាពុកនិងកូនគិតប្រទូសរ៉ាយ
នឹងយើង ៗ ក៏យល់សប្តិឃើញយ៉ាងនេះដែរ ហើយយើងបានកំចាត់
បញ្ចេញអស់ហើយ, ឥឡូវយល់សប្តិឃើញដូច្នេះទៀត តើនឹងអាក្រក់ល្អ
ឬការម្តេច ? ការសៀងទូលថា ទូលបង្គំពិគ្រោះឃើញលក្ខណៈយល់
សប្តិនេះល្អណាស់ មុខហាក់ដូចជានឹងមានបុណ្យឡើងទៀត ទ្រង់កុំព្រួយ
តក្កពេកឡើយ ៗ ចូចូឮដូច្នោះ ក៏គ្មានសេចក្តីកាលសង្ស័យសោះ ។

លុះថ្ងៃមួយនោះ ពេលកណ្តាលយប់ ចូចូឈឺក្បាលណាស់ ខេះ
តក្តៅក្រហល់ក្រហាយដេកមិនលក់សោះ លុះដល់ពេលយាម ៣ ក៏
ក្រោកចេញទៅអង្គុយ នៅលើកៅអីខាងលើល្វែងក្រៅ បានឮសម្លេងបង្គួច
ក៏គៅហែកព្រៃ បែរក្រឡេកមើលទៅ ស្រាប់តែឃើញព្រះនាងហុកហោ
នឹងព្រះកជនរសទាំង ២ ហើយនិងហុកអ៊ួនបិតាព្រះនាងហុកហោ នូវ
ហ៊ាងស៊ុនបិតានាងតាំងកុយហ៊ុយ នូវអស់ស្រីគ្រប់គ្នាពួកប្រហែល ២០ នាក់
កនឈាមហូរប្រឡាក់ក្រហមពេញអស់ទាំងខ្លួន ឈរនៅលើអាកាស
ហើយថា ចូចូអើយ ! អ្នកឯងយកអាយុជីវិតមកឲ្យយើងវិញ ៗ ចូចូ
ក៏ត្រាក់ក្រប៊ីកាប់ទៅត្រង់មាត់ទ្វារ ហើយក៏ឲ្យក្រវល់ក្រវាយខ្លាំងណាស់
ម៉ាំងក៏អស់ដួលចុះក្នុងទីនោះ ៗ បណ្តាមនុស្សម្នាដែលបំរើថែទាំ ក៏
នាំគ្នាគ្រាហ៍លើកចូចូទៅឲ្យនៅក្នុងដំណាក់ដដែល, លុះនៅមកក្នុងថ្ងៃមួយ

នោះ ពេលកណ្ដាលយប់ ចូចូដេកមិនលក់សោះ ចេះតែឮសម្លេងខ្មោចបិសាចទាំងស្រីទាំងប្រុស ស្រែកយំឮទ្រហឹងអឺងកងពាល់តែភូ, លុះព្រឹកឡើង ចូចូឲ្យប្រជុំនាម៉ឺនមុខមន្ត្រីទាំងពួងមកព្រមគ្នាហើយ និយាយថា យើងបានធ្វើសឹកសង្គ្រាមជាយូរលង់ តាំងពី ៣០ ប្លាយឆ្នាំមកហើយ មិនដែលបានឮសម្លេងខ្មោចបិសាច មកស្រែកយំឲ្យប្រាកដដូច្នេះឡើយ វេលានេះ មានខ្មោចបិសាចមកលងបន្លាច ស្រែកយំឮទ្រហឹងអឹងកងជាចំឡែកពេកណាស់ តើនឹងមានហេតុភេទដូចម្ដេច ?

ឯនាម៉ឺនទាំងពួងក៏ទូលថា សូមឲ្យទ្រង់រកគ្រូហ្មងខ្មោចបិសាចមកសៀនសែនពលិការ តាមរបៀបបុរាណ មិនយូរប៉ុន្មានគង់នឹងបាត់ ៗ ចូចូដេកផ្ងើមធំ ហើយថា បុរាណមាននិយាយទុកមកថា កម្មអកុសលមកដល់ខ្លួនហើយ ទោះនឹងដោះស្រាយប្រការម្ដេច ក៏មិនផុតពីសេចក្ដីស្លាប់បាន, ឥឡូវ បើកម្មមកដល់ហើយ ក្រៅស្លាប់ក៏គ្មានទីណានឹងជួយបាន ចូចូ ក៏មិនបានសៀនសែនខ្មោច, រំលងមកក្នុងថ្ងៃមួយនោះពេក ក៏កាន់តែកម្រើកឡើងធ្ងន់ជាងពីដើម ចេះតែល្វឹងល្វើយទន់ទៅ ៗ ទើបឲ្យហៅហៃហ្វ៊ីទុនចូលមក ៗ

ឯហៃហ្វ៊ីទុន មកដល់ទ្វារវាំង ក្រឡេកទៅឃើញព្រះនាងហុកហៅនាងតាំងក៊ុយហ៊ុយនិងព្រះរាជបុត្រទាំង ២ ហើយនិងហុកអ៊្វិន, តាំងស៊ុននូវស្ម័គ្របក្សពួកឈរពីមុខលងបន្លាចជាខ្មោចស្រស់ៗ, ហៃហ្វ៊ីទុន ក៏ដួល

សន្ទប់នៅទី នោះ, ពួកបារាំងក៏នាំគ្នាគ្រោហ៍លើកទៅឯផ្ទះវិញ, ហៃហ៊ួទុន ក៏ចាប់ផ្ដើមឈឺជាប់ព្រោះបិសាច ៗ ចូចូក៏ឲ្យហៅ ចូហង, តាន់កុយ, កាសៀង, សុម៉ាអ៊ី ឲ្យចូលទៅដល់គ្រែដំណេកខាងក្នុង ទើបនិយាយផ្ដាំផ្ញើបុត្រភរិយានិងស្រុកទេស ការពារការ ទឹកដី ឲ្យបណ្ដាមុខមន្ត្រីធំទាំង ៤ នាក់នោះ ៗ មន្ត្រីទាំងនោះ ក៏ទូលថា ព្រះរោគនេះ មិនជាទម្ងន់ប៉ុន្មានទេ គង់តែមើលទៅជាវិញ ៗ

ចូចូថា: យើងបានធ្វើការរណាង្គសង្គ្រាម លើសជាង ៣០ ឆ្នាំ ហើយ សត្រូវទាំងប៉ុន្មាន យើងក៏បានបង្ក្រាបឲ្យរាបទាបអស់ហើយ ផែនដីសព្វថ្ងៃ ក៏បានសេចក្ដីសុខក្សេមក្សាន្តទាំងអស់ ឃើញនៅចន្លោះតែស្រុកកាំងតាំង និងស្រុកសែឈួន ដែលស៊ុនគួន និងឡៅពីឈរជាធំ យើងបង្ក្រាបពុំទាន់បាន, ឥឡូវជម្ងឺក្នុងប្រាណ ក៏កាន់តែធ្ងន់ណាស់ទៅហើយ ដែលនឹងសង្ឃឹមឲ្យបានទៅជាកៀន ធ្វើការសង្គ្រាមតទៅជាមួយគ្នាទៀតពុំបានឡើយ, ហេតុនេះ យើងសូមផ្ដាំផ្ញើការធុរៈផែនដីនេះឲ្យអស់អ្នកទាំងឡាយ ចូរជួយយកចិត្តទុកដាក់ពិភក្ដិរក្សាតាមការផងចុះ កូនប្រុសរបស់យើងមួយឈ្មោះចូផាំង, កើតពីនាងឡៅស៊ី ក៏ទទួលអនិច្ចកម្មក្នុងស្រុកអ៊ួនសៀទៅហើយ, នៅតែកូន ៤ នាក់ ដែលកើតពីនាងពៀនស៊ី ឈ្មោះ ចូភី ១, ចូចៀង ១, ចូស៊ិត ១, ចូហ៊ឹម ១, យើងព្រួយវិតក្កណាស់នឹងចូស៊ិតនោះ ព្រោះកូនមួយនេះសំដីមិនមាំទាំត្រង់ណាសោះ

រមែងស្រវឹងស្រា នឹងកាន់ការមិនខ្ជាប់ខ្ជួន បើនឹងតាំងជាជំនួយខ្លួនយើងក៏ពុំបាន, ឯចូវចៀងនោះ វាជាមនុស្សមានកម្លាំងពលំក៏មែន តែថាមិនស្លូតបេះគិតតែការស៊ីសោះ, ចូហ៊ុមនោះ វាជាមនុស្សលោភទ្រព្យសម្បត្តិ, ដែលនឹងឃើញគំនិតមារយាទមធ្យ័ត តែចូភីជាបុត្រច្បង មានប្រាជ្ញាក្នុងលើសឯទៀត ព្រមទាំងសេចក្តីឆ្លៀវឆ្លាតវាងវៃជាងគេ បើនឹងផ្ទុកផ្ទេរការពារការឲ្យជាជំនួសខ្លួនយើងក៏បាន បើប្រសិនជាយើងអស់បុណ្យក័ព្វវាសនាទៅហើយ អ្នកទាំងឡាយ ចូរជួយអនុគ្រោះតាំងចូភីនោះ ឲ្យស្ដីទីរាជការជំនួសយើងតទៅចុះ ។

ខណៈនោះ ចូហាង, គាទកុយ, គាសៀង, សុមាគ៊ុ បានឮចូឆ្ចូថា ជាពាក្យបណ្ដាំសព្វគ្រប់ដូច្នោះ ក៏នាំគ្នាសោកាល័យសង្រែងសង្រេងរង្គើងស្មារតី មន្ត្រីទាំងនោះក៏នាំគ្នាថយចេញមកវិញ ។ ចូឆ្ចូក៏ឲ្យបំរើយកឈើក្រអូបយ៉ាងល្អឈ្មោះបេងបៀងមកចែកឲ្យភរិយាទាំងពួង ហើយក៏ផ្ដាំប្រដៅថា បើយើងអស់បុណ្យវាសនាហើយ នាងរាល់គ្នាចូរទុកស្បាហ៍យកចិត្តទុកដាក់ ហ្វឹកហាត់ក្នុងការដេរប៉ាក់ក្រឹប ជារបរចិញ្ចឹមជីវិតទៅថ្ងៃមុខ នាងចូរនាំគ្នាទៅនៅលើប្រាសាទតាំងសេិតតៃ ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ក)

លោក ឌឹក-គាម ប្រមូលរៀបរៀង

វិទ្យុទេសនា : កណ្ឌទី ១ ព្រះតេជព្រះគុណព្រះសាក្យវង្សគ្រូបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់ ទ.ក. ៧, ទំព័រ ៣, ឆ្នាំ ១៩៤២, (ម ៥២/១៤) ។

កណ្ឌទី ២ : ព្រះតេជព្រះគុណព្រះសិរីសម្មត្តិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ទ.ក. ៨, ទំព័រ ៣, ឆ្នាំ ១៩៤២, (ម.២៥/១៤) ។

កណ្ឌទី ៣ : ព្រះតេជគុណព្រះពុទ្ធឃោសាចារ្យ (ជ-ណាត) ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ទ.ក. ៩, ទំព័រ ៣, ឆ្នាំ ១៩៤២, (ម.២៥/១៤) ។

កណ្ឌទី ៤ : ព្រះបាឡាត់ឃោសនាគ ហ-ទៀវ ទ.ក. ១០, ទំព័រ ៣, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

កណ្ឌទី ៥ : លោកគ្រូអាចារ្យ ម៉ុញ-ណាគ្រី ទ.ក. ១១-១២, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ៦ : សាឌុម ទ.ក. ១៣-១៤, ទំព័រ ១, ឆ្នាំ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ៧ : ព្រះគ្រូមុនីសុមេធ (កេត បិតសីលោ)

ទ.ក. ១៥-១៦, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ៨ : . . . . . .

កណ្ឌទី ៩ លោកអាចារ្យ យូរ - អ៊ុន ទ.ក. ១៧ - ១៨, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ១០ : លោកអាចារ្យ ញូន - សឿន ទ.ក. ១៩-២០, ទំព័រ ១, ឆ្នាំ ១៩៤២, (ម ៥២/១៤) ។

កណ្ឌទី ១២ : លោកគ្រូអាចារ្យ ពាន់ - សុខ ទ.ក ២១ - ២២, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ១៣ : ព្រះគ្រូវិនយធម្ម ហ៊ុ - ជា ទ.ក. ២៣-២៤, ទំព័រ ១, ឆ្នាំ ១៩៤២., (ម.៥២/១៤) ។

កណ្ឌទី ១៥ : លោកអាចារ្យ កៅ - ស៊ុម ទ.ក. ១-២-៣, ទំព័រ ១, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

កណ្ឌទី ១៦ : លោកអាចារ្យ ឈឹម - ស៊ុំ ទ.ក. ១-២-៣, ទំព័រ ១៦, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

កណ្ឌទី ១៧ : ព្រះមហា សោម - ឡុប ទ.ក. ១ - ២-៣, ទំព័រ ២៧, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

ការសំអាត : ព្រះវិសុទ្ធវង្ស ហួត - តាត ទ.ក. ៧-៨-៩, ទំព័រ ១១១, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

វិធីគុបតែងព្រះពុទ្ធសាសនា ឲ្យចំរើន នៅក្នុងឯកៈ កម្ពុជា : ជី គឹម-ហាក់ ទ.ក ១១, ទំព័រ ៤៧, ឆ្នាំ ១៩៣០, (ម.៥២/៣) ។

វិធីធ្វើចំការច្បារដំណាំ : អ្នកស្រែម្នាក់ ទ.ក. ២០, ទំព័រ ១២, ឆ្នាំ ១៩៤១, (ម ៥២/១៣) ។

វិធីធ្វើក្រដាសដោយដៃ នៅប្រទេសលាវ : ទ.ក. ១៥, ទំព័រ ៣, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

វិធីបង្កាត់ពូជក្នុងកិច្ចការសម្រាលកូន : ព្រះមហា ឈឹម-ក្រសេម ទ.ក. ១-២.៣ ទំព័រ ៣៥, ឆ្នាំ ១៩៣៧ (ម.៥២/៩) ។

វិធីបង្ការរោគ : ដុកទ័រឡូរង្ស ទ.ក. ១-២.៣. ទំព័រ ១៩, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

វិធីរក្សាកក : ទ.ក. ២-៣, ទំព័រ ៥៨ ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

វិធីរក្សារាងកាយ : ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ទ.ក. ៥, ទំព័រ ២២៥, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

វិធីរាប់ថ្ងៃ-ខែ-ឆ្នាំ-រដូវ (កាព្យ) : ព្រះគ្រូញាណ-សំវរ ញាណ-ឈឺន ទ.ក. ២, ទំព័រ ៩៥, ឆ្នាំ ១៩៤៦, (ម.៥២/១៨) ។

វិធីសម្រាលកូន : ទ.ក. ៤-៥-៦, ទំព័រ ៤៥, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

វិធីសាងសំឡេង : លោកអាចារ្យ សេ - កោ ទ.ក. ៩, ទំព័រ ៤៤៩, ឆ្នាំ ១៩៤៧ (ម.៥២/១៩)

វិធីអប់រំចិត្ត : លោក ស៊ុន - ហ៊ាន ទ.ក. ៩, ទំព័រ ៦៤៣, ឆ្នាំ ១៩៥៤, (ម.៥២/២៦) ។

វិធីអប់រំជនជាតិខ្មែរ : លោក ក៏យ - ប៊ុក ទ.ក. ៧, ទំព័រ ៦៥១, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

វិធុរជាតក : ទ.ក. ២, ទំព័រ ១៣៤, ឆ្នាំ ១៩៦៤, (ម ៥២/៣៦) ។

វិជយកថា : ព្រះបាឡាត់អរិយកស្សប គុង - ឈួន ទ.ក. ៩, ទំព័រ ៦៤៣, ឆ្នាំ ១៩៥១, (ម ៥២/២៣) ។

វិន័យនិងការប្រតិបត្តិ : លោក គិត - ពិន ទ.ក. ៩, ទំព័រ ៧០៥, ឆ្នាំ ១៩៥២, (ម.៥២/២៩) ។

វិបត្តិសតិសម្បជញ្ញៈ : លោក ផេង - ជ្រៅ ទ.ក. ១, ទំព័រ ៤៩, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

វិរុឡ្ហវត្ថុគាថា : ព្រះវិគ្គញាណ សោម - ឡុប ទ.ក. ៣, ទំព័រ ១៧៩, ឆ្នាំ ១៩៤៥, (ម.៥២/២៧) ។

វិវត្តន៍នៃអក្សរខ្មែរ : លោក ឌ តាម ទ.ក. ៣, ទំព័រ ២៨៩, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

វិភធម្មបទ : ព្រះឧបាលិវង្ស ម៉ុង - សែស ទ.ក. ៦, ទំព័រ ៤១២, ឆ្នាំ ១៩៥៥ (ម ៥២/២៧) ។

វិតក្កូបសមកថា : ព្រះភិក្ខុ ហេន - ធឿន ទ.ក. ៥, ទំព័រ ៣២៣, ឆ្នាំ ១៩៥៤, (ម.៥២/២៦) ។

វិសារទធមិ : ព្រះមហាឧត្តមវិជ្ជា កែ - អឿន ទ.ក. ៨, ទំព័រ ៥៨១, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

វីរបុរសពីររូបនៃទ្វីបអាស៊ី : លោក ប៉ាយ - ប៊ុក ទ.ក. ១០, ទំព័រ ៩០៧, ឆ្នាំ ១៩៤៧, (ម ៥២/១៩) ។

វីរយកថា : យុទ្ធបណ្ឌិតរក្ស ប៊ូ - ប៉ូ ទ.ក. ៣, ទំព័រ ៦០៣, ឆ្នាំ ១៩៣៧, (ម.៥២/២៩) ។ អ្នកឧកញ៉ាសុភាធិកា ស៊ូរ ទ.ក. ៨, ទំព័រ ៨៧, ឆ្នាំ ១៩២៦ - ២៧ (ម.៥២/១) ។

វីរិយកថា : អាចារ្យ ស៊ូរ - ហាយ ទ.ក. ៧ - ៨ - ៩, ទំព័រ ២៣៥, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

វីរិយារម្ភកថា : ព្រះគ្រូ កែ - អឿន ទ.ក. ១០, ទំព័រ ៧២៣, ឆ្នាំ ១៩៥៤, (ម ៥២/២៦) ។

វេយ្យាករណ៍និបាតសព្ទខ្ទះ : ទ.ក. ៧, ទំព័រ ៧៤១, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

វេយ្យាករណ៍សំស្ក្រឹត : ព្រះវិសុទ្ធិវង្សហួត - តាត ទ.ក. ៧-៨-៩ ទំព័រ ១៦៣, ឆ្នាំ ១៩៣៨, (ម.៥២|១.) ។

វេរកថា : ព្រះសាសនមុនី កឹម-គូរ ទ.ក. ២, ទំព័រ ១១១, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

វេរប្បតិវេរកថា : ព្រះគ្រូមុនីសោភណ សោម - ឡុច ទ.ក. ១, ទំព័រ ៣២, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

វេឧញ្ញជាតក : ម.ឯកនិបាតជាតក ។

វេរុបសមកថា : ព្រះគ្រូញាណមុនី ឡេង - រម ទ.ក. ៥, ទំព័រ ៤៨១, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

វេសារជ្ជករណធម៌ : ព្រះមហា សុខ - យូរ ទ.ក. ៣, ទំព័រ ២៣៩, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរៈ លោក តាប ពិន ទ.ក. ១០, ទំព័រ ៩០០, ឆ្នាំ ១៩៥៧, (ម ៥២/២៩) ។

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីចំរៀងនិងប្រយោជន៍ចំរៀង : លោកតាប - ពិន ទ.ក. ២, ទំព័រ ១៣១, ឆ្នាំ ១៩៥៥, (ម.៥២/២៧) ។

សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ : លោកតាប - ពិន ទ.ក. ១, ទំព័រ ៧២, ឆ្នាំ ១៩៥៣; ទ.ក. ២, ទំព័រ

១៦១, ឆ្នាំ ១៩៥៣; ទ.ក. ៥, ទំព័រ ៣៨៤, ឆ្នាំ ១៩៥៣; ទ.ក. ៦, ទំព័រ ៤៦៣, ឆ្នាំ ១៩៥៣; ទ.ក. ៧, ទំព័រ ៥៤៤, ឆ្នាំ ១៩៥៣; ទ.ក. ៨, ទំព័រ ៦១៩, ឆ្នាំ ១៩៥៣; ទ.ក. ៩, ទំព័រ ៧០៣ ឆ្នាំ ១៩៥៣; ទ.ក. ១០, ទំព័រ ៧៨៣, ឆ្នាំ ១៩៥៣; ទ.ក. ១១, ទំព័រ ៨៥៣, ឆ្នាំ ១៩៥៣ (ម ៥២/២៥) ។

សង្គ្រោះ : អាចារ្យ គិម - អាន ទ.ក ១ - ២ - ៣ ទំព័រ ២១១, ឆ្នាំ ១៩៣៨, (ម.៥២/១០) ។

សង្ខិតន័យពីប្រវត្តិព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា អតីតកាល : ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ទ.ក. ១, ទំព័រ ៨, ឆ្នាំ ១៩៥៥, (ម.៥២/២៧) ។

សង្ឃហជមិ : ព្រះបាឡាត់ខុត្តមលិខិត សុង - ស៊ុរ ទ.ក. ៧, ទំព័រ ៤៨៣; ឆ្នាំ ១៩៥៣; (ម.៥២/២៥) ។ ព្រះវិន័យធម្ម យូរ - ប៊ុណ្ណ ទ.ក. ២, ទំព័រ ១៤៤, ឆ្នាំ ១៩៤៨, (ម ៥២/២០) , ទ.ក. ៤, ទំព័រ ២៥៦ ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

សង្ឃហជមិ ៤ ប្រការ : លោក ឈឹម - ស៊ុម ទ.ក. ២; ទំព័រ ១៦៨, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

សង្គាយនាព្រះត្រៃបិដកប្រទេសកម្ពុជា : ពុទ្ធសាសនបណ្ឌិត្យ ទ.ក. ៣, ទំព័រ ១៣៩, ឆ្នាំ ១៩៥៣, (ម.៥២|២៥) ។

សង្គាយនាយ៉ាងសង្ខេបរបស់ព្រះពុទ្ធសាសនា : ទ.ក. ១៦, ទំព័រ ៣, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សង្គ្រាមកំពាំង : យុទ្ធបណ្ណាទុរក្ស ប៊ូ-ប៉ូ ទ.ក. ១២, ទំព័រ ៩៣, ឆ្នាំ ១៩៥៥, (ម.៥២|២៧) ។

សង្គ្រាមរវាងគីត្តកាំងនិងព្រះព្រហ្ម : លោក លាង - ហ័បអាន ទ.ក. ១២, ទំព័រ ១២៧៧, ឆ្នាំ ១៩៦០, (ម.៥២|៣២) ។

សង្ឃសរណគាថា : ព្រះមហា កុន-ប្រិញ ទ.ក. ៤, ទំព័ ៣១៣, ឆ្នាំ ១៩៥៦, (ម.៥២|២៨) ។

សង្ឃសោភណគាថា : ព្រះមហា ជាន់ - ខុក ទ.ក. ១២, ទំព័រ ១៣២៧, ឆ្នាំ ១៩៥៩, (ម ៥២|៣១) ។

សតិសម្បជញ្ញគាថា : ព្រះបាឡាត់ សុន - ស៊ុរ ទ.ក. ៤ ទំព័រ ១១៨, ឆ្នាំ ១៩៥៦ (ម.៥២|២៨) ។

សត្តឧបសូត្រ : ឧកញ៉ាភក្តីកជា យ៉ុង ទ.ក. ៧ - ៨ - ៩, ទំព័រ ១០៤, ឆ្នាំ ១៩៣៣. (ម.៥២|៦) ។

(នៅមានត)

# ជីវប្រវត្តិ

## របស់ខ្ញុំឈ្មោះ អៀង·សាយ

( គ )

ខ្ញុំសន្យានឹងពួកយួនថា ខ្ញុំមិននិយាយតាមការពិត ខ្ញុំគិតឲ្យវារួចខ្លួនទាំងអស់គ្នា ។

ដោយខ្ញុំទៅនិយាយប្រាប់ពួកជប៉ុនថា ក្មេងវាប្រាប់ខ្ញុំថា កាបូបនោះ ដាក់ហោប៉ៅខាងក្រោយមិនបានចូលស៊ប់ នៅយប់ដែលស៊ីផឹករួច ដើរមកបានបន្តិច កាបូបនោះជ្រុះធ្លាក់នៅផ្លូវ មានយួនម្នាក់ពាក់អាវខ្មៅ ស្លៀកខោខ្មៅ ដើរជើងទទេ បំរុងទៅរកស៊ីផឹក វាជាន់ទៅលើកាបូប វារើសបើកមើលឃើញមានប្រាក់ពាររយរៀល វាដកយកប្រាក់ ហើយបោះកាបូបចោលទៅក្នុងគុម្ពផ្កា នៅមុខភោជនីយដ្ឋាននោះ វាត្រឡប់ទៅវិញ ឥឡូវនេះយួនដែលរើសបានប្រាក់ វាទៅផ្ទះវានៅឯព្រៃនគរ ឯណោះបាត់ទៅហើយ ។ ជប៉ុននាំគ្នាមករកមើល ឃើញកាបូបនោះ វាត្រេកអរខ្លាំងណាស់ ដោយបានឃើញឯកសាររបស់វា ។

ខ្ញុំចេះតែបែកគំនិត អំពីរឿងលេងកលថ្មីនៃក្ក រហូតដល់បានធ្វើឲ្យគេឃើញជាក្មេងកើតចេញពីផ្កាឈូក នាំឲ្យផ្អើលគេមកមើល បានប្រាក់ជាច្រើន រឿងក្មេងកើតពីផ្កាឈូកនោះអស្ចារ្យណាស់ មិនមែនដូចធ្វើសម័យឥឡូវនេះទេ គេចង់បង្ខំឲ្យដូចរបស់ខ្ញុំធ្វើ តែធ្វើមិនដូចៗ

កាលដែលធ្វើរួច គាំងឲ្យគេមើលនៅក្នុងពេញ ហើយចេញទៅគ្រប់ខេត្តក្រៅ ឲ្យបងប្អូនខ្ញុំនាំយកទៅតាំង ឲ្យគេមើលយកប្រាក់គ្រប់ខេត្តក្នុងស្រុកខ្មែរ ហើយទៅស្រុកយួនកូសាំងស៊ីននៅយួរទៃ ទើបទៅដល់ហាណូយឯតុងកឹងទៀត បានប្រាក់ច្រើនដូចត្រូវឆ្នោតធំមួយ ។ ខ្ញុំមានរូបថតទីងឯកសារអំពីភ្លេងកើតពីផ្កាឈូកនោះ ទុកមកដល់ពេលនេះ ។

បន្ទាប់អំពីរឿងដែលខ្ញុំលេងកលថ្មីនៃភ្លេង ខ្ញុំសរសេរអំពីរឿងដែលខ្ញុំចេះតែងពាក្យកាព្យឃ្លោង ។

នៅវត្តបាក់ក ដែលមានឈ្មោះត្រឹមត្រូវថាវត្តពុទ្ធជ្ឈមានជ័យ នៅជិតក្នុងស្រង់ គឺក្នុងស្រុកកំណើតរបស់ខ្ញុំ មានរូបគំនូររឿងពុទ្ធប្រវត្តិនៅផ្ទៃសាលាវត្តនោះ ដែលជាសំណាដៃរបស់លោកឪពុកខ្ញុំ ។ ខ្ញុំឃើញចំណងជើងជាពាក្យកាព្យ ខ្ញុំកត់ចម្លងយកមកតាំងពីខ្ញុំបានអាយុ១៨ ឆ្នាំ សេចក្តីថា :

សេរីភេហារប្រាជ្ញាវៀង នាមដើមឈ្មោះអៀងជាងគំនូរ
គំនិតប្រឹងគិតប្រកបគូរ ប្រគេនលោកគ្រូចៅអធិការ ។
ត្បិតព្រះទ័យព្រះទសពល យោបល់ត្រូវយល់ដោយបញ្ញា
ខំស្អិតគិតស្អាងសាងសាលា ជាការទុកតព្រះគុណថ្លៃ ។
ទើបទ្រង់តម្រាស់ត្រាស់ប្រើប្រាណ មិនខានខំប្រឹងតាមព្រះទ័យ
ប្រទានទ្រព្យឲ្យអាស្រ័យ មួយថ្ងៃជាប្រាក់សាមសិបសេន

ដោយឃើញពាក្យកាព្យ ដែលមានពាក្យផ្ទួនចួនជាប់គ្នា មានឃ្លាជាពាក្យពីរោះនោះ ខ្ញុំជាប់ចិត្តគិតពិនិត្យពាក្យកាព្យហ្នឹង ឲ្យតែឃើញពាក្យ ដែលមានកាព្យទាក់ទង ខ្ញុំឈ្លាកពិនិត្យគិតរករបៀបតាប់ចុងផ្ទួន ដោយព្យាយាមយូរមក ខ្ញុំរករបៀបតែងជាពាក្យកាព្យបានខ្លះ សូមយកពាក្យកាព្យជំនាន់នោះ តរៈ-បមកជូនមើល ៗ ដោយទៅធ្វើការកន្ទៃកំប៉ិណ្ឌ ទឹកចាស់ចិត្តនឹកដការអាណាព្យាបាល ខ្ញុំសរសេរពាក្យកាព្យមួយថា :

អស្ចារ្យចម្លែកប្លែកឆ្នាំនេះ　　កដការតែងបេះរះសព្វគ្រប់
បុណ្យកុំទាំងមូលមិនឲ្យឈប់　　គម្អីមកខ្ទប់សាលាដែក ៗ
ជូនតាតាតមករកឯវត្ត　　បាត់ចៅប្រាកដជាយំស្រែក
ទាំងញាតិសន្តានច្រើនអនេក　　ដែលចែកឃានទៅឥឡូវមក ៗ
ប៉េក្ខុនចៅនៅតែធ្វើការ　　អ្នកណាទឹងបានគិតរះរក
អន្សមទំគមរៀបដាក់ស្ពក　　ជ្រូវត្រូវមករកពិសា ៗ

ពាក្យកាព្យមួយទៀត ខ្ញុំឃើញជាងម្នាក់ធ្វើការជាមួយប្អូនខ្ញុំ មានគេនិយាយចំអកចំអន់លេងទឹងជាងនោះ ខ្ញុំសរសេរពាក្យកាព្យ ១ ឲ្យគេអាន ឲ្យគេស្ដាប់ទាំងអស់គ្នា មានសេចក្ដីថា :

ពួកជាងស៊ុមង៉ត់មានឈ្មោះយី　　បេះការខ្វេចខ្វីសល់ដោយជុំ
បេះបូកបូកក្បាច់កាច់ប្រមុំ　　ឲ្យតែមានពុម្ពធ្វើបានគ្រប់ ៗ

ចេះភាយស៊ីម៉ង់ត៍ផង់ដូចផេះ    ប៉ុកទៅនៅល្បេះផុយដុះ ១

បើធ្លាក់បាក់បែកមានដែកទប់    យើយល់ការគ្រប់យប់រៀនគួរ ៗ

ស្រី ៗ ឃើញក្បាច់ញោចកណ្តៀវ ដែលយើព្រានព្រៀវផ្អូលមើលល្ហួរ

សរសើរគ្រប់មាត់ថាគាត់គួរ    គំនូរល្អដាច់ដូចក្បាច់អាល ៗ

ដោយខ្ញុំជាប់គំនិតពីពាក្យកាព្យឃ្លោង មានឥស្សរជនជាន់ខ្ពស់មួយរូប ប្រើឲ្យខ្ញុំគូររូបមួយធំតាមរូបថតតូច ដល់ឃើញខ្ញុំគូរបានដូចរូបថតនោះ បានបញ្ចេញពាក្យសរសើរលើកទឹកចិត្តជាច្រើន ខ្ញុំនឹកចង់សើចនឹងពាក្យអស់នោះ ដែលជាពាក្យពយ ធម្មតាទេ តែខ្ញុំយកមកបន្ថែមបន្ថយតែងជាពាក្យកាព្យមើលលេងថា :

ខែងជាងអ្នកចេះចំណេះចប់    កុំជប់គិតព្រួយពីប្រាក់កាស

ឯងគូរល្អល្អិតកុំគិតផ្តាស    ប្រាក់កាសអញឲ្យឯងពេញចិត្ត ៗ

ដូចកាលអញទៅនៅប៉ារីស    មានជាងគេចេះបញ្ចេញមុត

គូរដូចរូបអញ ៗ ពេញចិត្ត    អាណិតគេណាស់អញឲ្យក្រៃល ៗ

គ្រាន់តែមេដាយរាល់ទឹងប៉ោត    ប្រាក់ហ្វ្រង់គ្រណាតប៉ូកនឹងប៉ែល

រាល់ទឹងក្រឡក្រប្រហែល    អញឲ្យគេក្រៃលរដោយរាក្រ ៕

ឯខ្លួនឯងនេះឯងកុំគិត    លែងលិទ្ធប្រហុកហុតសម្ល

សុទ្ធតែនំប័ុងនិងគ្រើខ    ម្ហូបបារាំងយ៉ាងល្អសម្ខិះ ៗ

ចាំងព្រឹករាំងល្ងាចមកស៊ីចុះ    ឯងនេះប៉ុណ្ណោះមិនសំគិះ

ឡានអញប្អូនដប់ប៉េចង់ជិះ ទាំងកុលាបម្ទិះបេះតាមចិត្ត ។
សួនច្បារដំណាំអញផាំផ្កា ទៅណាមកណាអញគាណិត
បេះទៅក្រងលេងកំសាន្តចិត្ត កុំគិតគោតខ្លាចអំណាចអញ ។
មួយទៀតស្រី ៗ ក្មេងក្ដុងក្រៅ គួនចៅអ្នកណាឯងស្រឡាញ់
មើលឲ្យស្រឡះរូបប្រាប់អញ ទឹងការញ់គិតគូរជណ្ដឹងឲ្យ ។
ឯគ្រង់ប្រពន្ធឯងកុំព្រួយ ឯខ្លួនឯងមួយមិនខ្សត់ខ្សោយ
អញធានាជួយប្រាក់កប់បេ អញរៀបការឲ្យកុំខ្លាចអត់ ។
ឯផ្ទះសម្បែងឯងមិនក្រ សង់ថ្កុតឡើងតម្កើងកត់
ប្អូនជានប្រាំជាន់មិនគំណត់ ឡើងម្ដងក្រែងហត់មាត់ហប ៗ ។

ខ្ញុំមានសរសេរពាក្យច្រើនទៀត ជាចំនុកច្រៀងខ្លះ ជាសុភាសិតខ្លះ ជារឿងបែបសាស្ត្រខ្លះ តែគេខ្ចីយកទៅមើលបំបាត់អស់ខ្លះ នៅសល់ខ្លះ គឺរឿង តាតូច និងមេកាព្យជាក្បួនច្បាប់ ។

ឯរឿងប្រលោមលោក ខ្ញុំស្រឡាញ់អានរឿងអក្សរខ្មែរ និងអក្សរបារាំងជាច្រើន ខ្ញុំអានមើលពិនិត្យល្បិចកិច្ចកលដែលគេសរសេរ លុះតែបានយល់ បានសរសេរលេង សរសេរល្បងមើលច្រើនរឿងដែរ ។

តែមុនដំបូងខ្ញុំចាប់សរសេររឿងល្ខោន ជារឿងកំប្លែងខ្លី ៗ មានតែមួយឈុត ។ បន្ទាប់មក ខ្ញុំសរសេររឿងល្ខោន ជារឿងគួរឲ្យសើច ជារឿងកំសត់ និងជារឿងអប់រំផង ។ មានច្រើនឈុត ច្រើន

ធាក ដល់មកក្រោយ ទើបខ្ញុំសរសេររឿងប្រលោមលោក និងរឿងកំសាន្តចិត្តខ្លី ៗ ជាច្រើន ។

បានជាខ្ញុំចាប់សរសេររឿងមុន ដោយខ្ញុំជាអ្នកនាំសិស្សហាត់លេងរឿងកាលពិធីចែករង្វាន់ ឬ បុណ្យផ្កា បុណ្យកឋិន ។

បើរាប់ឈ្មោះរឿងល្ខោន ដែលជារឿងវែងហើយល្អផងនោះគឺ :

១- រឿងសេនាក្លាហាន

២- រឿងរត់ទ័ព

៣- រឿងកេរ្តិ៍មរតក

៤- រឿងសុបិននិមិត្ត

៥- រឿងព្រះរាជសម្ភារ

៦- រឿងរើសរកប្តី

៧- រឿងស្រីសុភាព

៨- រឿងដាំងឈើប្រាជ្ញព្រោក ។

រឿងក្រោយនេះ បានទទួលរង្វាន់ក្នុងការប្រឡងអក្សរសាស្ត្រ អំពីដៃឯ.ក. ហ៊ុយ - កន្ធុល នៅទីព្រះនាំងភោជនីយ ចំពោះព្រះភក្ត្រព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ។

ឯរឿងប្រលោមលោក បើរឿងដែលល្អ ៗ គឺ :

១- រឿងសាភកាណ

២- រឿងស្រីប្តីឆោះ

៣- រឿងផិតក្បត់

៤- រឿងគូព្រេងគូកម្ម

៥- រឿងអ្នកជាប់ពោទទៅជាគ

៦- រឿងផ្ការីកផ្ការោយ

រឿងក្រោយនេះបានទទួលរង្វាន់ ក្នុងការប្រឡងអក្សរសាស្ត្រ អំពី ថ្ងៃ ៦.១. មាស - ណាល់ នៅមន្ទីរមហោស្រពក្រុង ចំពោះព្រះភក្ត្រ ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ និងចំពោះមុខលោក ឡូរ៉េស៊ុ. ដង់តស៊ុយប៉េរ៉េយេរ ។

បើត្រឡប់មកនិយាយអំពីចំណេះខាងវិចិត្រសិល្បៈវិញ កាលលោក ដេស្សាជាំងធ្វើជានាយកក្រសួងឃោសនាការ លោក គិម - ហាក់ ធ្វើ ជាកម្មនៅក្នុងក្រសួងនេះ មានបង្គាប់ទៅសាលាទស្សហកម្ម, សាលា របនា, ក្រសួងសុរិយោដី និងក្រសួងសាធារណការ ឲ្យរៀបតុបតែង ទូកញ្ចក់ ៣ ក្នុង ១ ក្រសួង ឲ្យគូរផាត់តពណ៌លើការស្តើង ឬក្រដាស ក្រាស់ហើយកាត់ដាក់បញ្ឈរ ធ្វើជាទេសភាព ឲ្យមើលឃើញមុខក្រោយ ឆ្ងាយជិត គឺ « ឌីយ៉ូរ៉ាម៉ា » ធ្វើយ៉ាងម៉េចឲ្យបានគេឃើញតាមគោល បីគឺ :

១– ស្រុកខ្មែរពីដើមយ៉ាងម៉េច

២– ស្រុកខ្មែរបច្ចុប្បន្នយ៉ាងម៉េច

៣– ស្រុកខ្មែរអនាគតយ៉ាងណាទៅ ។

គេឲ្យធ្វើប្រឡងគ្នាយករង្វាន់ កាលនោះសាលាឧស្សាហកម្ម ដែលមានខ្ញុំជាអ្នកធ្វើតាមគោលការណ៍បីគឺ កាំបូតដូហ្ស៊ើ, កាំបូតឌីយេរ, កាំបូតឌើម៉ាំង នោះបានទទួលរង្វាន់លេខ ១ ។

ម្យ៉ាងទៀត មានការប្រឡងគំនូរសំណាកប្រកាសផ្សាយដំណឹង អំពីពិព័រណ៍ ដែលនឹងមានតាំងនៅក្នុងព្រះកែវមរកត ។ កាលនោះ គេឲ្យរង្វាន់លេខ ១ ~~ទៅសាលារចនា, លេខ~~ ២ ឲ្យមកខ្ញុំ តែដល់បានជាប្រកាសយកទៅបិទពាសពេញក្នុងក្រុងនិងខេត្តក្រៅ ទៅជាឃើញរូបគំនូរសំណាករបស់ខ្ញុំទៅវិញ ឯគំនូរសាលារចនាដែលបានរង្វាន់លេខ ១ មិនឃើញ ដល់ស៊ើបសួរទៅលេចឮពាក្យថា មេប្រយោគយល់ដល់ពួកសាលារចនា ក៏ឲ្យរង្វាន់លេខ ១ ទៅ ដល់យកគំនូរលេខ ១ ទៅឲ្យរោងពុម្ព គេធ្វើពុម្ពបោះ គេថាពាស់ពីពណ៌គ្មានរបៀបល្មមធ្វើពុម្ពបាន គេចោលទៅ គេយករបស់ខ្ញុំដែលបានលេខ ២ មកធ្វើវិញ ដោយមានរបៀបរៀបពណ៌ល្អ ។

(នៅមានត)

អត្ថបទផ្នែកទំនៀមទម្លាប់

# ចូលឆ្នាំថ្មី

អ្នកស្រី ពេជ-សល់ រៀបរៀង

ខ្មែរនិយមចូលឆ្នាំថ្មីនៅក្នុងខែចេត្រ ដែលជាខែទី ៥ នៃប្រក្រតិទិនខ្មែរ ប៉ុន្តែគេនៅតែរាប់ខែមិគសិរ ជាខែទី ១ ដដែល ។ ការកំណត់ថ្ងៃ-ខែ ចូលឆ្នាំថ្មីនេះ កាលដើមឡើយ ពោរាណកបណ្ឌិតអ្នកប្រទេសទាំងឡាយក្នុងជម្ពូទ្វីប លោកកំណត់យកខែមិគសិរជាដើមឆ្នាំ ដោយហេតុក្នុងសម័យព្រេងនាយ លោកប្រើរដូវ ៣ តាមចន្ទគតិ ដោយច្រើនគឺ:

- ហេមន្តរដូវ (រដូវត្រជាក់)
- គិម្ហរដូវ (រដូវក្ដៅ)
- វស្សានរដូវ (រដូវភ្លៀង)

រដូវត្រជាក់ ឬ ហេមន្តរដូវ លោកទុកជារដូវដើមឆ្នាំ ប្រៀបដូចជាវេលាព្រឹក ចាត់ទុកជាដើមថ្ងៃ ដែលមានអាកាសធាតុត្រជាក់ គួរជាទីពេញចិត្តនៃមនុស្សសត្វទូទៅ ។

រដូវក្ដៅ លោកទុកជារដូវកណ្ដាលឆ្នាំ ប្រៀបដូចជាវេលាថ្ងៃត្រង់ ដែលព្រះអាទិត្យបញ្ចេញចំហាយយ៉ាងខ្លាំង ។

រដូវភ្លៀងផ្គរ ប្រកបដោយអាកាសងងឹតអួរអាប់ លោកទុកជាវេលាចុងថ្ងៃ ប្រៀបដូចជាវេលាទៀបចូលគ្រែ ។

អាស្រ័យហេតុនេះ ទើបចាស់ព្រឹទ្ធាចារ្យ លោកកំណត់យកខែមិគសិរ ជាខែចូលឆ្នាំ ។

ឯការកំណត់ចូលឆ្នាំ ក្នុងខែមិគសិរនោះ មកអំពីជំនាន់ដើម គឺពីគ្រឹមសម័យក្រុងនគរធំឡើងទៅ ប្រទេសកម្ពុជាយើង រាប់អានប្រើចន្ទ-គតិជាសំខាន់ ។ ប៉ុន្តែអ្នកប្រាជ្ញជាន់មុន បានធ្វើសេចក្តីកត់សំគាល់ថា ចន្ទគតិ គឺដំណើរនៃព្រះចន្ទនោះ គឺកំណត់តាមហោរាសាស្ត្រ ដែលព្រះចន្ទត្រូវដើរមួយជុំពិភពលោកម្តង ។ ដើម្បីធ្វើដំណើរឲ្យបាន ១ ជុំពិភពលោកនេះ ព្រះចន្ទត្រូវចំណាយពេលអស់ ២៩ ថ្ងៃកន្លះជាងបន្តិច ដែលហៅថា ១ ខែ ហើយ ១២ ខែ បានជា ១ ឆ្នាំ ។ ប៉ុន្តែប្រសិនបើយើងនិយមប្រើតាមចន្ទគតិតែម្យ៉ាង លុះច្រើនកាន់ឆ្នាំទៅខាងមុខ យើងនឹងឃើញថា រដូវតាមចន្ទគតិ នឹងមិនទៀងទាត់តាមធម្មតាឡើយ គឺថារដូវរងានឹងក្លាយទៅជារដូវក្តៅ ។ ក្លាយទៅជារដូវភ្លៀង ព្រោះគោលនៃរដូវទាំងឡាយ ដែលជាគ្រឿងសំគាល់ធម្មជាតិ ដូចជា រដូវឈើផ្កា ផ្លែ ភ្លៀង ខ្យល់ ជាដើម សុទ្ធតែត្រូវតាមសុរិយគតិទាំងអស់ ។ ដើម្បីចៀសវាងនូវការប្រែប្រួលដូចនេះហើយ ទើបនៅពេលដែលមនុស្សយើងមានសេចក្តីចេះដឹងវិសេសឡើង ក៏គិតប្រើរដូវតាមសុរិយគតិ អែបជាមួយនឹងចន្ទគតិផង និងប្រើសុរិយគតិសុទ្ធតែម្យ៉ាងក៏ពុំបាន ព្រោះក្នុងគោតមពុទ្ធកាលនេះ មានពិធីកិច្ចផ្សេង ១ ក្នុងសាសនាច្រើនណាស់

ដែលទាក់ទងនឹងចន្ទគតិ ទើបគេនិយមប្រើអែបគ្នាយ៉ាងនេះ ហើយបើកាលណាព្រះចន្ទនិងព្រះអាទិត្យដើរឃ្លាតឆ្ងាយអំពីគ្នា លម្អកបានជា ១ ខែហើយ ទើបគេគិតលើកអធិកមាសម្តង ដើម្បីឲ្យទាន់គ្នាវិញ (តាមទម្លាប់ ៤ ឆ្នាំ មានអធិកមាសម្តង) ។

ទើបតែជាខាងក្រោយ គឺក្រោយពីពេលដែលផ្តើមប្រើចុល្លសករាជមកនេះទេ ដែលខ្មែរយើងត្រឡប់ប្រើសុរិយគតិជាសំខាន់ ហើយកំណត់ចូលឆ្នាំក្នុងខែចេត្រ ដែលជាខែទី ៥ ជាប់រហូតមកដល់សព្វថ្ងៃនេះ ។ ប៉ុន្តែទោះជាមានលើកអធិកមាសឲ្យទាន់គ្នាយ៉ាងនេះក៏ដោយ ក៏ថ្ងៃចូលឆ្នាំខ្មែរ នៅតែពុំបានទៀងទាត់ដូចខាងអឺរ៉ុបដែរ ព្រោះជួនត្រូវខាងដើម ជួនត្រូវខាងនោះ ត្រាន់តែមានកំណត់ទុកថា សង្ក្រាន្តនឹងមានក្នុងរវាង ១ ខែ គឺ ក្នុងរវាងពីថ្ងៃ ៤ កើតខែចេត្រ ទៅថ្ងៃ ៤ កើតខែពិសាខ ប៉ុណ្ណោះ ។ ដូច្នេះ ទើបយើងបានសំគាល់ឃើញថា នៅឆ្នាំខ្លះ ការកំណត់ពេលចូលឆ្នាំ ត្រូវធ្លាក់ទៅដល់នៅខែពិសាខក៏មាន(១) ។

តាមសេចក្តីអធិប្បាយដូចខាងលើនេះ ឃើញថា ការដែលយើងធ្លាប់បានឮចាស់ទុំ លោកនិយាយថា ខ្មែរយើងសម័យបុរាណ គេនាំគ្នាធ្វើបុណ្យត្រុដ លេងល្បែងត្រុដ អស់ពេលពេញ ១ ខែចេត្រនោះ ជាការពិតណាស់ ព្រោះរយៈពេល ១ ខែចេត្រនេះ គេទុកជាវេលាចូលឆ្នាំទាំងមូល មិនកំណត់យកតែថ្ងៃណាមួយ ដូចសព្វថ្ងៃនេះទេ ។

---

១— ឆ្នាំមមែ នព្វស័ក ព.ស. ២៤៧០, ចូលឆ្នាំដល់ទៅ ៦ កើតខែវិសាខ ។

ក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ នៅតំបន់ខ្លះ ដូចជាជាំខ្សាន ប៉ៃលិនជាដើម មានទំនៀមមួយប្លែកអំពីតំបន់ឯទៀត ដែលគេតែងប្រារព្ធលេង នៅពេលចូលឆ្នាំខ្មែរ ក្រៅអំពីទំនៀមធ្វើបុណ្យជាកុសលចំពោះព្រះសង្ឃ ។

តាមសេចក្ដីឲ្យការណ៍របស់លោក មាស - ហាំ និង លោក ប៊ុន ប៊ុរ ដែលធ្លាប់បានធ្វើកសិការនៅតំបន់ជាំខ្សាននេះថា : ១៥ ថ្ងៃជាខាងក្រោយ គឺគិតអំពីថ្ងៃចូលឆ្នាំទៅ អ្នកស្រុកទាំងប្រុសទាំងស្រី ទាំងក្មេងទាំងចាស់ នាំគ្នាយកទឹកអប់ ផ្កាភ្ញី ទៅកាន់ទីវត្តអារាម ដើម្បីទៅធ្វើពិធីស្រង់ជម្រះព្រះពុទ្ធរូបនៅក្នុងព្រះវិហារ ដែលធូលីកាន់អស់ពេល ១ ឆ្នាំទៅហើយនោះ និងដើម្បីសុំសេចក្ដីសុខសប្បាយអំពីកិច្ចនោះផង ។

ពេលត្រឡប់មកផ្ទះវិញ ពួកកំលោះនាំគ្នាតាមស្រោចទឹកក្រមុំ គឺគេលេងចាក់ទឹកលើគ្នាទៅវិញទៅមក ឥតប្រកាន់ថាស្រី ថាប្រុសឡើយ ។ ល្បែងស្រោចទឹកដែលអ្នកស្រុក ក្នុងតំបន់ជាំខ្សាន ទាំងប្រុសទាំងស្រីលេងនោះ ហាក់ដូចជាសប្បាយណាស់ ។ នៅពេលដែលគេនិយមលេងនោះ ពួកកំលោះនាំគ្នារែកទឹកនឹងគ្រុះ សំដៅទៅផ្ទះណាដែលមានកូនក្រមុំ បានដល់ហើយ ដណ្ដឹងសួរឪពុកម្ដាយគេថា " លោកពូ · អ៊ំ នាងឈ្មោះ . . . (ឧ. ឈ្មោះនាង សាត់ ) ទៅណាហើយ ? " ជួនកាលឪពុកម្ដាយនាងក្រមុំនោះ កុហកថា " មិននៅទេ ទៅលេងឯនោះ

ហើយ ” តែទោះជាគេធ្វើយ៉ាងនេះក៏ដោយ ពួកកំលោះនោះ នាំគ្នាឡើងទៅបើកទាល់តែឃើញ ហើយនាំគ្នាយកទឹកដះ ទោះជាទឹកខ្លាតទៅទទឹកស៊ីកាំង ឬមនុស្សដទៃទៀត ក៏ឥតគិតឡើយ ។ ដូនកាល ពួកកំលោះដែលរកទឹក ដើរទៅកន្ត្រាចគេនោះ ប្រទះនឹងក្រមុំ ដែលមានកិច្ចការ កំពុងធ្វើដំណើរតាមផ្លូវ ក៏ដះទឹកទៅលើទាល់តែទទឹក អស់ តែគេឥតមានប្រកាន់ខឹងអ្វីឡើយ ។

រឿងល្បែងបែបនេះ មិនមែនមានតែស្រី ១ ទេ ដែលទទួលអភ័ព្វ, គឺពួកស្រី ១ ក៏គេចេះដែរ គេនាំគ្នាផ្ទាំងចាំមើល ឲ្យតែពួកកំលោះបែកហួង ឬដើរគ្នាតិចហើយស្លៀកពាក់ល្អ ១ គេនាំគ្នាព្រួតចាប់ផ្តួល ដងទឹកចាក់ចូលប្រមុះ ចូលត្រចៀក ទាល់តែសំពះអង្វរសុំចាញ់ ទើបគេឈប់ ។ ល្បែងចាក់ទឹកនេះ មិនមែនលេងត្រឹមតែអ្នកធ្លាប់ស្គាល់គ្នាប៉ុណ្ណោះទេ សូម្បីអ្នកមិនធ្លាប់ស្គាល់ ក៏លេងបាន ឲ្យតែចូលទៅដល់ក្នុងស្រុកគេ ។

តាមសេចក្តីឲ្យការណ៍ របស់លោក ហង់ · សំហឿនថា បុណ្យចូលឆ្នាំថ្មីនៅប៉ៃលិន ក៏សប្បាយណាស់ដែរ, សប្បាយតាំងរូបលោក តាំងភ្ញៀវទេសចរពីក្រៅតាំងខ្លាយ ដោយគេលេងចាក់ទឹកគ្នា ដូចជានៅឯជាំខ្សានដែរ ។

កាលដើមឡើយ នៅផ្ទះក្លូខ្សាទីមួយ ១ គេតែងរៀបទឹកអប់ និង

គ្រឿងក្រអូបផ្សេង ៗ សម្រាប់បុណ្យចូលឆ្នាំ កាលបើមានភ្ញៀវចូលទៅ អ្នកផ្ទះយកគ្រឿងក្រអូបនោះទៅប្រោះព្រំលើខ្លួនភ្ញៀវ ប្រសិទ្ធិពរឲ្យមានជោគជ័យ សេចក្ដីសុខ សេចក្ដីចំរើនគ្រប់ប្រការ តែលុះដល់ក្រោយមក ទំនៀមនេះ ក៏ក្លាយទៅជាទំនៀមបាចទឹកដាក់គ្នាទៅវិញ គឺនៅមុខផ្ទះម្នាក់ ៗ សុទ្ធតែមានផ្ដិល ឬធុងទឹក ឲ្យតែអ្នកណាដើរកាត់មុខផ្ទះគេ មិនថាស្រី · ប្រុស ឬកូនលោកណាទេ ទោះជាអ្នកណាក៏ដោយ បើស្លៀកពាក់ល្អ ៗ ផង គេរឹតតែចូលចិត្តលេងណាស់ទៅទៀត កំលោះដេញសាចទឹកលើក្រមុំ ក្រមុំដេញសាចទឹកលើកំលោះ បើក្រមុំណារត់ចូលផ្ទះ គេដេញសាចទឹកតាមដល់តែផ្ទះ សាចទឹកលើបានហើយ ទើបឈប់ ៗ ពុំឃើញមានលេងល្បែងអ្វីក្រៅពីល្បែងនេះទេ ។

តាស់ទុំនិងក្មេងខ្លះ នាំគ្នាឡើងទៅលើភ្នំយ៉ាត ដើម្បីជម្រះចិត្តអកុសលចោល ហើយតម្រង់ចិត្តឲ្យបានល្អក្នុងឆ្នាំថ្មីតទៅ អ្នកខ្លះទៀត គេដើរទៅសំពះចាស់ទុំ ដើម្បីសុំពរឲ្យបានសេចក្ដីសុខ សេចក្ដីចំរើន និងប្រកបការងារឲ្យបានសម្រេចគ្រប់ប្រការ ។

នៅថ្ងៃបង្ហើយបុណ្យចូលឆ្នាំ គេនាំគ្នាទៅកាន់ទីវត្តទាំងប្រុសទាំងស្រី មានទាំងទឹកអប់ជាប់គ្រប់ដៃទៅផង ដើម្បីទៅធ្វើពិធីស្រង់ព្រះដូចនៅខេត្តនានាដែរ ។ នៅពេលនោះ គេលេងល្បែងចាក់ទឹកធំណាស់

គេស្រង់ទាំងព្រះពុទ្ធរូប ទាំងពាក់ស្រោបគ្នាទៅវិញទៅមក ទាល់តែទទឹកស្រឡាបគ្រប់គ្នាគ្មានសល់ ទៅជាប្រឡូកប៉ូកប៉ាកពេញទាំងវត្ត ។ ពួកគេនិយាយថា មានស្រីៗខ្លះ លាយទឹកល័ក្តបន្ទុំ ដើម្បីពាក់លើប្រុសៗដែលមានសំលៀកបំពាក់សផង ហើយនាំគ្នាហ៊ោកញ្ជ្រៀវទ្រហឹងអឺងអាប់គួរសប្បាយពេកណាស់ ។

---

# ផ្នែកកំណត់និងប្រវត្តិការណ៍

## សេចក្ដីរាយការណ៍

អំពីសកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ

ក្នុងត្រីមាសទី ៤ ឆ្នាំ ១៩៦៦

សេចក្ដីរាយការណ៍នេះ គឺធ្វើបន្តពីសេចក្ដីរាយការណ៍ ៣ ត្រីមាសមុន ដែលបានធ្វើកាលពីថ្ងៃទី ៣០ កញ្ញា ១៩៦៦ (ផ្ញើជូនទៅក្រសួងធម្មការ តាមដីកាអម លេខ ១.៦៤០ ព.ប. ចុះថ្ងៃ ៣-១០-៦៦) ហើយដែលបានចុះក្នុងកម្ពុជសុរិយា លេខ ១-២ ឆ្នាំ ១៩៦៧ ។

១. ផ្នែករដ្ឋបាល :

ទោះបើខ្វះបុគ្គលិកមានសមត្ថភាពជាចាំបាច់គឺ : -អគ្គលេខាធិការរង ១ រូប, -នាយការិយាល័យរបៀប និង បុគ្គលិក ១ រូប, -នាយការិយាល័យនៃការផ្សាយ ១ រូប, ក៏វិជ្ជាស្ថាន បានចាត់ចែងការ មានរបៀបរៀបរយចម្រើន ដោយការខិតខំទុកម៉ាំង របស់បុគ្គលិកទទួលកិច្ចការបណ្ដោះអាសន្ន គ្រប់ៗគ្នា ក្នុងក្រសួងនេះ ។

## សេចក្ដីស្នើសុំ:

វិជ្ជាស្ថានសុំទទួចចំពោះក្រសួងធម្មការ សូមមានមេត្តា ៖

ក- ជួយរំលឹកចំពោះការសុំបុគ្គលិក (ពិសេសមានសហជីវិន លាន-ហ៊ីបអាន) គ្រូបង្រៀននៅសាលា អ៊ុង-ម៉េងតិក ជាដើម ដែល

ក្រសួងអប់រំជាតិ ទើបនឹងតបជាយល់ព្រមផ្តល់មកឲ្យតាមសុំនៅដំណាច់ឆ្នាំសិក្សា ១៩៦៦-៦៧ នេះ តាមលិខិតលេខ ៤៨២២ ប.ព. ចុះថ្ងៃ ២៦-១២-៦៦ ចម្លងផ្ញើរបស់ក្រសួងធម្មការ លេខ ៩-ប ចុះថ្ងៃ ៣-១-៦៧ ។

១- ចាត់ចែងយ៉ាងណាឲ្យបានកម្មករថែម ដើម្បីបំពេញការងារសំអាតអគារទាំងមូល ទីបរិវេណក្រសួងហូតដល់បរិវេណខាងមុខពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតផង ។

សូមជម្រាបថា កម្មករ និង កាប៉ូរ៉ាល់តែ ៣ នាក់របស់វិជ្ជាឋាន គឺសព្វថ្ងៃ ត្រូវទទួលខុសត្រូវគ្រប់បែបយ៉ាង នូវការសំអាតអគារក្រសួងធម្មការ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ទីបរិវេណទាំងអស់ នៃក្រសួងធម្មការ ព្រមទាំងពុទ្ធិកវិទ្យាល័យថែមទៀត ។

២- ផ្នែករៀបចំសម្ភារៈ

វិជ្ជាឋាន បានចាត់ឲ្យធ្វើផ្លាកសញ្ញាថ្មី កែពី "អគ្គលេខាធិការដ្ឋាន" មកជា "នាយកដ្ឋាន" នៃពុទ្ធសាសនបណ្ឌិត្យវិញ; ធ្វើសញ្ញាផ្លាកឈ្មោះបុគ្គលិកទៅតាមមុខនាទីរបស់ខ្លួន សម្រាប់ដាក់នៅលើការិយាល័យម្នាក់ៗ; ធ្វើសួនច្បារ នៅមុខពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត បានសមសួនក្នុងពេលអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ២៣; រៀបចំទីកន្លែងខាងត្បូងអគារ ដោយរៀបថ្មអង្គុយជុំវិញដើមអំពិលឲ្យបានស្អាតទូលាយ ដល់រថយន្តចតបានដោយស្រួល ។

## សេចក្ដីស្នើសុំ

ដើម្បីការពាររថយន្តកងការ កុំឲ្យត្រូវថ្ងៃ, ភ្លៀង, ខ្យល់, ខូចខាត, រឺផ្លាប់ខាងសុំក្រសួងធម្មការរៀបយ៉ាងណា សង់រោងមួយនៅខាងលិចអគារ គឺខាងកើតនៃអគារពុទ្ធិកវិទ្យាល័យ ដើម្បីធ្វើជាចំណតរថយន្ត (យើងមានហ៊ីប្រូស៊ីម៉ង់ ហើយទឹងឈើខ្លះដែលជារោងរថយន្តចាស់នៅខាងត្បូងអគារពុទ្ធិកវិទ្យាល័យ) ។

### ៣– ផ្នែកចំណូល–ចំណាយ

### ក– ផ្នែកចំណាយ

ទី ១– ចំណាយខាងទឹក: គិតត្រឹមត្រីមាសទី ៣ ។ ឯត្រីមាសទី ៤ រដ្ឋាករទឹកពុំទាន់ទារថ្លៃនៅឡើយទេ ។

### តារាងប្រៀបធៀប

ឆ្នាំកន្លងទៅ

| ត្រីមាស | ឆ្នាំ ១៩៦៥ | ឆ្នាំ ១៩៦៦ |
|---|---|---|
| ត្រីមាសទី ១ | ៧៥៧ ៛ ៦៥ | ៤១៩ ៛ ៨៥ |
| ត្រីមាសទី ២ | ៨០៥ ៛ ៥០ | ៤៣០ ៛ ៣៥ |
| ត្រីមាសទី ៣ | ២២៤ ៛ ៤០ | ១៩៨ ៛ ០០ |
| បូករួម . . . . | ១.៧៨៧ ៛ ៥៥ | ១.០៤៨ ៛ ២០ |

បញ្ញាត្តិ: កងឆ្នាំនេះចំណាយថយជាងឆ្នាំទៅចំនួន ៧៣៩ ៛ ៣៥ ។ ការចំណេញនេះមកពីបានសំចៃ ហើយមានភ្លៀងបរិបូណ៌ មិនសូវ

ប្រើប្រាស់ស្រោចរុក្ខជាតិនិងផ្កាក្នុងសួនច្បារឡើយ ។

ទី ២- ចំណាយខាងភ្លើង : ( គិតត្រឹមខែវិច្ឆិកា ) ។ ឯខែធ្នូ ពុំទាន់ការថ្លៃនៅឡើយទេ ។

## តារាងប្រៀបធៀប

ឆ្នាំកន្លងទៅ

| ខែ | ឆ្នាំ ១៩៦៥ | ឆ្នាំ ១៩៦៦ |
|---|---|---|
| មករា | ៣៧២r០០ | ៦៣៩r០០ |
| កុម្ភៈ | ៧២៣r០០ | ៥៦៨r០០ |
| មីនា | ៤០៥r០០ | ៩៧៦r០០ |
| មេសា | ៧៧៤r០០ | ៩៧៩r០០ |
| ឧសភា | ១០១៤r០០ | ៧៧៩r០០ |
| មិថុនា | ១១២៧r០០ | ១១៦៩r០០ |
| កក្កដា | ៨៣២r០០ | ៦៤៦r០០ |
| សីហា | ១០៤៧r០០ | ៧៣២r០០ |
| កញ្ញា | ៧៦១r០០ | ១៤៨៣r០០ |
| តុលា | ៨៥៤r០០ | ១៣០០r០០ |
| វិច្ឆិកា | ៨៤៧r០០ | ១៥០៥r០០ |
| ធ្នូ | ៨៩៩r០០ | ២០៨៩r០០ |
| បូករួម | ៩.៦៥៥r០០ | ១៣.៨៥៩r០០ |

បញ្ហាគាំ: ក្នុងឆ្នាំនេះ ចំណាយច្រើនជាងឆ្នាំទៅ ចំនួន ៤ ២០៤៛០០ ។ ការចាយច្រើនជាងបន្តិចនេះ បណ្តាលមកពីមាន ការបើកបំភ្លឺពេលយប់ ក្នុងទស្សនកិច្ចរបស់ភ្ញៀវជាតិ មាន ឯ.ឧ. ប្រធានាធិបតីបាកាំង និងក្នុងពេលបុណ្យ ព្រមទាំងការប្រើ ទូទឹកកក និង ម៉ាស៊ីនត្រជាក់ខាងធម្មការផង ។

សេចក្តីសង្កេត: ចំណាយទឹកភ្លើងនេះ គឺពុទ្ធសាសនបណ្ឌិត្យ ចេញសងសរុបចំពោះក្រសួងធម្មការទាំងមូលផង ពីព្រោះកុងទ័រទឹកភ្លើង ជាកម្មសិទ្ធិរបស់វិជ្ជាឋាន ដែលជាអ្នកទទួលបន្ទុកចាយវាយប្រាក់គ្រោង ចំណាយម្នាក់ឯង តាំងអំពីដើមរៀងដរាបមក ។

យោបល់រួម: បើគិតទៅនឹងប្រាក់គ្រោងចំណាយ របស់ក្រសួង ដែលមាន ២០.០០០៛០០ មួយឆ្នាំ ( ទោះបីថ្លៃទឹក ត្រីមាសទី ៤ និងថ្លៃភ្លើងខែធ្នូមិនទាន់គិតនៅឡើយក្តី ) យើងខិតខំសំចៃសល់ប្រាក់ថវិកា គ្មានការខ្ជះខ្ជាយអស់ប្រាក់គ្រោងឡើយ ( គឺសល់ប្រាក់គ្រោង ២០.០០០៛ – ១៤.៩០៧ ៛ ២០ = ៥.០៩២ ៛ ៨០ )

## ១_ ផ្នែកចំណូល

សូមបញ្ជាក់ថា ចំណូលក្នុង ៣ ត្រីមាសមុនមាន: ១.៤២៨.២៤៧៛៨១ ដែលបានមកពីលក់សៀវភៅនានា ។

មកទល់ថ្ងៃទី ៣១ ធ្នូ ១៩៦៦ នេះ ចំណូលសរុបឡើងដល់ ១.៨២៣.៣៨៤៛១១ ។

បញ្ជាក់ ៖ បើប្រៀបធៀបទៅនឹងចំណូលឆ្នាំ ១៩៦៥ ដែលមានដល់ទៅ ២.៤៤៤.២៧៤៛៦១ យើងឃើញថាឆ្នាំ ១៩៦៦ នេះ ចំណូលថយបន្តិច ។

ការថយចំណូលនេះ ហេតុទី ១ បណ្តាលមកអំពីក្រសួងធម្មការបានដកសៀវភៅ ១៦ មុខ របស់ធម្មសម្បត្តិចេញអំពីវិជ្ជាឋាននេះ ។ ហេតុទី ២ ថវិកាឆ្នាំទៅ គ្រោងបោះសៀវភៅខ្វះខ្វះ ពុំបានគ្រប់ចំនួនត្រូវការរបស់សាធារណជន ។ ហេតុទី ៣ គឺសៀវភៅបីមុខរបស់ពុទ្ធិកវិទ្យាល័យ ត្រូវបោះពុម្ពផ្សាយ ទាំងអស់មាន ២៤ មុខ ( បោះពុំទាន់ហើយគឺ កច្ចាយនូបត្ថម្ភ ភាគ ១ និងធម្មបទដ្ឋកថា ភាគ ១ និង ២ ) ។ ហេតុទី ៤ គឺ មកពីបណ្ណាគារក្រៅ បានលួចចម្លងយកសេចក្តីរៀងគន្ថសៀវភៅធម៌ជាដើមរបស់ក្រសួង ទៅបោះពុម្ពលក់ថោកជាងដើមក្រសួង, ប៉ុន្តែឥឡូវ យើងបានសម្រេចប្តឹងឲ្យប្រមូលដកហូត នូវសៀវភៅក្លែងបន្លំទាំងនេះហើយ ។ ហេតុទី ៥ មកពីយើងឲ្យកម្រៃភាគរយតិចពេក តែត្រឹម ១០ ភាគរយ ដល់ឈ្មួញជាវដុំយកទៅលក់ក្រៅ ( វិជ្ជាឋាន រង់ចាំតែព្រះរាជក្រឹត្យរៀបចំក្រសួង ដែលសព្វថ្ងៃនៅគណៈរដ្ឋមន្ត្រី ពុំទាន់ជំនុំអនុម័តនៅឡើយ នោះទើបសម្រួលច្បាប់

ចុះកម្រៃឲ្យបានសមសួនដល់ឈ្មួញខ្លះ ដើម្បីជាមធ្យោបាយជួយឲ្យសៀវ-ភៅយើងដាច់ច្រើន ) ។

**យោបល់** : ប៉ុន្តែចំណូលដែលចុះប៉ុណ្ណោះ គឺគង់តែឃើញថា បើប្រៀបធៀបទៅនឹងគ្រោងថវិកា សម្រាប់បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៦៦ ចំនួនប្រាក់ ១.៨០០.០០០៛០០ នោះ វិជ្ជាឋាន បានប្រើកកម្រៃចំណេញជូនថវិកាជាតិចំនួន ៤៣.៣៨៤៛១១ ដែរ ។ គឺថាយើងគ្មានខាត បើប្រៀបធៀបទៅនឹងឆ្នាំមុន គឺឆ្នាំ ១៩៦៤ ចុះទៅ ។

**សេចក្តីស្នើសុំ** : វិជ្ជាឋាន ចង់សុំក្រសួងធម្មការ ឲ្យផ្តល់សៀវភៅ ៤៤ មុខ ខាងពុទ្ធិកវិទ្យាល័យ មកឲ្យវិជ្ជាឋានផ្ទាល់ ចាត់ចែងបោះដោយថវិកាខាងវិជ្ជាឋានតែម្តង ដើម្បីងាយស្រួលក្នុងកិច្ចការទទួលខុសត្រូវផង ។

សូមបញ្ជាក់ថាពីមុន ពុទ្ធិកវិទ្យាល័យ ឬក្រសួងធម្មការ គ្រោងថវិកាបោះពុម្ពសៀវភៅ ៤៤ មុខដែលសុំនេះ ដោយគ្មានសួរវិជ្ជាឋានថា បោះប៉ុន្មាន ៗ ក្បាលទេ ។ លុះបោះហើយ ស្រាប់តែប្រគល់ចំនួនសៀវភៅ មកឲ្យវិជ្ជាឋានដាក់ឃ្លាំង ហើយលក់យកប្រាក់ដាក់ថវិកាវិញ ។ លំបាកម្យ៉ាងទៀតគឺ កាលណាពុទ្ធិកវិទ្យាល័យ សុំធម្មការបោះពុម្ព គឺពុំមានសួរគណៈកម្មការអ្នកប្រាជ្ញ ( មានគណៈកម្មការព្រះត្រៃបិដកជាដើម) ទេ ហើយលុះបោះចេញទៅមានខុស ឧទាហរណ៍

ដូចជាសៀវភៅភិក្ខុបាតិមោក្ខ ដែលសម្តេចព្រះសង្ឃរាជផ្ញើមក ប្រាប់ថា ខុសពេញពាសជាដើម ហើយវិជ្ជាឋាន ដែលគ្រាន់តែទទួលលក់នោះ ត្រូវទទួលទោសទាំងអស់ទៅវិញ ។

## ៤. ការបោះពុម្ពផ្សាយ

ដូចមានសេចក្តីរាយការណ៍ ចុះថ្ងៃ ៣១-៩ ៦៦ ផ្ញើមកក្រសួងធម្មការស្រាប់ ។

## ៥- ការជាតាំងចំពោះអង្គការនានា

ក្រសួងបានសម្រេចផ្ញើព្រះត្រៃបិដកពីភាគ ១ ដល់ ៩០ ( ៩០ ភាគ ) តាមសេចក្តីស្នើសុំរបស់ ឯ.ឧ. ហ៊ុយ - កន្ធុល ឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងម៉ូស្គូ ទៅតំកល់ទុកនៅវត្តមួយ ជាមជ្ឈមណ្ឌលពុទ្ធសាសនា នាក្រុងប៊ែរឡាំងខាងលិច ( លិខិតយល់ព្រមផ្តល់តាមសុំផ្ញើទៅធម្មការ លេខ ២០១៨.ពប ចុះថ្ងៃទី ៣១ ១២-៦៦ ) ។

## ៦- សេចក្តីសន្និដ្ឋាន

វិជ្ជាឋានដែលបានធ្វើកិច្ចការ ដូចរៀបរាប់ក្នុងរាយការណ៍ពេញ១ឆ្នាំមកនេះ ក៏នៅតែយល់ថា បានលទ្ធផលបន្តិចប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៦៧ នេះ វិជ្ជាឋាននឹងខិតខំបន្តសកម្មភាពឲ្យកាន់តែបានចំរើនដុះដាលតទៅទៀត ។

ភ្នំពេញ ថ្ងៃទី ៣១ ធ្នូ ១៩៦៦

នាយកនៃពុទ្ធសាសនបណ្ឌិត្យ

ហត្ថលេខា : ឈាង-ហ៊ាបអាន

# អនុសំវច្ឆរមហាសន្និបាតទី ២៣ នៃមន្ត្រីសង្ឃ

ញ.សឿង រៀបរៀង

ពិធីអនុសំវច្ឆរមហាសន្និបាតទី ២៣ នៃមន្ត្រីសង្ឃ សម្រាប់ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥០៩ បានប្រព្រឹត្តទៅ ក្នុងបរិយាកាសដ៏រីករាយយ៉ាងក្រៃលែង ពីថ្ងៃសុក្រ ៤ រោចខែបុស្ស ព.ស. ២៥០៩ (៣០ ធ្នូ ១៩៦៦) ដល់ថ្ងៃពុធ ៩ រោច ខែ-ឆ្នាំដដែល ( ៤ មករា ១៩៦៧ ) នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ( រួមទាំងពីរគណៈ ) ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ, នៅវត្តឧណ្ណាលោម ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងនៅវត្តបទុមវតី ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃនាយក គណៈធម្មយុត្តិកនិកាយ ( តាមកម្មវិធីនៃគណៈទាំងពីរ ) ។

យើងសូមរៀបរាប់សង្ខេប ចំពោះតែពិធីក្នុងថ្ងៃសៅរ៍ ៥ រោច ខែបុស្ស ព.ស. ២៥០៩ ( ៣១-១២-៦៦ ) ដែលជាថ្ងៃប្រជុំធំ រួមព្រះសង្ឃទាំងពីរគណៈ ពេលម៉ោង ៤ កន្លះរសៀល នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះប្រមុខរដ្ឋ ។ បន្ទាប់ពីព្រះសង្ឃស្វាធ្យាយធម៌ជយន្តោ ថ្វាយព្រះពរជ័យចំពោះសម្តេចឪ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភករូបហើយមក, សហជីវិន គុយ-គៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា រៀបរាប់អំពីសកម្មភាពនៃព្រះ

ពុទ្ធសាសនា, រួចហើយព្រះតេជព្រះគុណ ហោម - សឹម វិនយធរនៃមេគណខេត្តតាកែវ ជាតំណាងមន្ត្រីសង្ឃទាំងអស់ បានថ្វាយសុន្ទរកថាសង្ខេបមួយទៀត ( សុន្ទរកថាទាំងពីរនេះ យើងនឹងចុះផ្សាយក្នុងទំព័រខាងក្រោយ ) ។

បន្ទាប់ពីនេះ, សម្តេចព្រះប្រមុខរដ្ឋ ទ្រង់បានថ្វាយព្រះសន្ទកថាមួយ ជាកិច្ចប្រស័យ ចំពោះមន្ត្រីសង្ឃ, ព្រមទាំងព្រះសង្ឃទាំងអស់ ដែលបាននិមន្តមកយ៉ាងច្រើនកុះករណែនណាន់តាន់តាប់ ពាសពេញទីបរិវេណនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។ ជាដំបូង, ព្រះអង្គទ្រង់មានព្រះបន្ទូលអំពីការចំរើនលូតលាស់ជាអតិបរមា នៃវិស័យពុទ្ធសាសនា និងវិស័យដទៃទៀត ដោយសារព្រះសង្ឃទាំងអស់ មានសាមគ្គីធម៌ជួយដឹកនាំគាំទ្រយ៉ាងពេញបន្ទុក ស្របទៅតាមគន្លងការសង្គមរាស្ត្រនិយម ដែលជាលទ្ធិ សង្គមនិយមអាស្រ័យពុទ្ធសាសនា ។ ចំពោះការលូតលាស់នេះ, ទ្រង់មានព្រះបន្ទូលថែមថា : តាមការពិនិត្យសង្កេតរបស់ជនបរទេស ឃើញថា នៅប្រទេសកម្ពុជា វិស័យទាំងឡាយ សឹងបានចំរុងចំរើនលូតលាស់យ៉ាងស្តុកស្តម្ភសម្បើមណាស់ លើកលែងតែសាសនាកាតូលិកចេញ ។ មានកាសែតកាតូលិកមួយបានផ្សាយថា នៅស្រុកឯទៀត ១ គេបានឃើញបណ្តាជនក្រីក្រហោមហោម ដើរសុំទានជាហេតុនាំឲ្យជនបរទេសធុញទ្រាន់ណាស់ ចំណែកនៅប្រទេសកម្ពុជា

គ្មានស្ពានការពុនជាបែបនោះទេ — ភ្នំពេញជាទីក្រុងមួយស្អាតស្អំសក្តិសមស្រស់បំព្រង គួរឲ្យគោតសរសើរណាស់ ... ។ ចំពោះសាសនាវិញ ខ្មែរជឿកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនមុតមាំណាស់, គេមិនអាចនឹងឃោសនាពន្យល់ខ្មែរឲ្យជឿសាសនាដទៃទៀត មានគ្រិស្តសាស-នាជាដើម ដោយងាយៗបានទេ — ខ្មែរមិនស្គាល់គ្រិស្តសាសនាថាជាយ៉ាងណាៗទេ — ខ្មែរសំគាល់ថាគ្រិស្តសាសនា គឺជាសាសនា-របស់ជនជាតិអឺរ៉ុប ... ។ សម្ដេចឪ ព្រះអង្គទ្រង់សរសើរហើយសរសើរទៀត ចំពោះសម្ដេចព្រះពោធិវង្ស ដែលបានយកព្រះទ័យទុកដាក់យ៉ាងប្រិតប្រៀបជាទីបំផុត ក្នុងការរុះរើ-ស្ថាបនាជាថ្មីឡើងវិញ នូវអគារទាំងឡាយនៃពុទ្ធិកវិទ្យាល័យ, ជាពិសេសទៅទៀត ព្រះអង្គបានបរិច្ចាគបច្ច័យចំនួន ហុកសិបម៉ឺនរៀល ( ៦០០.០០០៛ ) សម្រាប់បង្ហើយការស្ថាបនានេះ ។

គពីនេះទៀត, សម្ដេចឪ ទ្រង់មានព្រះបន្ទូលអំពីនយោបាយក្នុងប្រទេស និងក្រៅប្រទេសនៃកម្ពុជាអព្យាក្រឹត យ៉ាងពិស្តារ ដែលគ្រប់ចំណុចទាំងអស់ សុទ្ធតែមានសារៈសំខាន់ ពីរោះក្បោះក្បាយ ព្រះសង្ឃនិងបណ្ដាជនទាំងឡាយ បានចាប់អារម្មណ៍ ប្រុងស្ដៀងស្ដាប់យ៉ាងផ្ចិតផ្ចង់ដក់ជាប់ចិត្តឥតធុញទ្រាន់ ដរាបដល់ចប់ព្រះសន្ទរកថានេះ នៅពេលម៉ោង ៧ យប់ ក្នុងបរិយាកាសដ៏សែនរីករាយយ៉ាងក្រៃលែង ។

សូមលោកអ្នកអាន មេត្តាអភ័យទោស ចំពោះការពុំអាចលើកយកព្រះសន្ទរកថាទាំងស្រុងរបស់សម្តេចៗ មកចុះផ្សាយក្នុងទំព័រនេះបាន ។

ឯសុន្ទរកថារបស់សហជីវិន គុយ-ពៅ និងព្រះវិនយធរ សោម-សឹម តំណាងមន្ត្រីសង្ឃ, យើងសូមចុះផ្សាយដូចតទៅនេះ ៖

## សុន្ទរកថា សហជីវិន គុយ-ពៅ

អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនសិក្សាធិការ

សូមព្រះតេជះតម្កល់លើត្បូង

សូមព្រះករុណាគ្រាបបង្គំទូល ក្រោមលម្អងធូលីព្រះបាទ នៃសម្តេច សហជីវិន ព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

នៅក្នុងពិធីអនុសំវច្ឆរមហាសន្និបាត នៃមន្ត្រីសង្ឃលើកទី ២៣ ប្រចាំឆ្នាំមមែអដ្ឋស័ក ព.ស. ២៥០៩ នេះ, ទូលព្រះបង្គំជាខ្ញុំ, ក្នុងនាមនៃក្រសួងធម្មការ និងសាសនសិក្សាធិការ និងក្នុងនាមពុទ្ធបរិស័ទទាំងអស់ក្នុងប្រទេសកម្ពុជា សូមថ្វាយនូវព្រះមហាករុណាធិគុណ យ៉ាងរំភើប និងយ៉ាងកក់ក្តៅបំផុត ចំពោះព្រះរាជាធិបតីភាព ដែលលម្អងធូលីព្រះបាទ បានទ្រង់សព្វព្រះរាជហឫទ័យ ស្តេចព្រះរាជដំណើរដល់ពិធីសម្ពោធបើកមហាសន្និបាតនៃព្រះសង្ឃ ក្នុងឱកាសដ៏មហោឡារិកនេះ ដែលមានប្រជុំរៀងរាល់ឆ្នាំ ដើម្បីពិភាក្សាចំពោះបញ្ហានានាទាក់ទងព្រះពុទ្ធសាសនា ។

សូមទ្រង់ព្រះមេត្តាប្រោស

អនុស្សាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃនេះ បានកើតឡើងចំនួន ២៣ ឆ្នាំហើយ គប់តាំងឆ្នាំនេះផង គឺជាលទ្ធផលដ៏វិសេសក្រៃលែងនៃការឧបត្ថម្ភរបស់រាជបល្ល័ង្ក ចំពោះព្រះពុទ្ធសាសនា ដែលជាសាសនាសុខចំរើនបំផុតក្នុងលោក ហើយជាពិសេស គឺសម្តេចជាអម្ចាស់ កាលដែលព្រះអង្គនៅគង់គ្រប់គ្រងរាជសម្បត្តិនោះ ទ្រង់បានបង្កបង្កើតឲ្យមានឡើង ។ ដូច្នេះ អាចសន្មតយ៉ាងខ្លីបានថា មហាសន្និបាតនៃព្រះសង្ឃនេះ មានអាយុកាល ២៣ ឆ្នាំហើយ ជាបុត្រផ្ទាល់របស់សម្តេចជាអម្ចាស់ ។ មិនតែប៉ុណ្ណោះ, សម្តេចជាអម្ចាស់ទ្រង់តែងស្តេចយាងមកជាព្រះរាជាធិបតីរៀងរាល់ឆ្នាំ រឹងរឹតតែបង្ហាញឲ្យឃើញថា ព្រះអង្គតែងសព្វព្រះរាជហឫទ័យជានិច្ច ចំពោះមហាសន្និបាតនេះ ។ ដូច្នេះហើយ កិច្ចការអ្វីដែលទាក់ទងនឹងព្រះពុទ្ធសាសនាក្តី ទាក់ទងនឹងកិច្ចការរដ្ឋក្តី ព្រះអង្គពុំដែលលាក់លៀមម្តងណាទេ ទ្រង់តែងតែថ្លែងជាឱឡារិក លាតត្រដាងនូវការទាំងអស់នេះ ថ្វាយ - ប្រគេនព្រះសង្ឃនៅក្នុងវេទិកានេះជាដរាប ដូចជាព្រឹត្តិការណ៍ពីរ គឺ :

១- ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ថ្វាយព្រះឋានន្តរស័ក្តិដល់សម្តេចព្រះសង្ឃរាជ ចំពោះសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ គឺនៅត្រង់កន្លែងនេះ ។

៦– ព្រះអង្គទ្រង់ថ្លែងទៅបញ្ជាក់អំពីគោលនយោបាយខ្មែរ ហេតុព្រះអង្គទ្រង់និពន្ធបានជាសៀវភៅមួយមានចំណងជើងថា នយោបាយសង្គមនិយមព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ក៏ផ្ដើមឡើងនៅត្រង់ទីនេះដែរ ។

ហេតុការណ៍ទាំងនេះទៀត បញ្ជាក់ឲ្យឃើញថា ព្រះរាជបល្ល័ង្កខ្មែរ បានទំនុកបំរុងព្រះពុទ្ធសាសនា ជាដរាបរៀងមកជាប់ជាប្រពៃណីតាំងពីបុរាណកាល រហូតមកដល់បច្ចុប្បន្នកាល ក៏រឹងរឹតតែបន្ថែមកម្លាំងឧបត្ថម្ភឲ្យខ្លាំងក្លាឡើងទៀត ដូចជានៅពេលថ្មី ៗ នេះ ល្អងធូលីព្រះបាទ បានកសាងវត្តធំៗ ពីរទៀត គឺវត្តជោតញ្ញាណ ១ ឥន្ទញ្ញាណ ១ នៅក្រុងព្រះសីហនុ ដែលទើបសម្ពោធ ហើយប្រោសព្រះរាជទានដល់ព្រះសង្ឃ និងពុទ្ធសាសនិកជន ធ្វើសក្ការបូជាចង្កើនរុងរឿង ជាកិត្យាភាពក្នុងព្រះពុទ្ធសាសនា ។ ដោយសារព្រះរាជហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនានេះ អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃរៀងរាល់ឆ្នាំ ដែលប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គ ឬព្រះអធិបតីភាព នៃសម្ដេចព្រះសង្ឃនាយកនោះ តែងតែបានលទ្ធផលល្អពិភាក្សាសម្រេចនូវបញ្ហាធំ តូចផ្សេង ៗ ដែលកើតមានក្នុងរយៈឆ្នាំដែលកន្លងទៅ និង រៀបចំសម្រាប់ឆ្នាំទៅមុខទៀត ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំសូមព្រះរាជទាន ព្រះបរមរាជឱកាស ដើម្បីក្រាបបង្គំថ្វាយអំពីកិច្ចការខ្លះ ដែលក្រសួងធម្មការបានបំពេញមក ក្នុងរយៈឆ្នាំនេះ :

១- ផ្នែកវិជ្ជាស្ថានស្រាវជ្រាវទំនៀមទម្លាប់ ៖ កិច្ចការខាងការស្រាវជ្រាវទំនៀមទម្លាប់ និងប្រវត្តិផ្សេង ៗ ក៏ប្រមូលបានឯកសារសំខាន់ ៗ ពីគ្រប់ភូមិភាគក្នុងប្រទេសបានកើនចំនួនលើសពីឆ្នាំមុនដែរ ជាហេតុនាំឲ្យមានអ្នកប្រាជ្ញ អ្នកស្រាវជ្រាវក្នុងស្រុក និងបរទេសជាច្រើន ចេញចូលទាក់ទងជាមួយបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ដែលព្រះរាជបល្ល័ង្កបានបង្កើតឡើងរាប់ជាង ៤០ ឆ្នាំមកហើយ ។ មានមនុស្សជនបរទេសនានា គេទទួលស្គាល់ថា បណ្ណាល័យយើងនេះ ជាមជ្ឈមណ្ឌលខាងវប្បធម៌ជាតិយ៉ាងសំខាន់ផង ។ មិនតែប៉ុណ្ណោះ ក្រសួងបានអំពាវនាវឲ្យវត្តនានា បង្កើតបណ្ណាល័យប្រចាំវត្ត ដោយអនុគ្រោះឲ្យជាសៀវភៅបណ្តាក់ ហើយនិងប៉ុះតម្លៃយ៉ាងថោកថែមទៀតផង មកទល់នឹងពេលនេះ មានវត្តចំនួនជិតមួយពាន់ហើយ ដែលបានបង្កើតបណ្ណាល័យតាមសេចក្តីអំពាវនាវ ។

២- ផ្នែកបោះពុម្ពផ្សាយ ៖ ចំពោះកិច្ចការបោះពុម្ពផ្សាយក្បួនខ្នាតផ្សេង ៗ នៅឆ្នាំនេះ បានកើនច្រើនជាងឆ្នាំមុន ។ គឺបោះពុម្ពហើយស្រេចបានចំនួនសៀវភៅ ១៦៤.៧១០ ក្បាល ចែកចេញជា ៥៤ ឈ្មោះផ្សេង ៗ គ្នា ។ ក្នុងចំនួននេះ មានខ្លះជាសៀវភៅចាស់បោះពុម្ពឡើងវិញ និងខ្លះទៀតជាសៀវភៅតែងថ្មី ៗ ឯព្រះត្រៃបិដក ក៏ចេញផ្សាយបាន ៩០ ភាគហើយ ក្នុងចំនួន ១១០ ភាគ

ដែលបានប្រែតម្រឹមតម្រង់ប្រសើរ ៗ

៣- ផ្នែកការសិក្សាខាងព្រះពុទ្ធសាសនាវិញ ក៏មានដំណើរល្អ ទាំងខាងផ្នែកគន្ថធុរៈ និងវិបស្សនាធុរៈព្រមគ្នា ៗ ខាងផ្នែកគន្ថធុរៈ រដ្ឋាភិបាល បានចាត់ចែងឲ្យមានសាលាធម្មវិន័យ ដែលបានបើកបង្រៀនហើយចំនួន ១.០៥៦ សាលា មានសិស្ស ១៥.៩៥១ រូប មានសាលាពុទ្ធិកបឋមសិក្សា ៦៦៧ មានសិស្ស ១០.៣៨៣ រូប ហើយសាលាបឋមសិក្សានេះ ត្រូវមានការកែទម្រង់ថ្មីលើសម្តេចព្រះមហាក្សត្រិ-យានី ជាម្ចាស់ជីវិតលើត្បូង និងសម្តេចសហជីវិន បានទ្រង់ព្រះមេត្តាប្រោស តាមសេចក្តីទូលស្នើនៃសម្តេចព្រះពោធិវង្ស ជាអគ្គាធិការនៃពុទ្ធិកសិក្សា ក្នុងព្រះរាជាណាចក្រ ក៏បានប្រកបទៅដោយដំណើរល្អ ឥតអ្វីជាឧបសគ្គដែរ ៗ សព្វថ្ងៃ សាលាពុទ្ធិកបឋមសិក្សាបែបទម្រង់ថ្មី មានចំនួន ៦១ ចែកជា ៨៧ ថ្នាក់រៀន និងមានសមណ-សិស្សចំនួន ២.៩៥៩ រូប គឺទើបតែបង្កើតនៅគ្រប់ទីប្រជុំជនស្រុក ក្នុងខេត្តសំខាន់ ៗ នៅឡើយ ពុំទាន់បានដល់ខេត្តថ្មី ៗ នៅឡើយទេ ៗ ដូច្នេះ បានជាគ្រោងការក្នុងឆ្នាំថ្មីនេះ នឹងត្រូវបង្កើនថ្នាក់ បន្ថែមគ្រូសម្រាប់នៅទីថ្មី ៗ ទៀត ដើម្បីបំពេញកិច្ចត្រូវការ របស់បណ្តាពុទ្ធបរិស័ទគ្រប់ដំបន់ទាំងនោះ ៗ ព្រោះរបៀបកែទម្រង់ថ្មីនេះ ជាទិសដៅតែមួយនៃកិច្ចសិក្សាក្នុងពុទ្ធចក្រ ឲ្យស្របគ្នាទៅនឹងការសិក្សាខាងអាណាចក្រ

ដែលសព្វថ្ងៃកំពុងតែមានវឌ្ឍនភាពជាអតិបរមា ក្រោមព្រះរាជកិច្ចដឹកនាំ នៃសម្តេចសហជីវិន ជាប្រធាននៃសង្គមរាស្ត្រនិយម ។ វត្ថុបំណងនេះ ក៏កើតឡើងពីព្រះរាជតម្រាស់ដាស់តឿននៃល្អងធូលីព្រះបាទ ដែលទ្រង់បានថ្លែងផ្តាំផ្ញើនៅទីនេះដែរថា : សមណនិស្សិត ក៏ជាអនាគតពលរដ្ឋយើងប្រពៃណាស់ សំរាប់បំរើប្រទេសជាតិទៅអនាគត ។ ព្រះរាជបន្ទូលសូរសីហនាទនេះ មានន័យទូលាយអនេកអនន្តណាស់ ដែលទូលព្រះបង្គំទាំងអស់ខំប្រតិបត្តិមិនឲ្យខ្វះឡើយ ហេតុនេះ បានជាត្រូវសំរិតសំរាំងរើសគ្រូ ដើម្បីយកទៅបង្រៀនសាលាទាំងនេះ ឲ្យមានសមត្ថភាព និងគុណសម្បត្តិបរិបូណ៌ ដោយបើកការប្រឡងជ្រើសរើសយ៉ាងតឹងរ៉ឹង កាលពីឆ្នាំ ១៩៦៥ មុន និងកាលពីដើមឆ្នាំ ១៩៦៦ នេះមុន ហើយបានគ្រោងថា នឹងជ្រើសរើសសម្រាប់ឆ្នាំសិក្សាថ្មីតទៅទៀត ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ថ្លែងក្នុងនាមព្រះរាជរដ្ឋាភិបាល នូវអំណរព្រះករុណាធិគុណ និង កតញ្ញូតាធម៌ដ៏លើសលប់ថ្វាយចំពោះសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក, សម្តេចព្រះពោធិវង្ស ដែលព្រះអង្គទ្រង់តែងតែប្រឹងប្រែងពេញព្រះកាយពល ឧបត្ថម្ភកិច្ចការគ្រប់បែប កង្វល់ពុទ្ធចក្រឲ្យប្រកបដោយសេចក្តីចំរើនមហិមា

គ្រប់គ្រាគ្រប់កាល ពិសេសគឺព្រះអង្គទ្រង់ត្រិះរិះរកមធ្យោបាយល្អ ៗ ជួយប្រទានព្រះរាជយោបល់ដល់ក្រសួងធម្មការ ។ ទូលព្រះបង្គំជាខ្ញុំ - ខ្ញុំព្រះករុណា ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ពុំអាចភ្លេចបានឡើយ ចំពោះព្រះគតិបណ្ឌិតទាំងនេះ ។

មួយចំណែកទៀត ទូលព្រះបង្គំជាខ្ញុំ សូមឆ្លៀតឱកាសដ៏ឧឡារិកនេះ ថ្វាយអំណរព្រះគុណចំពោះព្រះតេជព្រះគុណរាជាគណៈ ឋានានុក្រម មេគណ អនុគណ និងចៅអធិការគ្រប់ព្រះអង្គ ដែលបានជ្រោមជ្រែងពេញសមត្ថភាព ឥតសំចៃកម្លាំង រួបរួមគ្នាធ្វើឲ្យកិច្ចពុទ្ធចក្រលឿនទៅមុខ ស្មើគ្នានឹងល្បឿននៃកិច្ចអាណាចក្រដែរ ឧទាហរណ៍ដូចជាខិតខំជួយដល់រាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច វប្បធម៌ មានជាអាទិ៍គឺ ការដាំដើមឈើ, ជីកអណ្ដូងទឹក, ស្ថាបនាមន្ទីរពេទ្យ, សាលារៀន ដោយបានចូលជួយជាសកម្មផង ជាទីប្រឹក្សានៃកិច្ចការអភិវឌ្ឍន៍សហគមន៍ផង និងកិច្ចការជាច្រើនទៀត ឲ្យបានសម្រេចឡើង នៅតាមទីក្រុង និងទីជនបទនានា ស្របទៅតាមព្រះមាគ៌ានយោបាយដ៏ខ្ពង់ខ្ពស់ នៃសម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ ។

## សូមទ្រង់ព្រះមេត្តាប្រោស

នៅទីអវសាននេះ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយល្អងធូលីព្រះបាទជាថ្មីម្ដងទៀត នូវអំណរព្រះមហាករុណាធិគុណ និងកតញ្ញុតាដ៏

ជ្រាលជ្រៅ ចំពោះព្រះរាជវត្តមាននៃព្រះអង្គ និង សូមឧទ្ទិសបួងសួង ចំពោះគុណបុណ្យព្រះរតនត្រ័យ តេជានុភាពនៃព្រះពុទ្ធសាសនា និងវត្ថុស័ក្តិសិទ្ធិ ក្នុងសកលលោក ជួយអភិបាលថែរក្សាអង្គសម្តេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានប្រកបដោយព្រះបរមសុខសួស្តី ឈ្នះមារសត្រូវគ្រប់ទិសទី និងមានព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់ដ៏សុខសាន្តនៃប្រជាពលរដ្ឋខ្មែរជាកូនចៅព្រះអង្គដរាបតទៅ ។

ជយោ ! ព្រះរាជបល្ល័ង្ក

ជយោ ! សម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

ជយោ ! សង្គមនិយមព្រះពុទ្ធសាសនា

សូមព្រះតេជះតាំកល់លើត្បូង

---

## សុន្ទរកថា

ព្រះវិនយធរ សោម សឹម កំណាងមន្ត្រីសង្ឃ

សូមថ្វាយព្រះពរសម្តេចព្រះប្រមុខរដ្ឋ អគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃគ្រប់ឋានៈ ក្នុងព្រះរាជធានីភ្នំពេញ និងក្នុងខេត្តក្រៅ ដែលស្ថិតនៅក្រោមព្រះឱវាទ នៃសម្តេចព្រះសង្ឃរាជ និងសម្តេចព្រះសង្ឃនាយក តាំងពីព្រះអង្គ ហើយដែលបាននិមន្តមកជួប

ជុំក្នុងមហាសន្និបាតនេះ អាត្មាភាព សូមថ្វាយព្រះពរ ថ្លែងនូវអំណរដ៏ក្រៃលែង ចំពោះព្រះមហាករុណាធិគុណដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះប្រមុខរដ្ឋ អគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីអនុស្សាវរីយ៍មហាសន្និបាតទី ២៣ នៃមន្ត្រីសង្ឃនេះ ។

សូមថ្វាយព្រះពរ

អម្បាញ់មិញនេះ លោកអ្នកឧកញ៉ាអនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសេចក្តីថ្វាយពតិមាន អំពីមហាសន្និបាតនេះ ដែលមានសេចក្តីជាប់ទាក់ទងចំពោះព្រះមហាក្សត្រ ចំពោះព្រះពុទ្ធសាសនា ចំពោះព្រះសង្ឃ និង ចំពោះប្រទេសជាតិរួចហើយ ។

ឥឡូវនេះ អាត្មាភាព ជាតំណាងមន្ត្រីសង្ឃទាំងអស់ សូមព្រះរាជទានព្រះរាជឱកាស ថ្វាយពតិមាន បន្ថែមយ៉ាងសង្ខេប អំពីព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា សម័យបច្ចុប្បន្នដូចតទៅនេះ ៖

សូមថ្វាយព្រះពរ

សម័យបច្ចុប្បន្ននេះ ទោះបីជនរួមជាតិ ជា ឧបាសក ទាយក ពុទ្ធសាសនិកនៅតាមព្រំដែន បានទទួលរងគ្រោះថ្នាក់មួយដងមួយកាល ដោយការឈ្លានពានអំពីបរទេសជិតខាង, ក៏អាចសន្និដ្ឋានបានថា ពុទ្ធ-សាសនិកជន ទាំងគ្រហស្ថ ទាំងបព្វជិត ក្នុងប្រទេសកម្ពុជាទាំង

មូល បានប្រកបដោយសេចក្ដីសុខសាន្ត ស្ទើរតែឥតមានទុក្ខព្រួយ ប្រសើរវិសេសជាងពុទ្ធសាសនិកជន នៅប្រទេសជិតខាងជុំវិញកម្ពុជរដ្ឋ យើង ព្រោះថា ដូចជាកិត្តិយស ដែលយើងធ្លាប់បានទទួលរៀងមក, ប្រទេសខ្មែរយើង ជាកោះសន្តិភាព នៅកណ្ដាលសមុទ្រនៃភ្លើងសង្គ្រាម ។

ដោយអាស្រ័យនូវសេចក្ដីសុខសាន្តនេះ ព្រះសង្ឃទាំងឡាយ សឹងមានឱកាសគ្រប់គ្រាន់ ក្នុងដំណើរបំពេញគន្ថធុរៈ គឺការសិក្សាធម៌វិន័យព្រះពុទ្ធសាសនា និងវិបស្សនាធុរៈ គឺការដុសខាត់ សម្រិតសម្រាំងចិត្តគំនិតឲ្យបានថ្លៃថ្នូរ និងការកសាងបង្កើតសមិទ្ធិថ្មី ៗ ក្នុងព្រះពុទ្ធសាសនា ព្រមទាំងជួយបំពេញសង្គមកិច្ច ចំពោះត្រង់ណា ដែលមិនពាស់ខុសនឹងវិន័យបញ្ញត្តិ ។

ព្រះសង្ឃទាំងអស់ បានដឹងច្បាស់ណាស់ថា ប្រទេសកម្ពុជា ដែលប្រកបដោយឯករាជ្យ, អព្យាក្រឹត្យ និងសេចក្ដីសុខ · ចម្រើន មានសមិទ្ធិកើនចំនួនជាទិចកល់ថ្លៃ ទាំងព្រះពុទ្ធសាសនា ក៏មានការលូតលាស់ចម្រើនជាលំដាប់មកយ៉ាងនេះ ប្រាកដជាដោយសារព្រះបញ្ញាញាណដ៏វាងវៃ និងព្រះនយោបាយដ៏ភ្លឺថ្លា ព្រមទាំងព្រះគតិបណ្ឌិតដ៏ឆ្នើម នៃសម្ដេចព្រះប្រមុខរដ្ឋជាអម្ចាស់ ដែលជាព្រះឯកអគ្គមគ្គុទ្ទេសក៍ដ៏ប្រសើរបំផុត ។

ព្រះសង្ឃទាំងអស់ តែងមានកតញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់ ចំពោះសម្ដេច

ជាអម្ចាស់ ឥតមានភ្លេចព្រះឧបការគុណដ៏លើសលុបរបស់ព្រះអង្គ ដែលទ្រង់បានកសាងសុខសន្តិភាព ព្រះរាជទានដល់ប្រជាពលរដ្ឋទូទៅ ដោយនយោបាយសង្គមនិយមព្រះពុទ្ធសាសនា ដែលជានយោបាយឯកតែមួយសម្រាប់មាតុភូមិជាទីស្រឡាញ់ គឺប្រទេសកម្ពុជា ព្រមទាំងសម្រាប់សកលពិភពលោកផង ។

សូមថ្វាយព្រះពរ

មន្ត្រីសង្ឃទាំងអស់ នៅចាំជាក់ថា ទីកន្លែងនៃមហាសន្និបាតនេះ ដែលផ្តល់ឱកាសមហាប្រសើរ ឲ្យបានជួបព្រះភក្ត្រជាទីស្នេហា ជាទីទឹករលឹក នៃសម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភកជាអម្ចាស់, កាលដើមឡើយក្នុងសម័យអាណាព្យាបាលបារាំង, ជាបរិវេណនៃសាលាបាលីជាន់ខ្ពស់ ។ ចាប់តាំងពីសម័យដែលប្រទេសកម្ពុជា ត្រឡប់បានឯករាជ្យមក, ក្រោមព្រះរាជូបត្ថម្ភនៃព្រះបរមមហាក្សត្រ, ដោយសារព្រះរាជសទ្ធាជ្រះថ្លាដ៏មោះមុត និង ព្រះបំណងដ៏ឧត្តម ដើម្បីលើកឋានៈចំណេះវិជ្ជានៃព្រះសង្ឃសាលាបាលីជាន់ខ្ពស់ ក៏បានប្រែនាមបញ្ញត្តិជា ពុទ្ធិកវិទ្យាល័យព្រះសុក-ម្រឹត ដោយមានសកលវិទ្យាល័យព្រះសីហនុរាជ បានចាប់សម្ពោធឡើង ដើម្បីនាំដំណើរនៃពុទ្ធិកសិក្សា ឲ្យបានទៅដល់ទីបំផុត ។ មិនត្រឹមតែការកែប្រែនាមបញ្ញត្តិ និងឋានៈនៃការសិក្សាប៉ុណ្ណោះទេ ទោះទាំងរូបរាងដែលមានសភាពទ្រុឌទ្រោមចាស់គ្រាំគ្រា ក៏សម្តេចព្រះប្រមុខរដ្ឋ

ជាម្ចាស់ ទ្រង់មានព្រះបញ្ញា ឲ្យកែប្រែ ឲ្យមានសម្រស់ និងសភាព ថ្កោងថ្កើងវិញដែរ ។ ការកែប្រែទាំងខាងគុណសម្បទ ទាំងខាងរូបសម្បទនេះ មន្ត្រីសង្ឃគ្រប់រូប និងពុទ្ធបរិស័ទជាគ្រហស្ថគ្រប់គ្នា បានឃើញប្រត្យក្ស ថ្ងៃកហើយថ្ងៃកទៀតរៀងរាល់ឆ្នាំ ។ ភិក្ខុសង្ឃខ្មែរតែងបានទទួលភាពត្រជាក់ត្រជុំ ដោយសារទឹកព្រះហឫទ័យដ៏ថ្លៃថ្លា នៃសម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ជាទីស្នេហាតែមួយព្រះអង្គ ។ មន្ត្រីសង្ឃមានសង្ឃឹមមាំ លើកិច្ចទំនុកបម្រុងតទៅអនាគត នៃព្រះរាជរដ្ឋាភិបាលថា ការសិក្សាក្នុងព្រះពុទ្ធសាសនា នឹងមានដំណើរទៅកាន់វឌ្ឍនភាពជាលំដាប់ ។

ជាទីបញ្ចប់នេះ, អាត្មាភាព, ក្នុងនាមនៃព្រះសង្ឃទាំងអស់, សូមថ្វាយព្រះពរបវរសួស្តី ជោគជ័យ មហាមង្គល វិបុលសុខគ្រប់ប្រការ ចំពោះសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត, ចំពោះសម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គមគ្គុទ្ទេសក៍ :

— សូមព្រះអង្គបានប្រកបដោយព្រះជន្មាយុយឺនយូរ ជាងរយវស្សា មានព្រះសុខភាពដ៏បរិបូណ៌ !

— មារសត្រូវគ្រប់ទិសទី កុំគប្បីយាយីបៀតបៀនព្រះអង្គបានឡើយ!

សូមថ្វាយព្រះពរ !